# ថ្ងៃទី០៣ ខែមករា ឆ្នាំ២០១៩

## ថៅកែរោងចក្រថៃ ព្រមឲ្យពលករខ្មែរ ដែលបានបណ្ដេញចេញ ចូលធ្វើការងារវិញ

https://www.rfa.org/khmer/news/ ដោយ មួង ណារ៉េត 2019-01-02

តំណាងពលករដែលធ្វើការនៅរោងចក្រ SC WADO ក្នុងខេត្តឈុនបុរី ប្រទេសថៃ ឲ្យដឹងថា ថៅកែរោងចក្រនេះបានផ្ដល់ដំណឹងដល់ពលរដ្ឋខ្មែរទាំងជាង ៥០នាក់ ដែលត្រូវបញ្ឈប់ពីការងារឲ្យចូលធ្វើការវិញហើយ។ ប្រភពដដែលអះអាងទៀតថា ថៅកែថែមទាំងឲ្យពលករខ្មែរទាំងនោះ ខ្ចីលុយស្មើនឹងប្រាក់ខែពួកគេពាក់កណ្ដាល ធ្វើជាសោហ៊ុយក្នុងការធ្វើដំណើរថែមទៀតផង។ តំណាងពលករដែលធ្វើការនៅ រោងចក្រ SC WADO លោក រស់ ប៊ុនធឿន ឲ្យអាស៊ីសេរី នៅថ្ងៃទី២ មករាថា ការសម្រេចរបស់ថៅកែថៃដែលហៅពលករខ្មែរឲ្យចូលធ្វើការងារបន្ទាប់ពីវិទ្យុអាស៊ីសេរី បានចុះផ្សាយព័ត៌មានអំពីការបញ្ឈប់ពលករខ្មែរទាំងនេះជាបន្តបន្ទាប់ ដែលធ្វើឲ្យថៅកែរោងចក្រ មានការព្រួយបារម្ភពីទង្វើរបស់ខ្លួន ស្របពេលមានការចោទប្រកាន់ថា ការបញ្ឈប់នេះ ជាការរំលោភសិទ្ធិការងារ។ លោកបន្តថា ពេលនេះ ថៅកែថៃថែមទាំងសន្យាផ្ដល់ប្រាក់ខែ និងប្រាក់លើកទឹកចិត្តផ្សេងៗ ទៀត ដល់ពលករខ្មែរ ដូចការផ្ដល់ឲ្យពលករថៃដែរ។ តំណាងពលកររូបនេះ សាទរចំពោះការបង្ហាញដំណោះស្រាយនេះ ពីភាគីថៅកែថៃបែបនេះ។ លោកបន្តថា ពេលនេះក្រុមពលករកំពុងរៀបចំធ្វើដំណើរមកប្រទេសថៃដើម្បីធ្វើការងារក្រោយទទួលដំណឹងពីថៅកែរោងចក្រ។

ដូចគ្នានេះដែរ ពលករម្នាក់លោក ជួប សាវុធ ដែលភរិយារបស់លោក បានសម្រេចវិលទៅប្រទេសកម្ពុជាវិញ ឲ្យដឹងដែរថា លោកទទួលបានដំណឹងពីរោងចក្រថា ថៅកែរោងចក្រយល់ព្រមឲ្យពលករខ្មែរ ដែលត្រូវបានបញ្ឈប់ពីការងារ ចូលធ្វើការងារវិញ។ លោកបន្តថា ពេលនេះលោកកំពុងទាក់ទងទៅភរិយារបស់លោក ដែលកំពុងនៅប្រទេសកម្ពុជា ឲ្យត្រឡប់មកធ្វើការវិញ៖

មេការរោងចក្រ SC WADO ជនជាតិខ្មែរ លោក សឿ ចន្ថា ធ្លាប់ប្រាប់ អាស៊ីសេរីឲ្យដឹង កាលពីចុងឆ្នាំ២០១៨ ថា រោងចក្រមិនសូវមានការងារធ្វើ មានបញ្ហាខ្លះកើតឡើង។ លោកថា ដើមឆ្នាំ២០១៩ នេះ ថៅកែរោងចក្ររបស់លោកអះអាងថា មានការងារគ្រប់គ្រាន់ឲ្យពលករធ្វើឡើងវិញហើយ។ ចំពោះរឿងមិនផ្ដល់លិខិតឆ្លងដែនដល់ពលករ លោកថា លោកមិនសូវដឹងច្បាស់ទេ ព្រោះការគ្រប់គ្រងលិខិតឆ្លងដែនរបស់ពលករ គឺជាការទទួលខុសត្រូវរបស់ក្រុមផ្សេង ដែលនាំពលករមកធ្វើការនៅប្រទេសថៃ៖

កាលពីចុងឆ្នាំ២០១៨ ក្នុងអំឡុងខែវិច្ឆិកា ថៅកែរោងចក្រ SC WADO ក្នុងខេត្តឈុនបុរី ប្រទេសថៃ បានបញ្ឈប់ពលករខ្មែរជាង៥០នាក់ ពីការងារ។ ពលករប្រាប់ថា អ្នកដែលត្រូវបញ្ឈប់ពីការងារ ថៅកែមិនបានផ្ដល់លិខិតឆ្លងដែនឲ្យវិញទេ ហើយពលរដ្ឋភាគច្រើន បានសម្រេចទៅប្រទេសកម្ពុជាវិញ ទាំងគ្មានលិខិតឆ្លងដែន។ សព្វថ្ងៃនេះ ទោះបីជារបបលោក ហ៊ុន សែន អះអាងថា អត្រាគ្មានការងារធ្វើនៅកម្ពុជា មានមិនដល់ ១ភាគរយក្ដី ក៏ពលករខ្មែរជាច្រើន មិនអាចរកការងារ ដែលមានប្រាក់ខែសមរម្យនៅប្រទេសរបស់ខ្លួនបាន ទើបត្រូវធ្វើចំណាកស្រុកទៅធ្វើការនៅក្រៅប្រទេស ដូចជា ប្រទេសថៃនេះជាដើម។ ឥឡូវនេះ យ៉ាងហោចណាស់មាន ពលករខ្មែរចំណាកស្រុក ដែលកំពុងធ្វើការនៅប្រទេសថៃ ទាំងស្របច្បាប់ និងខុសច្បាប់ជាងមួយលាននាក់៕

## មន្ត្រី៖ ស្ថានភាពសន្តិសុខនៅតាមព្រំដែនឆ្នាំមុនល្អជាងឆ្នាំ ២០១៧

https://www.postkhmer.com/ ម៉ិច ដារ៉ា | Publication date 03 January 2019 | 08:46 ICT

**ភ្នំពេញ៖** មន្ត្រីជាន់ខ្ពស់ក្រសួងការពារជាតិបានថ្លែងពីម្សិលមិញថា ឆ្នាំ ២០១៨ កន្លងទៅនេះកងទ័ពជើងគោកបានត្រួតពិនិត្យ ទប់ស្កាត់ និងបង្ក្រាបបទល្មើសផ្សេងៗតាមតំបន់ព្រំដែនជាង ៥ ពាន់ករណី ហើយថាស្ថានភាពសន្តិសុខនៅតាមព្រំដែនកាលពីឆ្នាំមុនមានលក្ខណៈល្អប្រសើរជាងឆ្នាំ ២០១៧ ឆ្ងាយណាស់។

នាយឧត្តមសេនីយ៍ ឈុំ សុជាតិ អនុរដ្ឋលេខាធិការ និងជាអ្នកនាំពាក្យក្រសួងការពារជាតិបានប្រាប់ភ្នំពេញប៉ុស្តិ៍កាលពីថ្ងៃទី ២ មករា ថាក្នុងឆ្នាំ ២០១៨ កន្លងទៅនេះកងទ័ពជើងគោកបានត្រួតពិនិត្យ ទប់ស្កាត់ និងបង្ក្រាបបទល្មើសផ្សេងៗសរុបបានចំនួន ៥១៩៣ ករណីនៅតាមខ្សែបន្ទាត់ព្រំដែន។ លោកក៏បានប្រៀបធៀបស្ថានភាពសន្តិសុខនៅតាមបណ្ដោយព្រំដែនក្នុងឆ្នាំ ២០១៨ ថាមានភាពល្អប្រសើរជាងឆ្នាំ ២០១៧ ទៅទៀត។ លោកបញ្ជាក់ថា៖ «ជាង ៥ ពាន់ករណីគឺពាក់ព័ន្ធបទល្មើសព្រំដែនដូចជាឆ្លងដែនខុសច្បាប់ គ្រឿងញៀន កាប់ឈើ ការនាំពលករខុសច្បាប់ ហើយបទល្មើសដែលពាក់ព័ន្ធនឹងការឆ្លងព្រំដែន។ យើងបន្តការអនុវត្តគោលនយោបាយរបស់រាជរដ្ឋាភិបាលស្ដីពីការសហប្រតិបត្តិការជាមួយប្រទេសជិតខាងដើម្បីរួមគ្នាទប់ស្កាត់នូវបណ្ដាបទល្មើសដែលកើតឡើងតាមបណ្ដោយព្រំដែន។ លោកបន្ថែមថាកងយោធពលខេមរភូមិន្ទបានពង្រឹងប្រៀបការពារជាតិលើគ្រប់វិស័យនៅតាមតំបន់ព្រំដែនធ្វើល្បាតជាប្រចាំដើម្បីត្រួតពិនិត្យ គ្រប់គ្រងសភាពការណ៍ និងភូមិសាស្ត្រទទួលខុសត្រូវ និងចូលរួមទប់ស្កាត់ បទល្មើសផ្សេងៗ និងសកម្មភាពឆ្លងដែនខុសច្បាប់ ព្រមទាំងបានបន្តកិច្ចសហប្រតិបត្តិការល្អជាមួយប្រទេសជិតខាងដោះស្រាយបញ្ហាផ្សេងៗដែលកើតមានដោយសន្តិវិធី និងបានអនុវត្តភារកិច្ចការពារអធិបតេយ្យ បូរណភាពទឹកដីយ៉ាងហ្មត់ចត់ ដែលធ្វើឲ្យស្ថានភាពសន្តិសុខតាមបណ្ដោយព្រំដែនមានភាពល្អប្រសើរជាងឆ្នាំ ២០១៧ ឆ្ងាយណាស់។ លោកបញ្ជាក់ថា៖ មានលក្ខណៈល្អប្រសើរជាងឆ្នាំ ២០១៧ ឆ្ងាយណាស់យើងមិនមានបញ្ហាអ្វីដែលជាការលំបាកទេ។ នៅតាមបណ្ដោយព្រំដែនយើងសហការគ្នាបានល្អណាស់។ ពេលខ្លះពេលយើងឃើញមានបាតុភាព យើងបានសហការជាមួយគ្នាដោះស្រាយដោយសន្តិវិធីតាមបណ្ដោយព្រំដែនដែលធ្វើឲ្យស្ថានភាពនៅតាមព្រំដែនទាំងអស់មានលក្ខណៈប្រក្រតីធម្មតា។ លោកបានបន្ថែមថា ពេលមានបទល្មើសគឺកងទ័ពឈរមុខគេព្យាយាមដោះស្រាយនៅនឹងកន្លែង ដើម្បីរក្សាព្រំដែនឲ្យមានស្ថិរភាព និងសន្តិភាព ហើយថាកងយោធពលខេមរភូមិន្ទដែលនៅតាមបណ្ដោយព្រំដែនបានយាមល្បាតយ៉ាងរឹងមាំ និងម៉ឺងម៉ាត់ក្នុងការការពារអធិបតេយ្យ បូរណភាពទឹកដី និងបង្កើនកិច្ចសហប្រតិបត្តិការជាមួយប្រទេសជិតខាងដើម្បីប្រែក្លាយតំបន់ព្រំដែនដែលជាតំបន់អភិវឌ្ឍន៍ និងទីផ្សារដើម្បីជួយលើកស្ទួយជីវភាពប្រជាពលរដ្ឋដែលរស់នៅតាមបណ្ដោយព្រំដែន។

## ថៃចាប់ឃាត់ខ្លួនពលករខ្មែរម្នាក់បន្ទាប់ពីសម្លាប់ពលករខ្មែរដូចគ្នា

http://mekong-post.com/ ដោយ មេគង្គ ប៉ុស្តិ៍ ចេញផ្សាយ ថ្ងៃទី 1 January, 2019

**ថៃ ៖ ពលករខ្មែរម្នាក់ត្រូវកម្លាំងសមត្ថកិច្ចថៃ ចាប់ឃាត់ខ្លួន បន្ទាប់ពីសម្លាប់ពលករខ្មែរដូចគ្នា កាលពីវេលា ម៉ោង ១១ថ្ងៃទី២៩ធ្នូឆ្នាំ២០១៨ នៅមុខអគាររបស់កម្មករស្នាក់នៅ ត្រង់ចំណុចស្ថិតក្នុងចំការអំពៅ ភូមិ ១០ឃុំវ៉ាំងយិន ស្រុកវ៉ាំងយិន ខេត្តស្រះកែវ ប្រទេសថៃ។**

បុរសសង្ស័យឈ្មោះ ច័ន្ទ អាយុ២៩ឆ្នាំ មានស្រុកកំណើតនៅឃុំ សន្តិភាពស្រុក សំពៅលូន ខេត្ត បាត់ដំបង។ បុសរងគ្រោះមានឈ្មោះ ហូ សាំ ភេទប្រុស អាយុ២៣ឆ្នាំ ជាពលករកាប់អំពៅ ដូចគ្នា ។ ជនរងគ្រោះ ត្រូវបានជនដៃដល់កាប់ស្លាប់ ខណៈកំពុងអង្គុយហូបកាហ្វេនៅខាងមុខ អគារស្នាក់ នៅ ដោយបានក្រាបដេកនៅលើតុក្នុងសភាពងងុយដេក។ ក្រោយពីធ្វើសកម្មភាពជនដៃដល់បានរត់គេចខ្លួន តែត្រូវសមត្ថកិច្ចថៃ តាមចាប់ខ្លួនបាន បញ្ជូនទៅតុលាការខេត្តស្រះកែវ ចំណែកសពជនរងគ្រោះ ត្រូវបានបញ្ជូនអោយក្រុមគ្រួសារនាំយកទៅស្រុក កំណើតវិញ ដើម្បីរៀបចំធ្វើបុណ្យនៅស្រុកកំណើត៕

# ថ្ងៃទី០៨ ខែមករា ឆ្នាំ២០១៩

## ILO៖កុមារមិនគ្រប់អាយុធ្វើការក្នុងវិស័យកាត់ដេរបានថយចុះ

https://thmeythmey.com/ 07, Jan 2019 , 11:19 pm ដោយ: ភួង វ៉ាន់ថា

កម្មករមិនទាន់គ្រប់អាយុ នៅក្នុងវិស័យកាត់ដេរ មានការធ្លាក់ចុះពី៧៤ ករណី ក្នុងឆ្នាំ២០១៣ មកត្រឹម១០ករណីនៅក្នុងឆ្នាំ២០១៨។ នេះបើយោងតាមរបាយការណ៍របស់អង្គការILO នៃគម្រោងរោងចក្រកាន់តែប្រសើរនៅកម្ពុជា ដែលបានវាយតម្លៃលើរោងចក្រចំនួន៤៦៤ ពីថ្ងៃទី១ ខែឧសភា ឆ្នាំ២០១៧ ដល់ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៨។

បើតាមរបាយការណ៍ដដែល កម្មករកុមារទាំង១០ មានអាយុក្រោម១៥ឆ្នាំ ហើយពួកគេសុទ្ធតែជាក្មេងស្រី។ ក្នុងចំណោមពួកគេ កម្មករដែលចូលទម្រង់ពលកម្មកុមារចំនួន៤ករណី បានទទួលយកកម្មវិធីដោះស្រាយដើម្បីកែលម្អរបស់ GMAC/BFC និងបានយកពួកគេទៅរៀន នៅក្នុងមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈ។ មានករណីចំនួន២បានបដិសេធមិនចូលរួមក្នុងកម្មវិធីកែលម្អរបស់ BFC ហើយត្រូវបង្ហាញក្នុងប្រព័ន្ធទិន្នន័យតម្លាភាពរបស់ BFC ថាជាករណីពលកម្មកុមារដែលពុំត្រូវបានដោះស្រាយ។ បើទោះបីជាលក្ខខណ្ឌការងារក្នុងរោងចក្រកាត់ដេរនៅកម្ពុជា កំពុងមានភាពប្រសើរឡើង ប៉ុន្តែការរំលោភសិទ្ធិនៅតែមានដូចជា ការរើសអើង, ការងារដោយបង្ខំ, សេរីភាពនៃការបង្កើតអង្គការវិជ្ជាជីវៈ-ល-។ នេះបើតាម ILO ដែលបានបន្តតម្រូវឲ្យ រោងចក្រកាត់ដេរទាំងអស់គួរកែតម្រូវ ឲ្យអនុលោមតាមច្បាប់ជាតិ និងអន្តរជាតិ។

សូមជម្រាបថា វិស័យកាត់ដេរបានបង្កើតចំណូលជាង៧០ភាគរយ នៃចំណូលនាំចេញសរុបរបស់កម្ពុជា ហើយពលរដ្ឋកម្ពុជាជាង ៦៥០, ០០០នាក់ កំពុងធ្វើការក្នុងវិស័យនេះ ដែលភាគច្រើនជាស្ត្រី។ ប្រាក់ឈ្នួលអប្បបរមាប្រចាំខែ សម្រាប់កម្មករនិយោជិតពេញសិទ្ធិ នៅតាមបណ្តារោងចក្របានកើនឡើងពី១០០ដុល្លារនៅឆ្នាំ២០១៤ ដល់ ១៧០ដុល្លារ ក្នុងឆ្នាំ២០១៨ និងបានកើនឡើងដល់ ១៨២ដុល្លារ នៅឆ្នាំ២០១៩នេះ។

សមាគមរោងចក្រកាត់ដេរនៅកម្ពុជា (GMAC) សហជីព និងអង្គការអន្តរជាតិខាងការងារ (ILO) បានរួមគ្នាអំពាវនាវដល់សហគមន៍អន្តរជាតិ បន្តការគាំទ្រលើលទ្ធភាពទីផ្សារ ការអនុគ្រោះពាណិជ្ជកម្ម ការរក្សាគម្រោងផ្តួចផ្តើមនាំចូលទំនិញ គ្រប់យ៉ាងលើកលែងតែអាវុធសម្រាប់កម្ពុជា៕

## ៣ គន្លឹះអាចជួយអ្នកធ្វើការនៅក្រៅប្រទេសមានសុវត្ថិភាពខ្ពស់

https://cammigrant.blogspot.com/ posted by MT Vlog on January 05, 2019

ចំណាកស្រុកទៅធ្វើការនៅក្រៅប្រទេសខុសច្បាប់នៅតែជាបញ្ហាប្រឈមសម្រាប់ប្រជាជនខ្មែរ ខណៈពេលដែរពលរដ្ឋខ្មែរត្រូវបានរងនូវការទៅជួញដូរ និងការកេងប្រវ័ញ្ចកម្លាំងពលកម្មពីការចំណាកស្រុកខុសច្បាប់នោះ បន្ថែមពីនោះកង្វះខាតព័ត៌មានមុនពេលសម្រេចចិត្តធ្វើចំណាកស្រុកក៏ជាផ្នែកមួយ ដែលធ្វើឲ្យពលករខ្មែរសម្រេចចិត្តមិនបានត្រឹមត្រូវ។

**ខាងក្រោមនេះគឺជាគន្លឹះដែលអាចជួយអ្នកធ្វើការចំណាកស្រុកបានដោយសុវត្ថិភាព៖**

១. លិខិតឆ្លងដែន អ្នកត្រូវប្រាកដថា អ្នកមានលិខិតឆ្លងដែន ដែរមានសុពលភាពត្រឹមត្រូវសម្រាប់ការអនុញ្ញាតឆ្លងដែនទៅក្រៅប្រទេស។ អ្នកអាចធ្វើលិខិឆ្លងដែនបានដោយខ្លួនឯង ឬតាមរយៈក្រុមហ៊ុនជ្រើសរើសពលករស្របច្បាប់ សម្រាប់តម្លៃលិខិឆ្លងដែនគឺចន្លោះពី ១០០ដុល្លា ទៅ ១៥០ដុល្លា ទៅតាមសេវាកម្មនៃលិខិតឆ្លងដែន។

២. ជ្រើសរើសក្រុមហ៊ុនជ្រើសរើសពលករដែលស្របច្បាប់មុននឹងសម្រេចចិត្តស្វែករកក្រុមហ៊ុនជ្រើសរើសពលករសម្រាប់ទៅធ្វើការនៅក្រៅប្រទេស អ្នកត្រូវដឹងថាក្រុមហ៊ុននោះមានសិទ្ធអនុញ្ញាតស្របច្បាប់ដែល ឬទេ! ដើម្បីដឹងថាក្រុមហ៊ុននោះស្របច្បាប់ អ្នកអាចចូលទៅក្នុងទំព័រហ្វេសបុករបស់ក្រសួងការងារ និងបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ ដើម្បីមើលតារាងបញ្ជីឈ្មោះក្រុមហ៊ុន ដែលចុះបញ្ជីត្រឹមត្រូវជាមួយក្រសួង។

៣. សួរយោបល់ពីអជ្ញាធរ ឬបណ្តាអង្គការនានា អ្វីដែលអ្នកគួរធ្វើដើម្បីជួយដល់ការសម្រេចចិត្តបានត្រឹមត្រូវ អ្នកអាចសុំការណែនាំ និងលេខទំនាក់ទំនងពេលមានអាសន្នពីអជ្ញាធរមូលដ្ឋាន ឬបណ្តាអង្គការដូចជា គម្រោងអ៊ីស្សារ៉ា ទូរស័ព្ទលេខ +66 86 968 6085, អ្នកក៏អាចធ្វើជាសំណួរមកកាន់ហ្វេសបុកផេក ព័ត៌មានពលករខ្មែរ ផងដែរ។

# ថ្ងៃទី០៩ ខែមករា ឆ្នាំ២០១៩

## ពលករបរទេសបំរើការងារនៅកម្ពុជាត្រូវបានសង្ស័យថា មានលើសពីកូតាកំណត់១០%

http://km.rfi.fr/cambodia/ ដោយ សឿង ភារៈ 08/01/2019

លោក ខៀវ សុភ័គ អ្នកនាំពាក្យក្រសួងមហាផ្ទៃ កាលពីថ្ងៃម្សិលមិញ បានលើកឡើងដោយផ្អែកលើច្បាប់ការងារថា នៅការដ្ឋានសំណង់នីមួយៗ មិនអាចឲ្យមានជនបរទេសធ្វើការលើសពី១០ភាគរយនៃចំនួនអ្នកធ្វើការក្នុងការដ្ឋាននោះទេ។ ជាការលើកឡើងខណៈសហជីពសំណង់មើលឃើញថាតាមការដ្ឋានសំណង់ខ្លះមានជនបរទេសធ្វើការច្រើនជាងជនជាតិខ្មែរ។ តាមរយៈបទសម្ភាសរបស់វិទ្យុបារាំងអន្តរជាតិ កាលពីថ្ងៃទី០៧ ខែមករា លោក ខៀវ សុភ័គ អ្នកនាំពាក្យក្រសួងមហាផ្ទៃបានថ្លែងថា បច្ចុប្បន្ននេះក្រសួងមហាផ្ទៃកំពុងតែត្រួតពិនិត្យលើការដ្ឋានសំណង់ផ្សេងៗទៀតដើម្បីពិនិត្យពីភាពត្រឹមត្រូវតាមច្បាប់ការងារ។ លោកបានលើកឡើងថា នៅតាមការដ្ឋាននីមួយៗ មិនឲ្យមានជនបរទេសធ្វើកិច្ចការងារលើសពី១០ភាគរយទេ ដូច្នេះក្នុងចំណោមមនុស្ស១០០នាក់ បើមានជនបរទេសលើសពី១០នាក់ នោះគឺខុសនឹងច្បាប់ហើយ។ លោកបន្ថែមថារាល់ជនបរទេស ដែលធ្វើការងារនៅក្នុងប្រទេសកម្ពុជាត្រូវតែបង់ពន្ធប្រាក់ចំណូលជូនរដ្ឋ។

អ្នកនាំពាក្យក្រសួងការងារ លោក ហេង សួរ បានបញ្ជាក់ប្រាប់វិទ្យុបារាំងអន្តរជាតិថា ច្បាប់របស់កម្ពុជាបានចែងពីកូតាកំណត់ចំនួនជនបរទេសមិនឲ្យលើសពី១០ភាគរយក្នុងការដ្ឋានមួយ ប៉ុន្តែច្បាប់ដដែលនេះក៏បានអនុញ្ញាតឲ្យម្ចាស់គម្រោង ឬអ្នកវិនិយោគ អាចស្នើសុំបន្ថែមចំនួនជនបរទេស ប្រសិនបើមានករណីខ្វះកម្លាំងពលកម្មនៅក្នុងស្រុក ដើម្បីបំពេញការងារនៅក្នុងការដ្ឋានរបស់ខ្លួន។

ដោយឡែក លោក សុខ គីន ប្រធានសហព័ន្ធសហជីពកម្មករសំណង់ និងព្រៃឈើកម្ពុជា បានអះអាងថា បច្ចុប្បន្ននេះ ដោយសារមានលំហូរវិនិយោគរបស់ចិនមកកម្ពុជាច្រើន ធ្វើឲ្យចំនួនជនបរទេស ដែលធ្វើការនៅតាមការដ្ឋានសំណង់មានលើសពី១០ភាគរយនៃកូតា ដែលបានកំណត់ដោយច្បាប់។ លោកបន្តថាកន្លែងការដ្ឋានខ្លះគឺមិនមានជនជាតិខ្មែរតែម្តង។ លោក សុខ គីន បញ្ជាក់ថា ជនបរទេសនៅតាមការដ្ឋានច្រើនជាងជនជាតិខ្មែរជាម្ចាស់ស្រុក នោះនឹងបង្កឲ្យមានបញ្ហាមួយចំនួនកើតឡើងដូចជា កើតមាននូវការរើសអើងតាមរយៈប្រាក់ឈ្នួល ព្រោះជនបរទេសមានប្រាក់ឈ្នួលច្រើនជាងជនជាតិខ្មែរ, ពលរដ្ឋខ្មែរនឹងបាត់បង់ការងារធ្វើ ឬទៅធ្វើការងារចំណាកស្រុកនៅប្រទេសជិតខាងជាដើម៕

## លោក អ៊ុំ រាត្រី ៖ ប័ណ្ណព្រំដែនបើចង់ធ្វើនៅរដ្ឋបាលខេត្ត

http://ppt-news.net/ ចេញផ្សាយ ថ្ងៃទី 03/01/2019

ខេត្តបន្ទាយមានជ័យ ៖ លោក អ៊ុំ រាត្រី អភិបាលរងខេត្តបានថ្លែងក្នុងពិធីសំណេះសំណាលជាមួយប្រជាពលរដ្ឋដែលមកធ្វើប័ណ្ណព្រំដែននៅព្រឹក ថ្ងៃទី២ ខែមករា ឆ្នាំ២០១៩នៅសាលាខេត្តច្រកចេញចូលតែមួយថាប័ណ្ណព្រំដែនបើចង់ធ្វើនៅរដ្ឋបាលខេត្តច្រកចេញចូលតែមួយប្រយ័ត្នចាញ់បោកគេ ឯសំបុត្រឆ្លងដែនឲ្យនគរបាលអន្តោប្រវេសន៍អ្នកធ្វើតែតម្រូវឲ្យយកកំរៃតែ១០០រៀលតែប៉ុណ្ណោះ។ លោក អ៊ុំ រាត្រី បានបញ្ជាក់ឲ្យដឹងទៀតថាបងប្អូនប្រជាពលរដ្ឋដែលមានបំណងធ្វើប័ណ្ណព្រំដែន(Border Pass) សូមភ្ជាប់មកជាមួយនូវឯកសាររួមមានច្បាប់ថតចម្លងតាមច្បាប់ដើម ១អត្តសញ្ញាណប័ណ្ណថតចម្លង១ ច្បាប់ ២សេចក្តីចម្លងសំបុត្រកំណើត ឬសំបុត្របញ្ជាក់កំណើត ចំនួន១ច្បាប់៣សេចក្តីចម្លងសៀវភៅគ្រួសារ ឬសៀវភៅស្នាក់នៅ ចំនួន១ច្បាប់៤រូបថត ៤X៦ ចំនួន ២សន្លឹករូបថតកូនភ្ជាប់មកជាមួយ៤X៦ ចំនួន ២សន្លឹក ករណីមានកូនរួមដំណើរជាមួយហើយបង់សេវាចូលរដ្ឋចំនួន២០.០០០រៀលក្នុងរយៈពេល៥ថ្ងៃទើបអាចមកយកធ្វើប័ណ្ណព្រំដែន(Border Pass) បាន។ លោក អ៊ុំ រាត្រីបានបញ្ជាក់ឲ្យដឹងទៀតថា បើគិតរយៈពេល១ឆ្នាំនេះ ការធ្វើប័ណ្ណនេះមានបរិមាណច្រើនមានទាំងខេត្តឆ្ងាយៗក៏អាចធ្វើបានដែរឲ្យតែមានសៀវភៅមកស្នាក់

នៅក្នុងខេត្តបន្ទាយមានជ័យដែរ។ហើយចំណែកប័ណ្ណនេះត្រូវចំណាយពេល៥ថ្ងៃទើបធ្វើរួចលទ្ធផលនេះមិនទាន់ឆ្លើយតបតាមសំណូមនិងផែនការដាក់ចុះនៅឡើយនោះទេ។ លោក អ៊ុំ រាត្រីបានបញ្ជាក់ទៀតថា ក្នុងការត្រួតពិនិត្យការងារធ្វើប័ណ្ណព្រំដែននេះជាមួយមន្ត្រីក្រសួងមហាផ្ទៃ មន្ត្រីអាជ្ញាធរ សមត្ថកិច្ចនគរបាលអន្តោប្រវេសន៍ មន្ត្រីនគរបាលចំណុះស្នងការដ្ឋានខេត្តថា លទ្ធផលនៃដំណើរការធ្វើប័ណ្ណព្រំដែនឬ Border Pass នៅខេត្តបន្ទាយមានជ័យនេះ បានល្អប្រសើរហើយចំណែកបញ្ហាប្រឈម មានតែករណីបងប្អូនប្រជាពលរដ្ឋមកធ្វើប័ណ្ណនៅមិនទាន់យល់ច្បាស់ពីនិតិវិធីដូចជាខ្វះឬមិនបំពេញបានតាមការណែនាំរបស់ក្រសួងមហាផ្ទៃដូចជា ឯកសារលិខិតចម្លងសំបុត្រកំណើត អត្តសញ្ញាណប័ណ្ណនិងសៀវភៅស្នាក់នៅត្រូវតែថតចម្លងឲ្យបានត្រឹមត្រូវតាមច្បាប់ដើម និងបោះត្រាក្រហមលើសេចក្តីថតចម្លង។ល។

ប៉ុន្តែ នគរបាលអន្តោប្រវេសន៍ប៉ុស្តិ៍ច្រកទ្វារអន្តរជាតិប៉ោយប៉ែតនេះទទួលសិទ្ធិពីរដ្ឋបាលខេត្តក្នុងការបោះពុម្ពសំបុត្រឆ្លងព្រំដែនចូលផ្សាររោងក្លឿ ដោយអនុញ្ញាតិឲ្យយកលុយតម្លៃ១០០រៀលឬ១បាតក្នុងសំបុត្រ១សន្លឹកសម្រាប់ទូទាត់ថ្លៃបោះពុម្ពប៉ុន្តែតម្លៃសំបុត្រថ្លៃ១.០០០រៀលឬ១០បាត នៅតែគិតថ្លៃពីពលរដ្ឋដដែល។នៅខាងកម្ពុជាតាមច្រកទ្វារព្រំដែនអន្តរជាតិ មាននគរបាលអន្តោប្រវេសន៍ តែ តាមច្រកទ្វារតំបន់ មានតែនគរបាលការពារព្រំដែនគោក គ្មាននគរបាលអន្តោប្រវេសន៍ឡើយប៉ុន្តែខាងថៃវិញគេមាន។ករណីនេះ មន្ត្រីរដ្ឋបាលខេត្តនិយាយថា ខេត្តនឹងស្នើទៅក្រសួងមហាផ្ទៃ ដើម្បីបានចាត់តាំងមន្ត្រីអន្តោប្រវេសន៍ទៅប្រចាំតាមច្រកតំបន់ព្រំដែននិងច្រកទ្វារភាគីដើម្បីត្រួតពិនិត្យប័ណ្ណព្រំដែនដូចខាងភាគីថៃដែរនេះជាការសម្រួលដល់ពលរដ្ឋអាចប្រើប័ណ្ណព្រំដែនឆ្លងដែនបានដែរ។ ប័ណ្ណព្រំដែន Border Passនេះ ឧទាហរណ៍សម្រាប់ពលរដ្ឋនៅក្នុងខេត្តបន្ទាយមានជ័យជាប់តំបន់ព្រំដែន ត្រូវបានអាជ្ញាធរថៃ អនុញ្ញាតិឲ្យពលរដ្ឋកម្ពុជានៅខេត្តជាប់ព្រំដែនអាចឆ្លងចេញចូលទៅក្នុងជម្រៅ២ខេត្តជាប់គ្នា គឺខេត្តស្រះកែវនិងខេត្តប្រាជីនបុរីហើយមានរយៈពេលស្នាក់នៅ៧ថ្ងៃ៕

## សមត្ថកិច្ចចុះបង្ក្រាបទីតាំងហាងម៉ាស្សា សាឃីហ៊ោបាតដៃសម្រួលសរសៃបែបបុរាណខ្មែរ ឃាត់ខ្លួនប្រុសស្រី ៨នាក់

https://chsknews.com/ 2019/01/09/ មាណព បុល

ភ្នំពេញ ៖ កាលពីវេលាម៉ោង៨យប់ថ្ងៃទី៨ ខែមករា ឆ្នាំ២០១៩ មានករណី បង្ក្រាបទីតាំងហាងម៉ាស្សាមួយកន្លែង ឃាត់ខ្លួនប្រុសស្រី ៨នាក់ នៅចំណុចផ្ទះម៉ាស្សាសាឃីហ៊ោបាតដៃសម្រួលសរសៃបែបបុរាណខ្មែរ តាមបណ្តោយផ្លូវលេខ១៣៨ កែងផ្លូវ២៣៣ ស្ថិតក្នុងសង្កាត់ផ្សារដេប៉ូទី២ ខណ្ឌទួលគោក។ ម្ចាស់ទីតាំងមានឈ្មោះ សុខ រតនា ភេទប្រុសអាយុ២៧ឆ្នាំ និងឈ្មោះដួង ស្រីពៅ ភេទស្រីអាយុ២៦ឆ្នាំ ស្នាក់នៅកន្លែងកើតហេតុ។ មន្ទីរប្រឆាំងការជួញដូរមនុស្សនិងអនិតិជន បានសហការជាមួយសមត្ថកិច្ចមូលដ្ឋានបានចុះបង្ក្រាបទីតាំងហាងម៉ាស្សាមួយកន្លែងដែលស្លាកឃីហ៊ោឈ្មោះ បាតដៃសម្រួលសរសៃបែបបុរាណខ្មែរ ដែលបានបង្កប់សេវាកម្មផ្លូវភេទនឹងឃាត់ខ្លួនមនុស្សប្រុសស្រីចំនួន៨នាក់។

ប្រតិបត្តិការនេះមានការចូលរួមពីអនុប្រធាននាយកដ្ឋានការជួញដូមនុស្ស និងកម្លាំងនគរបាលមូលដ្ឋាន។ ដោយបានឃាត់ខ្លួននារីជាជនរងគ្រោះចំនួន៥នាក់ ម្ចាស់ទីតាំងប្តីប្រពន្ធ២នាក់រួមទាំងបុរសជាភ្ញៀវ១នាក់។ ឃាត់ខ្លួននារីជាជនរងគ្រោះត្រូវបាននាំយកទៅមន្ទីរប្រឆាំងការជួញដូរមនុស្សដើម្បីអប់រំ។ ជនសង្ស័យត្រូវបានកសាងសំណុំរឿងបញ្ជូនទៅតុលាការចាត់កាបន្ត ចំពោះទីតាំងត្រូវបានសមត្ថកិច្ចបិទទ្វាបណ្តោះអាសន្ន៕

# ក្រសួងមហាផ្ទៃ បង្កើតក្រុមការងារពិភាក្សាពីដំណើរការការងារនៅតាមព្រំដែន

https://www.postkhmer.com/ ម៉ិច ដារ៉ា | Publication date 09 January 2019 | 13:58 ICT

**ភ្នំពេញៈ** ក្រសួងមហាផ្ទៃកាលពីម្សិលមិញបានសម្រេចបង្កើតក្រុមការងារមួយ ដើម្បីសិក្សានិងពិភាក្សាជំរុញកិច្ចដំណើរការបើកច្រកទ្វារព្រំដែនដែលបានព្រមព្រៀងរវាងរដ្ឋាភិបាលកម្ពុជា និងបណ្តាប្រទេសជាប់ព្រំដែនដើម្បីស្វែងរកដំណោះស្រាយសមស្របទាក់ទងនឹងបញ្ហាណាមួយនៅតាមព្រំដែន។ សេចក្តីសម្រេចនេះ ត្រូវបានចុះហត្ថលេខាដោយលោកឧបនាយករដ្ឋមន្ត្រី ស ខេង រដ្ឋមន្ត្រី ក្រសួងមហាផ្ទៃកាលពីថ្ងៃទី ៨ ខែមករា ឆ្នាំ ២០១៩ ដោយមានសមាសភាព ១០ រូប ក្នុងនោះ មានលោក សុខ ផល រដ្ឋលេខាធិការក្រសួងមហាផ្ទៃជាប្រធានលោក ឡាំ ជា រដ្ឋលេខាធិការក្រសួងមហាផ្ទៃ ជាអនុប្រធាន និង ៨ រូបទៀតជាសមាជិក។ បើតាមសេចក្តីសម្រេច ការបង្កើតក្រុមការងារនេះឡើងគឺដើម្បីសិក្សា និងពិភាក្សា ជំរុញកិច្ចដំណើរការបើកច្រកទ្វារព្រំដែនដែលបានព្រមព្រៀងរវាងរដ្ឋាភិបាលកម្ពុជា និងបណ្តាប្រទេសជាប់ព្រំដែន និងពិភាក្សាជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ អំពីកិច្ចដំណើរការក្នុងការបើកច្រកទ្វារព្រំដែនដែលបានសម្រេច។ សេចក្តីសម្រេចដដែលបានឲ្យដឹងថា៖ «ក្រុមការងារនេះមានភារកិច្ចដូចខាងក្រោម៖ ចុះពិនិត្យ និងសិក្សាពីស្ថានភាពជាក់ស្តែង នៃច្រកទ្វារព្រំដែននីមួយៗដែលបានព្រមព្រៀងរវាងរាជរដ្ឋាភិបាលកម្ពុជា និងបណ្តាប្រទេសជាប់ព្រំដែនដើម្បីស្វែងរកដំណោះស្រាយសមស្រប។ សម្របសម្រួលពិភាក្សា និងចរចាជាមួយភាគីនៃបណ្តាប្រទេសជាប់ព្រំដែន ដើម្បីជំរុញកិច្ចដំណើរការបើកច្រកទ្វារព្រំដែនដែលបានព្រមព្រៀងរវាងកម្ពុជានិងបណ្តាប្រទេសជាប់ព្រំដែន»។ សេចក្តីសម្រេចបន្ថែមថា ក្រុមការងារនេះមានភារកិច្ចធ្វើរបាយការណ៍អំពីលទ្ធផល ការងារ និងសុំយោបល់ថ្នាក់ដឹកនាំ ផ្ទាល់ពីរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងបំពេញភារកិច្ចផ្សេងៗទៀតតាមការចាំបាច់ហើយក្រុមការងារនេះមានសិទ្ធិប្រើប្រាស់មន្ត្រីក្រោមឱវាទរបស់ខ្លួនដើម្បីជួយការងារតាមតម្រូវការចាំបាច់។

លោក សុខ ផល រដ្ឋលេខាធិការក្រសួងមហាផ្ទៃដែលជាប្រធានក្រុមការងារនេះបានថ្លែងប្រាប់កាសែតភ្នំពេញប៉ុស្តិ៍កាលពីម្សិលថា ក្រុមការងារនេះមានភារកិច្ចសិក្សា ពិភាក្សា និងត្រួតពិនិត្យរាល់ការងារទាក់ទងនឹងច្រកទ្វារព្រំដែនថ្មីៗ នៅតាមបណ្តាព្រំដែនដូចជាព្រំដែនប្រទេសថៃ ប្រទេសឡាវ និងប្រទេសវៀតណាម ហើយក្រុមការងារនេះធ្វើការសហការជាមួយនឹងបណ្តាប្រទេសជាប់ព្រំដែនទាំងនោះ ដើម្បីសិក្សាពីលទ្ធភាព និងបញ្ហាផ្សេងក្នុងការកសាងច្រកព្រំដែនថ្មី។ លោកបានបញ្ជាក់ថា៖ «ខ្ញុំមានគម្រោងថា នៅអាទិត្យទី ៣ ឬទី ៤ នៃខែនេះយើងនឹងប្រជុំគណៈកម្មការក្រុមការងាររៀបចំផែនការ ដើម្បីលើកទិសដៅដើម្បីថា យើងនឹងធ្វើការងារអ្វីខ្លះ»។ លោកបន្ថែមថា ក្រុមការងារនេះមិនមានភារកិច្ចពាក់ព័ន្ធនឹងបិទច្រករបៀងនានានៅតាមបណ្តាព្រំដែន ដើម្បីទប់ស្កាត់ ការនាំចូលទំនិញគេចពន្ធ និងទប់ស្កាត់ការនាំពលករទៅធ្វើការនៅក្រៅប្រទេសដោយខុសច្បាប់នោះទេ។ យ៉ាងណាក្តី ការបង្កើតក្រុមការងារនេះធ្វើឡើងបន្ទាប់ពីលោករដ្ឋមន្ត្រីក្រសួងមហាផ្ទៃ បានបង្គាប់កាលពីថ្មីៗនេះឱ្យអាជ្ញាធរបិទច្រករបៀងនានានៅតាមបណ្តាព្រំដែនដើម្បីទប់ស្កាត់ការនាំចូលទំនិញគេចពន្ធ និងទប់ស្កាត់ការនាំពលករទៅធ្វើការនៅក្រៅប្រទេសដោយខុសច្បាប់។ កាលពីថ្ងៃ ២ មករា ថ្មីៗនេះ នាយឧត្តមសេនីយ៍ ឈុំ សុជាតិ អនុរដ្ឋលេខាធិការ និងជាអ្នកនាំពាក្យក្រសួងការពារជាតិបានប្រាប់ភ្នំពេញប៉ុស្តិ៍ថា ក្នុងឆ្នាំ ២០១៨ កន្លងទៅ កងទ័ពជើងគោកបានត្រួតពិនិត្យទប់ស្កាត់ និងបង្ក្រាបបទល្មើសផ្សេងៗសរុបបាន ៥១៩៣ ករណីនៅតាមខ្សែបន្ទាត់ព្រំដែនជាមួយប្រទេសជាប់កម្ពុជា។ លោកក៏បានប្រៀបធៀបស្ថានភាពសន្តិសុខនៅតាមព្រំដែនក្នុងឆ្នាំ ២០១៨ ថា មានភាពល្អប្រសើរជាងឆ្នាំ ២០១៧៕ Contact author: ម៉ិច ដារ៉ា

## ពលករពលករខ្មែរខុសច្បាប់ចំនួន០៧នាក់ត្រូវកម្លាំងអាជ្ញាធរអន្តោប្រវេសន៍ខេត្តឈុនបុរីធ្វើការឃាត់ខ្លួន

https://www.facebook.com/CambodiaLabour/ 08-01-2019

ពលករពលករខ្មែរខុសច្បាប់ចំនួន០៧នាក់ត្រូវកម្លាំងអាជ្ញាធរអន្តោប្រវេសន៍ខេត្តឈុនបុរីធ្វើការឃាត់ខ្លួន ហេតុការណ៍នេះបានកើតឡើងកាលពីវេលាម៉ោង០៦:៣០នាទីព្រឹក ថ្ងៃអង្គារ ទី០៨ ខែមករា ឆ្នាំ២០១៩ នៅម្តុំបន្ទប់ជួលមួយកន្លែងស្ថិតក្នុងសង្កាត់ប៉រីន ស្រុកស៊ីរាឆា ខេត្តឈុនបុរី ប្រទេសថៃ។ យោងតាមរបាយការណ៍របស់អាជ្ញាធរថៃបានអោយដឹងថា ពលកពលករខ្មែរទាំង០៧នាក់ គ្មានឯកសារស្នាក់នៅក្នុងប្រទេសថៃដោយស្របច្បាប់នោះទេ បច្ចុបច្ចុប្បន្នពលករខ្មែរទាំង០៧នាក់ត្រូវអាជ្ញាធរថៃបញ្ជូនទៅកាន់អធិការដ្ឋាន តម្រួតអន្តោប្រវេសន៍ស្រុកស៊ីរាឆា ដើម្បីចាត់វិធានការតាមផ្លូវច្បាប់។

## គេហទំព័រកម្លាំងពលកម្ម អំពីជួញដូរមនុស្ស មានទោសធ្ងន់

https://www.facebook.com/CambodiaLabour/ 08-01-2019

-បុគ្គលដែលប្រព្រឹត្តិបទល្មើសជួញដូរមនុស្ស ត្រូវមត្រូវមានទោសជាប់ពន្ធនាគារចាប់ពី០៤ឆ្នាំ ដល់១២ឆ្នាំ ពិន័យជាប្រាក់ពី(៤០០,០០០៛) ដល់(១,២០០,០០០៛)។

-ប្រព្រឹត្តិបទល្មើសលើអនីតិជនអាយុក្រោម ១៥ឆ្នាំ ឬបុគ្គលមានរាងកាយសម្បទាពិការ និងបុគ្គលមានសតិសម្បជញ្ញៈមិនគ្រប់១០ ត្រូវមានទោសជាប់ពន្ធនាគារចាប់ពី ០៨ឆ្នាំ-ដល់២០ឆ្នាំ និងពិន័យជាប្រាក់ពី(៨០០,០០០៛)-(២,០០០,០០០៛)។

-ប្រព្រឹត្តិបទល្មើសលើអនីតិជនអាយុលើស ១៥ឆ្នាំ ក្រោម ១៨ឆ្នាំ ត្រូវមានទោសជាប់ពន្ធនាគារពី៦ឆ្នាំ-១៥ឆ្នាំ ពិន័យជាប្រាក់ពី(៦០០,០០០៛)- ដល់(១,៥០០,០០០៛)។

# ថ្ងៃទី១០ ខែមករា ឆ្នាំ២០១៩

## ឯកឧត្តម អ៊ិត សំហេង៖ គិតមកដល់ពេលនេះ កម្ពុជាមានកម្មសិក្សាការីចេញទៅធ្វើការនៅជប៉ុន មានចំនួន ប្រមាណជាង០៩ពាន់នាក់

http://www.mlvt.gov.kh/ Thursday, 10 January 2019 10:49

ទីស្តីការក្រសួង៖ ក្នុងជំនួបពិភាក្សាការងារ រវាងលោក មីគី វ៉ាត់ណាបេ (Miki Watanabe) ប្រធានគណៈកម្មាធិការអេចិន្ត្រៃយ៍កិច្ចការបរទេស និងការពារជាតិជប៉ុន នាព្រឹកថ្ងៃទី១០ ខែមករា ឆ្នាំ២០១៩ នៅទីស្តីការក្រសួង ឯកឧត្តមបណ្ឌិត អ៊ិត សំហេង រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានមានប្រសាសន៍ថា នៅពេលខាងមុខនឹងមានក្រុមហ៊ុនជប៉ុនបើកជាបន្តបន្ទាប់ដើម្បី បណ្តុះបណ្តាលនិងងាយស្រួលបញ្ជូនកម្មសិក្សាការីពីកម្ពុជាទៅជប៉ុន ខណៈដែលរដ្ឋាភិបាលជប៉ុនបានកែប្រែច្បាប់ថ្មី។

ឯកឧត្តមរដ្ឋមន្ត្រីបានបញ្ជាក់ថា ក្រុមហ៊ុនខាងលើ គឺជាក្រុមហ៊ុនចម្រុះខាងផ្នែកឧស្សាហកម្ម និងផ្នែកសេវា បច្ចុប្បន្នក្រុមហ៊ុននេះបានគ្រប់គ្រងបុគ្គលិកប្រមាណ០២ម៉ឺននាក់នៅជប៉ុន ដែលត្រូវការកម្លាំងបន្ថែមទៀត។ ឯកឧត្តមបន្តថា ដើម្បីអនុវត្តន៍នូវគម្រោងថ្មីនេះបាន នាពេលខាងមុខរដ្ឋាភិបាលប្រទេសទាំងពីរ កម្ពុជា-ជប៉ុន ពិសេសក្រសួងការងារកំពុងរៀបចំឲ្យមានចុះកិច្ចព្រមព្រៀងសហប្រតិបត្តិការជាមួយក្រសួងពាក់ព័ន្ធរបស់ប្រទេសជប៉ុន ដើម្បីអនុវត្តន៍នូវប្រព័ន្ធថ្មី និងច្បាប់ថ្មីរបស់ភាគីជប៉ុន។ ជប៉ុនបានចាប់ផ្តើមរៀបចំបង្កើតឱ្យមានគម្រោងថ្មី សម្រាប់បង្កើនលំហូរនៃកម្លាំងពលកម្មពីប្រទេសផ្សេងៗ និងសម្រាប់អនុវត្តនូវកំឡុងខែមេសា ឆ្នាំ២០១៩ខាងមុខនេះ ដើម្បីដោះស្រាយបញ្ហាកង្វះកម្លាំងពលកម្មជំនាញនៅប្រទេសជប៉ុន។

ជាមួយគ្នានេះ ជប៉ុនបាននឹងកំពុងរៀបចំឱ្យមានសេចក្តីព្រាងនិងកិច្ចព្រមព្រៀងសហប្រតិបត្តិការជាមួយបណ្តាប្រទេសបញ្ជូនទាំងអស់ ដែលបានអនុញ្ញាតឱ្យបញ្ចូលទាំងកម្មសិក្សាការីបច្ចេកទេស និងអ្នកធ្វើការជំនាញបច្ចេកទេស ទៅប្រទេសជប៉ុន។ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈបានសហការជាមួយមន្ត្រីជំនាញនៃប្រទេសជប៉ុន ដើម្បីពិនិត្យ និងរៀបចំឱ្យមានកិច្ចព្រមព្រៀងសហប្រតិបត្តិការជាមួយគ្នា ក្នុងគោលបំណងដើម្បីបង្កើនទីផ្សារការងារ និងឱកាសការងារដល់ប្រជាជនកម្ពុជា។ សូមបញ្ជាក់ថា នៅក្នុងចំណោមជាដៃគូប្រទេសជប៉ុនដែលបញ្ជូនពលករទៅធ្វើការនៅទីនោះមានចំនួន១៥ប្រទេស ហើយចំនួនដែលបានបញ្ជូនទៅពីលេខ១ រហូតដល់១៥ កម្ពុជាឈរលើលេខរៀងទី៧៕

## ដេញប្រពន្ធឲ្យទៅឆ្ងាយ នៅបង្រៀនក្មួយស្រីរបៀបរួមសិចខាយលក់ខ្លួនឲ្យឧកញ៉ា ពេលចំណង់ដល់កំពូលរំលោភបានសម្រេច

http://nokorwatnews.com/ 10-01-2019

ខេត្តកណ្តាលៈ ជារឿងអសិលធម៌បំផុត ដែលបុរសល្មោភកាមម្នាក់ប្រព្រឹត្តអំពើអនាចារដោយដេញប្រពន្ធឲ្យទៅផ្ទះមុន ឯខ្លួននៅបង្រៀនក្មួយស្រីអាយុ១៧ឆ្នាំរបៀបរួមសិចដើម្បីមានបទពិសោធងាយស្រួលលក់ខ្លួនឲ្យឧកញ៉ាឬអ្នកមាន ហើយនៅពេលមានចំណង់ដល់កំពូលទ្រាំលែងបានរំលោភសេពសន្ថវៈក្មួយស្រីខ្លួនឯងដល់គោលដៅ។ ហេតុការណ៍នេះកើតឡើងកាលពីវេលាម៉ោង១១និង៣០នាទីយប់ថ្ងៃ ពុធ ៣ កើត ខែបុស្ស ឆ្នាំ ច សំរឹទ្ធិស័ក ព.ស.២៥៦២ ត្រូវនឹង ថ្ងៃទី៩ ខែមករា ឆ្នាំ២០១៨ ស្ថិតក្នុងភូមិលេខ២ ឃុំស្វាយរលំ ស្រុកស្អាង ខេត្តកណ្តាល ។

មន្ត្រីនគរបាលស្រុកស្អាងបានឲ្យដឹងថា បុរសសង្ស័យមានឈ្មោះ ប៉ុក អាមីឡា ភេទប្រុស អាយុ៣៨ឆ្នាំ មុខរបរបើកបររថយន្ត មានទីលំនៅ ភូមិស្រុកកៀនស្វាយ ខេត្តកណ្តាល។ រីឯយុវនារីរងគ្រោះឈ្មោះ ប ណ.រ អាយុ១៧ឆ្នាំ ជនជាតិខ្មែរ មុខរបរកសិករ មានទីលំនៅភូមិ លេខ២ ឃុំស្វាយរលំ ស្រុកស្អាង ខេត្តកណ្តាល ជាកូនអ្នកក្រីក្រ ។ ប្រភពដដែលបន្តថា នៅមុនពេលកើតហេតុជនសង្ស័យនិងប្រពន្ធមកលេងបងថ្លៃស្រី ត្រូវជាម្តាយក្មេងស្រីរងគ្រោះរស់នៅភូមិខាងលើ។លុះនៅវេលាម៉ោង១១និង៣០នាទីយប់ថ្ងៃទី៩ ខែមករា ឆ្នាំ២០១៩ ជនសង្ស័យ និងប្រពន្ធឈ្មោះ រ៉ាយ ចន្ធូ អាយុ៣៥ឆ្នាំ បានបបួលយុវនារីរងគ្រោះ(ត្រូវជាក្មួយ)ជិះម៉ូតូចេញទៅក្រៅដើម្បីទិញអីហូបនៅផ្សារកែងកាច់ជ្រុងក្រុងតាខ្មៅ។

លុះជិះមកដល់ផ្លូវលំទួលអន្សែ ស្រាប់តែជនសង្ស័យបានឈប់ម៉ូតូរបស់ខ្លួន ហើយប្រើមធ្យោបាយដេញប្រពន្ធឈ្មោះ រ៉ាយ ចន្ធូ ដើរចេញឲ្យឆ្ងាយពីខ្លួន ដោយទុកតែយុវនារីរងគ្រោះ (ត្រូវជាក្មួយ)នៅជាជិតខ្លួនប៉ុណ្ណោះ។ បន្ទាប់ពីប្រពន្ធដើរចាកចេញទៅឆ្ងាយបន្តិច ស្រាប់តែជនសង្ស័យបានចាប់ក្មួយស្រីខ្លួនឯងរំលោភសេពសន្ថវៈរហូតបានសម្រេច រួចប្រាប់នារីរងគ្រោះថាកុំឲ្យប្រាប់រឿងនេះឲ្យអ្នកណាដឹងឲ្យសោះ ។ បន្ទាប់ពីធ្វើសកម្មភាពរួច ជនសង្ស័យ និងប្រពន្ធរួមជាមួយយុវនារីរងគ្រោះបានជិះម៉ូតូត្រឡប់មកផ្ទះវិញ ខណៈមកដល់ផ្ទះរបស់ខ្លួនយុវនារីរងគ្រោះ បានរៀបរាប់ដំណើររឿងហេតុប្រាប់ម្តាយរបស់ខ្លួន ក្រោយពីម្តាយយុវនារីរងគ្រោះបានដឹងពីរឿងហេតុរួច ភ្លាមនោះក៏ទៅដាក់ពាក្យបណ្តឹងនៅនគរបាលប៉ុស្តិ៍រដ្ឋបាលស្វាយរលំដើម្បីធ្វើការអន្តរាគមន៍ចាប់ខ្លួនជនសង្ស័យតែម្តង ។ ក្រោយពីសមត្ថកិច្ចនគរបាលទទួលបានពាក្យបណ្តឹងពីម្តាយយុវនារីរងគ្រោះរួច ភ្លាមនោះក៏ចុះទៅធ្វើការឃាត់ខ្លួនជនសង្ស័យខាងលើ យកមកប៉ុស្តិ៍នគរបាលរដ្ឋបាលស្វាយរលំដើម្បីកសាងសំណុំរឿងបញ្ជូនទៅកាន់អធិការដ្ឋាននគរបាលស្រុក ចាត់ការតាមនីតិវិធីច្បាប់ ។

នៅចំពោះមុខសមត្ថកិច្ច ជនសង្ស័យរូបនេះបានសារភាពថា បានជាខ្លួនរំលោភក្មួយស្រីបាន សម្រេចបែបនេះ ដោយសារខ្លួនមានបំណងល្បួងលួងលោមលក់ក្មួយស្រីឲ្យឧកញ៉ា និងអ្នកមានណាម្នាក់ ដើម្បីយកលុយមកផ្គត់ផ្គង់គ្រួសារ ព្រោះម្តាយនាងក្រីក្រណាស់។ ដោយយល់ ឃើញថាក្មួយស្រីនៅវ័យក្មេងខ្ចីពេកមិនយល់រឿងស្នេហាលើគ្រែ ទើបខ្លួនប្រើល្បិចដេញប្រពន្ធឲ្យដើរទៅឆ្ងាយរួចខ្លួននៅបង្រៀនរបៀបរួមសិច ដោយវិធីបបោសអង្អែល លិឍ គ្រប់

កន្សៀតកៀនកោះ និងក្បាច់ពិសេសៗដល់នាង ងាយស្រួលពេលរួមភេទជាមួយឧកញ៉ា ឬអ្នកមានទាំងនោះគេបាក់ចិត្ត ស្ពងអារម្មណ៍ផ្តល់លុយកាក់ដល់នាងបានច្រើន។ ប៉ុន្តែខណៈដែលកំពុងបង្រៀនវិធីរួមសិចនោះខ្លួនមានកំសួលតណ្ហា ពុះកញ្ជ្រោលខ្លាំងឡើងធ្វើឲ្យ ទ្រាំលែងបានក៏ចាប់រំលោភក្មួយស្រីបានសម្រេចតែម្តងទៅ។

យ៉ាងណាក្នុងករណីនេះសមត្ថកិច្ចជំនាញកំពុងកសាងសំណុំរឿងដាក់បន្ទុកជនសង្ស័យពីរ បទល្មើស គឺ១-ចាប់រំលោភសេពសន្ថវៈ និង២- អំពើជួញដូរមនុស្ស ៕ ស្អាងជ័យ

## អ្នកសុំទានតាមផ្លូវ ក្នុងខេត្តទាំង៦របស់ថៃ ត្រូវផាកពិន័យ១ម៉ឺនបាត និងត្រូវជាប់គុក មួយខែ បើដឹងថាក្នុងនោះមានអ្នកសុំទានទៀត

https://khmer.social/social/ Pheak Tra January 10, 2019

ប្រទេសថៃៈ កាលពីថ្មីៗនេះ អ្នកសុំទានតាមផ្លូវ ក្នុងខេត្តទាំង០៦ ត្រូវប្រឈមនឹងការផាកពិន័យរហូតដល់១ម៉ឺនបាត ស្មើនិងជាង៣០០ដុល្លារ និងជាប់ពន្ធនាគារអតិបរមាមួយខែ ក្រោយពីគេរកឃើញអ្នកទាំងនោះ ល្មើសច្បាប់ម្តងហើយ ម្តងទៀត ដែលត្រូវប្រកាសថា ជាតំបន់គ្មានអ្នកសុំទាន។ ខេត្តចំនួន០៦ ប្រកាសមិនឲ្យមានអ្នកទានរួមមានៈ ខេត្តស៊ីងប៊ុរី ប្រាជិនបូរី ឡាំភូន ផាតតាឡាំង ប៊ូរីរ៉ាម និងសុខោទ័យ។ ចំណែកឯខេត្តចំនួន១១ផ្សេងទៀត ក៏បានប្រកាសពីបំណងរបស់ខ្លួន ដាក់ទៅជាតំបន់គ្មានអ្នកសុំទានផងដែរ គឺខេត្តត្រា បឹងកាន នគរផានុំ ប៉ាតានី ភាងន ណាន់ ពេជ្របុិន ផារ៉ា រ៉ាត់ចាប៊ូរី ម៉េហុងសុង និងណុងប៊ុនឡាំហ្វូន។ កិច្ចប្រជុំលើកទី១ រៀបចំឡើងដើម្បីពិភាក្សាអំពីផែនការគ្រប់គ្រងអ្នកសុំទាន ដើម្បីកាត់បន្ថយចំនួនអ្នកសុំទាន ។

ខេត្តណុនថាបុរី នៅភាគកណ្តាល ប្រទេសថៃ បានបង្កើតគណៈកម្មាធិការមួយ ដែលមានភារកិច្ចកាត់បន្ថយចំនួនអ្នកសុំទាន ខណៈខេត្តត្រាង នៅភាគខាងត្បូង បានផ្តល់ការបណ្តុះបណ្តាលវិជ្ជាជីវៈ ដល់អ្នកសុំទាន ដើម្បីជួយពួកគេ រកការងារធ្វើដើម្បីចិញ្ចឹមគ្រួសារពួកគេ ដោយមិនដើរសុំទានគេ តទៅទៀត។ បើតាមមាត្រា១៩ នៃច្បាប់គ្រប់គ្រងអ្នកសុំទាន ត្រូវបានសភានីតិបញ្ញត្តិជាតិថៃ បានអនុម័ត ក្នុងឆ្នាំ២០១៦ បង្ហាញថា អ្នកដែលគេចាប់បានសុំទាននៅតាមដងផ្លូវ អាចត្រូវផ្តន្ទាទោសឱ្យជាប់ពន្ធនាគារអតិបរមាមួយខែ និងផាកពិន័យអតិបរមា ១ម៉ឺនបាត។ ច្បាប់នេះហាមឃាត់ការសុំទានទាំងអស់ ហើយផ្តន្ទាទោសចំពោះនរណាម្នាក់ ដែលបង្ខំឬគាំទ្រអ្នកដទៃដើម្បីសុំទាន ឬប្រើអ្នកដទៃ ដើម្បីសម្របសម្រួលការសុំទានរបស់ពួកគេ។ ទោះជាយ៉ាងណាក៏ដោយ ការហាមប្រាមមិនអនុវត្តចំពោះមនុស្ស ដែលស្នើសុំលុយពីមិត្តភក្តិ និងសាច់ញាតិ ឬការរៃអង្គាស ដែលត្រូវបានអនុញ្ញាតិដោយច្បាប់រៃអង្គាសប្រាក់ និងការរៃអង្គាសប្រាក់សម្រាប់កិច្ចការសាសនាទេ។

ប៉ុន្តែកិច្ចប្រជុំកាលពីថ្ងៃទី៧ ខែមករា ឆ្នាំ២០១៩ គណៈកម្មាធិការ បានស្នើឱ្យតម្រូតថៃផ្តន្ទាទោសជនល្មើសតាមរយៈការពិន័យតាមកម្រិត គឺពិន័យចំនួន៥០០បាត (ប្រាក់ថៃ) សម្រាប់អ្នកប្រព្រឹត្តល្មើសលើកដំបូង ពិន័យ ២.០០០បាត សម្រាប់អ្នកល្មើសជាលើកទី២ ពិន័យ៥.០០០បាត សម្រាប់អ្នកល្មើសជាលើកទី៣ និងពិន័យ ១០.០០០បាត សម្រាប់អ្នកដែលត្រូវចាប់បានជាលើកទី៤ ឬលើសពីនេះ។ គណៈកម្មាធិការ ក៏បាននិយាយដែរថា អ្នកសុំទានប្រហែល ៣.៥០០នាក់ បានចុះបញ្ជីជាមួយអាជ្ញាធរ។ ហើយកិច្ចប្រជុំនេះ ក៏បានប្រកាសអំពីសកម្មភាពប្រឆាំងនឹងអ្នកសុំទាន នៅទូទាំងប្រទេសថៃ ផងដែរ ៕

# ឃាត់ខ្លួនពលករខ្មែរ ឡាវ និងភូមាចំនួន ៩៦នាក់ ពីបទស្នាក់នៅហួសទិដ្ឋាការកំណត់និង មិនរាយការណ៍កន្លែងស្នាក់នៅ

https://www.facebook.com/CambodiaLabour/ 09-01-2019

កាលពីវេលាម៉ោង ០៦ព្រឹក ថ្ងៃអង្គារ ទី០៨ ខែមករា ឆ្នាំ២០១៩ កម្លាំងអាជ្ញាធរអន្តោប្រវេសន៍ថៃ សហការជាមួយ កម្លាំងសមត្ថកិច្ចចម្រុះ ខេត្តសាមុតប្រាកាន ប្រមាណជាង ២០០នាក់ ចុះត្រួតពិនិត្យ អាអាផាក់មែនកម្ពស់ ៥ ជាន់ មួយកន្លែង ស្ថិតក្នុងក្រុមទី១៩ សង្កាត់បាងផ្លីយ៉ៃ ស្រុកបាងផ្លី ខេត្តសាមុតប្រាកាន ប្រទេសថៃ កាចុះត្រួតទីតាំងខាងលើនោះ កម្លាំងសមត្ថកិច្ចថៃ បានរកឃើញពលករបទេស សញ្ជាតិខ្មែរ ឡាវ និងភូមា សរុបចំនួន ៣៩៨នាក់ ។ ក្នុងនោះមានពលករបរទេសស្នាក់នៅហួសទិដ្ឋាការកំណត់(Over Slay) និងមិនរាយការណ៍កន្លែងនៅសរុបចំនួន៩៦ នាក់ ។ បច្ចុប្បន្នពលករបទេសទាំង ៩៦នាក់ ត្រូវអាជ្ញាធរថៃបញ្ជូន ទៅកាន់អធិការដ្ឋាន តម្រួតខេត្តសាមុតប្រាកាន ដើម្បីចាត់វិធានការតាមផ្លូវច្បាប់។

## ថ្ងៃទី១១ ខែមករា ឆ្នាំ២០១៩

## ឪពុកម្ដាយខ្មែរណែនាំកូនឲ្យទៅធ្វើពលករនៅប្រទេសកូរ៉េខាងត្បូង

https://khmer.voanews.com/ 10 មករា 2019 ស៊ុន ណារិន

រហូតមកដល់ពេលនេះ ពលករខ្មែរនៅប្រទេសកូរ៉េខាងត្បូងមានទៅដល់ជិត៥៤០០០នាក់។ ក្នុងមួយឆ្នាំៗ កម្ពុជាអាចនឹងបញ្ជូនពលករទៅកូរ៉េជាង៤ពាន់នាក់។

ឃុំព្រែកអាជី ខេត្តកំពង់ចាម៖ រវាងការសិក្សា និងការចំណាកស្រុកទៅធ្វើការក្រៅប្រទេស អ្នកស្រីហាម សៀង អាយុ៥៤ឆ្នាំ ជាប្រជាពលរដ្ឋម្នាក់ក្នុងឃុំព្រែកអាជី ស្រុកក្រូចឆ្មារ ខេត្តកំពង់ចាម បានសម្រេចជោគវាសនាកូនប្រុសរបស់អ្នកស្រីឲ្យឈប់រៀន ហើយទៅធ្វើការនៅប្រទេសកូរ៉េខាងត្បូង។ ក្នុងបទសម្ភាសន៍មួយជាមួយ VOA នៅផ្ទះរបស់អ្នកស្រី អ្នកស្រីបានថ្លែងថា៖ «ឃើញគេទៅអស់ហើយ នៅក្រៅតែយើងអ៊ីចឹង។ មួយផ្ទះពីរបី មួយផ្ទះពីរបី អត់តែយើងហ្នឹង ប្រថុយទៅៗកូន។ អាឪហ្នឹងចេះទៅបន្ទោសថា កុំទៅ! កុំអីបានធ្វើគ្រូហ្នឹងគេហើយ»។ កូនប្រុសរបស់អ្នកស្រីគឺលោករិន ឪណា អាយុ២៨ឆ្នាំ បាននិងកំពុងធ្វើការនៅរោងចក្រដែកមួយក្នុងប្រទេសកូរ៉េអស់រយៈពេលជិត៣ឆ្នាំមកហើយ។ មុនពេលចាកចេញទៅប្រទេសកូរ៉េ លោកឪណាបានសម្រេចបោះបង់ការសិក្សាថ្នាក់ទី១១ ក្រោយមានការជំរុញពីម្ដាយរបស់គេ ខណៈប្រជាពលរដ្ឋជាច្រើននៅក្នុងឃុំមួយនេះបានចាកចេញទៅប្រទេសកូរ៉េ។ ដោយសាររៀនខ្មែរផង និងភាសាកូរ៉េផង លោកឪណា ពិបាកនឹងចាប់បានទាំង២ ដូច្នេះលោកបានឈប់រៀនថ្នាក់ខ្មែរទី១១ និងសម្រេចផ្ដោតតែលើភាសាកូរ៉េ។ អ្នកស្រី ហាម សៀង ជាម្ដាយ មានប្រសាសន៍ថា៖ «វារៀនរដ្ឋហ្នឹងផង កូរ៉េផង រៀនអត់ចូលលោកគ្រូ។ ដល់អ៊ីចឹង អានេះផង អានោះផង ដល់ពេលរៀនបាន២ឆ្នាំ អត់ជាប់។ ខ្ញុំថា អាអូនអ្ហា គេទៅកូរ៉េអស់ហើយ ទៅនឹងគេទៅ! "អ៊ីចឹងទៅកូរ៉េ ចោលខ្មែរហើយណាម៉ែ?" ចោលខ្មែរហ្នឹងទៅ បានជាប់កូរ៉េវគ្គហ្នឹង»។

ប្រជាពលរដ្ឋដែលមានបំណងទៅធ្វើការនៅប្រទេសកូរ៉េ ត្រូវតែប្រកួតប្រជែងសមត្ថភាពភាសាកូរ៉េជាមួយបេក្ខជនជាច្រើនផ្សេងទៀត។ រដ្ឋាភិបាលកម្ពុជាមិនអនុញ្ញាតឲ្យមានក្រុមហ៊ុនឯកជនក្នុងការជ្រើសរើសពលករទៅធ្វើការនៅប្រទេសកូរ៉េនោះទេគឺរដ្ឋាភិបាលជាអ្នករ៉ាប់រង ដោយសហការជាមួយប្រទេសកូរ៉េ។ ជាធម្មតា ពលករខ្មែរធ្វើការនៅប្រទេសកូរ៉េអាចរកប្រាក់ចំណូលបានចន្លោះពី១២០០ទៅ១៣០០ដុល្លារក្នុងមួយខែសម្រាប់ការងារផ្នែកកសិកម្ម ហើយពួកគេអាចរកបានចន្លោះពី១៧០០ទៅ១៨០០ដុល្លារអាមេរិកក្នុងផ្នែកឧស្សាហកម្ម។ ពលករខ្មែរប្រហែល ៥៤.០០០នាក់កំពុងធ្វើការនៅប្រទេសកូរ៉េ ហើយពួកគេធ្វើការក្នុងផ្នែកសំណង់ កសិកម្ម និងឧស្សាហកម្មធុនតូច និងមធ្យម។ មានការប៉ាន់ប្រមាណថា ជារៀងរាល់ឆ្នាំ ពួកគេបានផ្ញើលុយសរុបប្រមាណ៣០០លានដុល្លារអាមេរិកមកក្រុមគ្រួសារនៅក្នុងប្រទេសកម្ពុជា។

ស្ថានភាពរស់នៅរបស់អ្នកស្រីសៀងមានភាពល្អប្រសើរជាងមុនគឺពីមុនធ្លាប់ខ្ចីលុយគេ តែឥឡូវមានលុយដាក់ក្នុងធនាគារ។ អ្នកស្រីធ្លាប់បានខ្ចីលុយគេរៀងរាល់រដូវធ្វើស្រែ ដោយសារត្រូវទិញប្រេងសម្រាប់បូមទឹក និងជីដាក់ស្រែ។ ប៉ុន្តែអ្នកស្រីថា បច្ចុប្បន្ននេះ អ្នកស្រីមានលុយសល់ក្នុងធនាគារ ដោយសារកូនប្រុសផ្ញើមកពីប្រទេសកូរ៉េ។ អ្នកស្រីបញ្ជាក់ថា ក្នុងមួយខែៗ កូនប្រុសបានផ្ញើលុយប្រមាណ១ពាន់ដុល្លារដល់អ្នកស្រី ហើយរហូតមកដល់ពេលនេះបានជាង២ម៉ឺនដុល្លាររួចទៅហើយ។ អ្នកស្រីបានយកថវិកាមួយចំនួនទៅធ្វើផ្ទះ ទិញម៉ូតូ និងទិញទូរស័ព្ទដៃទំនើបផងដែរ។ អ្នកស្រីមានប្រសាសន៍ថា៖ «វាធូរ មុនដល់ខែស្រូវអ៊ីចឹង ជំពាក់គេដែរ ហ្នឹងគ្រូ»។ ប៉ុន្តែមុនពេលកូនប្រុសទៅប្រទេសកូរ៉េ អ្នកស្រីបានខ្ចីលុយគេប្រមាណ៣ពាន់ដុល្លារដើម្បីចំណាយមុនចេញទៅធ្វើការ ដូចជាថ្លៃយន្តហោះ និងទិញសម្ភារៈផ្សេងៗ។ ប៉ុន្តែបច្ចុប្បន្ននេះ អ្នកស្រីបានសងគេអស់រួចទៅហើយ។ អ្នកស្រីក៏បានចំណាយលុយអស់រាប់រយដុល្លារសម្រាប់កូនរៀនភាសាកូរ៉េ និងប្រឡងត្រៀមចេញទៅប្រទេសកូរ៉េ។ អ្នកស្រីមានប្រសាសន៍ថា៖ «លុយគ្រាន់តែបណ្ដោះវាទៅមកៗ គេហៅទៅភ្នំពេញហ្នឹងលោកគ្រូ។ ទៅអ៊ីចឹងទៅ១០០ដុល្លារ។ ត្រឡប់មកវិញទៅ ពីរបីថ្ងៃទៀតទៅវិញ១០០ដុល្លារទៀតទៅ។ អាហ្នឹងលុយខ្លួនឯង។ ដល់ពេលវាឡើងយន្តហោះ អាហ្នឹងខ្ញុំយកលុយគេ»។ នៅតាមជនបទ វាជារឿងធម្មតាទេ ដែលប្រជាជនពឹងផ្អែកលើការធ្វើស្រែ និងចម្ការ។ ប៉ុន្តែវានឹងមានការលំបាក ប្រសិនបើពួកគេមិនមានដីសម្រាប់ធ្វើស្រែ និងចម្ការ។ អ្វីដែលពួកគេអាចធ្វើបានគឺការចំណាកស្រុកទៅទីក្រុង ឬទៅក្រៅប្រទេសដែលជាបញ្ហាធំនៅកម្ពុជា។

ប្រទេសចំនួន៧ ដែលពលករកម្ពុជាកំពុងធ្វើការគឺប្រទេសម៉ាឡេស៊ី អារ៉ាប៊ីសាអូឌីត ថៃ ជប៉ុន សិង្ហបុរី ហុងកុង និងប្រទេសកូរ៉េខាងត្បូង។ ប្រជាជនខ្មែររាប់ម៉ឺននាក់កំពុងធ្វើការនៅប្រទេសថៃ និងម៉ាឡេស៊ី ដោយខុសច្បាប់។

អ្នកភូមិលើកឡើងថា ប្រជាជនក្នុងឃុំព្រៃកអាជីនេះបានសម្រេចបញ្ជូនកូនទៅប្រទេសកូរ៉េស្ទើរតែគ្រប់គ្នាទៅហើយ។ មុនពេលកូនរបស់អ្នកស្រីសៀងចេញទៅក្រៅប្រទេស អ្នកភូមិផ្សេងទៀតក៏បានបញ្ជូនកូនទៅជាបន្តបន្ទាប់ផងដែរ ក្នុងនោះកូនប្រុស៣នាក់របស់លោកឃឹម សាន អាយុ៥០ឆ្នាំ។ មិនតែប៉ុណ្ណោះ កូនប្រសារស្រី២នាក់របស់លោកក៏កំពុងធ្វើការនៅប្រទេសកូរ៉េផងដែរ។

លោក ឃឹម សានបានថ្លែងប្រាប់ VOA ថា៖ «ឃើញគេ ឃើញឯងទៅចេះតែបានទៅ ទៅតាមគេ ទៅរៀន ទៅអីតាមគេប្រឡងតាមគេទៅ»។ លោកបន្តថា មុនដំបូងឡើយ កូនប្រុសទី១បានទៅធ្វើការ ហើយបន្ទាប់មកកូនប្រុសទី២ និងទី៣។ ទោះជាយ៉ាងណា លោកហាក់ដូចជាមិនទទួលបានប្រាក់កម្រៃច្រើន ដូចអ្នកស្រីសៀងនោះទេ។ លោកមានប្រសាសន៍ថា៖ «វាគួរសម។ វាមិនពិបាក ក៏មិនស្រណុកពេកដែរ។ ផ្ញើគ្រាន់តែចាយ៥០(ដុល្លារ) ១០០(ដុល្លារ) អ៊ីចឹង»។ មុនពេលកូនចេញទៅ លោកក៏បានខ្ចីលុយគេផងដែរគឺកូនដំបូង ខ្ចី៤ពាន់ដុល្លារ កូនទីពីរខ្ចី៣ពាន់ដុល្លារទៀត និងកូនទីបីខ្ចី៣ពាន់ដុល្លារផងដែរ។ ទោះជាយ៉ាងណា លោកមានប្រសាសន៍ថា កូនរបស់លោកនឹងត្រឡប់មកស្រុកកំណើតវិញ នៅពេលណាមួយ ដែលពួកគេអាចសន្សំលុយបានខ្លះ ដើម្បីរកស៊ីនៅស្រុកខ្មែរ។ លោកមានប្រសាសន៍ថា៖ «ចង់ឲ្យទៅម្នាក់មួយអាណត្តិទៅ ចង់បានលុយរកស៊ី។ នៅម៉េចកើត? មានកូនមានចៅ។ គ្រាន់តែសន្សំលុយឲ្យបានដើមរកស៊ីនៅស្រុកខ្មែរយើង»។

នៅក្នុងឃុំដដែលនេះ អ្នកជិតខាងអ្នកស្រី សៀង គឺអ្នកស្រី ជន ណាត អាយុ៦៥ឆ្នាំ មានប្រសាសន៍ថា អ្នកស្រីមានកូនស្រី២នាក់ដែលបានរៀបការជាមួយស្វាមីកូរ៉េ ហើយបានទៅរស់នៅទីនោះជាច្រើនឆ្នាំមកហើយ។ អ្នកស្រីមានប្រសាសន៍ថា ពួកគេទទួលបានសញ្ជាតិកូរ៉េរួចហើយ។ អ្នកស្រីបន្តថា ពួកគេបានផ្ញើលុយមកអ្នកស្រីដើម្បីធ្វើផ្ទះ និងចាយវាយបន្តិចបន្តួចផងដែរ។ អ្នកស្រីបញ្ជាក់ថា៖ «អី ឥឡូវ ផ្ញើតែចាយ១០០(ដុល្លារ)។ គេមក គេធ្វើផ្ទះទាំងអស់ហ្នឹងណ៎ា»។

បើតាមមន្ត្រីកម្ពុជា ស្ត្រីខ្មែរប្រមាណ៨ពាន់នាក់បានរៀបការជាមួយប្ដីកូរ៉េ។

មេឃុំព្រៃកអាជី លោកអ៊ីវ លីហួរបានថ្លែងប្រាប់ VOA ថា ប្រជាពលរដ្ឋក្នុងឃុំបានសម្រុកទៅប្រទេសកូរ៉េច្រើន ដោយសារពួកគាត់បានឃើញជីវភាពគ្រួសារដែលមានកូនទៅធ្វើការនៅប្រទេសកូរ៉េ ដូច្នេះពួកគាត់តាមគ្នា។ លោកបន្ត ថា ក្មេងៗជាសិស្សមួយចំនួនបានឈប់រៀនត្រឹមថ្នាក់ទី១១ ទី១២ រួចក៏ទៅធ្វើការនៅប្រទេសកូរ៉េ។ លោកមាន ប្រសាសន៍ថា៖ «និយាយទៅ ម៉ែឪគេជំរុញដែរ ហើយការស្ម័គ្រចិត្តខ្លួនគេផង។ ពលករច្រើនតែយុវជន អ្នកមានគ្រួសារ កូនមួយ កូនពីរអីហ្នឹងណា។ ខ្លះគេរៀនប្រឡងបាក់ឌុបជាប់ទៅ ខ្លះត្រូវប្រឡងអីចឹងទៅ។ ម្នាក់ៗមើលឃើញតាមគ្នា។ ខ្លះនឹកឃើញថា ទៅរកលុយសិនអីចឹងទៅ ទៅរកលុយទៅ! ដូចថា ជាប់បាក់ឌុប មករកស៊ីអ៊ីចឹងទៅ ខ្លះមករកស៊ីវិញអ៊ីចឹងទៅ»។

ទោះជាយ៉ាងណា លោកយល់ថា ពលករដែលទៅធ្វើការនៅប្រទេសកូរ៉េពិបាកនឹងប្រើជំនាញរបស់ខ្លួនដែល មានបទពិសោធន៍នៅទីនោះ មកធ្វើការនៅប្រទេសខ្មែរ។ លោកមានប្រសាសន៍ថា៖ «ខ្ញុំមើលទៅ មានខ្លះអី ខ្លះទៅ ខ្លះ ក៏គ្មានចាប់ជំនាញអីបាន ព្រោះយើងទៅធ្វើការនៅហ្នឹង ខ្លះរោងចក្រតូច។ តាមពិតទៅ ជំនាញដែលគេឲ្យមាន អ្នកនេះ ធ្វើស្អី អ្នកនោះធ្វើស្អី យើងយកមកផ្គួបផ្សំ បានន័យថា ធ្វើវាអត់កើតដដែល»។ មេឃុំរូបនោះបានបញ្ជាក់ថា អ្នកខ្លះត្រឡប់ពីប្រទេសកូរ៉េវិញ ហើយមានលុយ ពួកគេបានទិញដី និងខ្លះទៀតបានចាប់ផ្ដើមរបររកស៊ីមួយចំនួន។

លោកឌី ថេហូយ៉ា មន្ត្រីកម្មវិធីនៃមជ្ឈមណ្ឌលសម្ព័ន្ធភាពការងារ និងសិទ្ធិមនុស្ស (Central)មានប្រសាសន៍ថា កូរ៉េខាងត្បូងមានលក្ខខណ្ឌការងារល្អ ការគោរពសិទ្ធិមនុស្ស និងប្រាក់កម្រៃការងារល្អប្រសើរជាងគេ។ លោកបញ្ជាក់ថា ពលករខ្មែរទៅប្រទេសផ្សេង ដូចជាប្រទេសថៃ និងម៉ាឡេស៊ី រងការរំលោភបំពាន ដោយសារពួកគេជាពលករមិនមាន ជំនាញ ហើយមិនយល់ដឹងពីច្បាប់ការងារ។ លោកក៏បារម្ភអំពីការត្រឡប់មកពីក្រៅប្រទេសវិញរបស់ពលករ ដោយសារ កម្ពុជាមិនទាន់មានការរៀបចំឲ្យពួកគេបានប្រើប្រាស់ជំនាញទាំងនោះនៅកន្លែងការងារ។ លោកមានប្រសាសន៍ថា៖ «អ៊ីចឹង រាល់ថ្ងៃយើងអត់មានឧទាហរណ៍។ ទៅនៅកូរ៉េពីរឆ្នាំ ឬ៤ឆ្នាំ ត្រឡប់មកវិញ តាមសមត្ថភាពរបស់គាត់ បើគាត់ រកបានការងារបានធ្វើជារឿងឱកាសរបស់គាត់។ វាអត់មានអា Plan [ផែនការ] អ្នកដែលមកពីកូរ៉េ អ្នកមកពីប្រទេសផ្សេងៗ បញ្ចប់កុងត្រា កិច្ចសន្យាការងារស្រុកគេហ្នឹង គួរមានចន្លោះ គួរតែមានទីផ្សារការងារហ្នឹងសម្រាប់ពួកគេ ឲ្យគាត់ បានប្រើប្រាស់ជំនាញរបស់គាត់ បន្តការងារ បន្តអាជីពរបស់គាត់ហ្នឹង»។

កាលពីខែធ្នូឆ្នាំ២០១៧ លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន បានជួបជាមួយមន្ត្រីរបស់កូរ៉េ ដោយពួកគេមានការ កោតសរសើរពលករខ្មែរនៅទីនោះ។ លោកហ៊ុន សែនបានថ្លែងថា៖ «នៅកូរ៉េមានព័ត៌មានល្អ គេបានចាត់ទុកថា កម្មករ កម្មការិនីរបស់កម្ពុជាមានស្តង់ដារខ្ពស់ណាស់ មានកម្រិតគោរពវិន័យខ្ពស់ណាស់ មានវិជ្ជាជីវៈខ្ពស់ណាស់»។

លោកហេង សួរ អ្នកនាំពាក្យក្រសួងការងារ បានថ្លែងថា រដ្ឋាភិបាលកំពុងធ្វើការ ដើម្បីធ្វើឲ្យប្រសើរនូវស្ថាន ភាពនៃពលករដែលត្រឡប់មកវិញ។ លោកបន្តថា រដ្ឋាភិបាលក៏បានគិតគូរដល់ជំនាញរបស់ពួកគេ ពេលពួកគេត្រឡប់ មកវិញផងដែរ តាមរយៈការទទួលស្គាល់ជំនាញ និងបទពិសោធន៍របស់ពួកគេ។

ត្រឡប់មកផ្ទះរបស់អ្នកស្រី សៀង វិញ អ្នកស្រីនៅតែធ្វើស្រែ និងដាំឈូកដើម្បីរកចំណូលបន្ថែមពីការផ្ញើលុយ របស់កូនពីក្រៅប្រទេស។ អ្នកស្រីសៀងបានឲ្យដឹងថា ក្នុងមួយសប្តាហ៍ អ្នកស្រីទូរស័ព្ទទៅកូន ហើយពេលណាចង់ ឃើញមុខ អ្នកស្រីអាចនិយាយគ្នាតាមហ្វេសប៊ុក។ ទោះជាយ៉ាងណា អ្នកស្រីបង្ហាញក្តីព្រួយបារម្ភអំពីសុវត្ថិភាព និង សុខភាពកូនប្រុសផងដែរ ដោយគេសារធ្វើការនៅកន្លែងដែលក្តៅ។ អ្នកស្រីមានប្រសាសន៍ថា៖ «ក្តៅណាស់ គាត់ត្អូញ ដែរ។ គេនៅកើត យើងនៅកើត។ ម៉េចខ្ជិលដែរ»។ អ្នកស្រីបញ្ជាក់ថា កូនប្រុសរបស់អ្នកស្រីធ្លាប់ជួបគ្រោះថ្នាក់ការងារ ផងដែរ។ អ្នកស្រីមានប្រសាសន៍ថា៖ «ម៉ាស៊ីនកាត់ក្រចកនេះដាច់បន្តិចដែរហ្នឹង។ ប៉ុន្តែវាអត់មានប្រាប់ខ្ញុំទេ ដេកពេទ្យ មួយខែដែរ»។ ទោះជាយ៉ាងណា អ្នកស្រីក៏បានផ្តាំឲ្យកូនចេះមើលថែសុខភាព ដោយសារអាកាសធាតុនៅប្រទេសកូរ៉េ ត្រជាក់ពេក៕

# កម្ពុជាកំពុងចាប់អារម្មណ៍ទីផ្សារពលករជំនាញនៅជប៉ុន ខណៈជប៉ុនកែប្រែច្បាប់ការងាររបស់ខ្លួន

http://km.rfi.fr/cambodia/ ដោយ ញឹម សុផល 10/01/2019

នៅក្នុងជំនួបជាមួយ លោក មីគី វ៉ាត់ណាបេ (MIKI WATANABE) ប្រធានគណៈកម្មាធិការអេចិន្ត្រៃយ៍កិច្ចការបរទេស និងការពារជាតិជប៉ុន នាព្រឹកថ្ងៃទី១០ ខែមករា នេះ រដ្ឋមន្ត្រីក្រសួងការងារ លោក អ៊ិត សំហេង បានថ្លែងថា គិតមកដល់ពេលនេះកម្ពុជាមានកម្មសិក្សាការី ដែលបណ្តុះបណ្តាលដោយក្រុមហ៊ុនជប៉ុន មានចំនួនជាង៩ពាន់នាក់។ ការបើកទូលាយច្បាប់ការងារជប៉ុន ធ្វើឲ្យប្រទេសកម្ពុជា មានការចាប់អារម្មណ៍ និងគ្រោងបញ្ជូនពលករជំនាញមធ្យមរបស់ខ្លួនទៅធ្វើការនៅជប៉ុនផងដែរ។

លោក អ៊ិត សំហេង រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ឲ្យដឹងថា នៅពេលខាងមុខ នឹងមានក្រុមហ៊ុនជប៉ុនបើកដំណើរការជាបន្តបន្ទាប់ដើម្បីបណ្តុះបណ្តាលនិងបង្កភាពងាយស្រួលបញ្ជូនកម្មសិក្សាការី ពីកម្ពុជាទៅធ្វើការនៅជប៉ុន ខណៈដែលរដ្ឋាភិបាលជប៉ុនបានកែប្រែច្បាប់ថ្មី។ ដើម្បីអនុវត្តនូវគម្រោងថ្មីនេះបាន នាពេលខាងមុខ រដ្ឋាភិបាលប្រទេសទាំងពីរ កម្ពុជា-ជប៉ុន ពិសេសក្រសួងការងារ កំពុងរៀបចំឲ្យមានចុះកិច្ចព្រមព្រៀងសហប្រតិបត្តិការជាមួយក្រសួងពាក់ព័ន្ធរបស់ប្រទេសជប៉ុន ដើម្បីអនុវត្តនូវប្រព័ន្ធថ្មី និងច្បាប់ថ្មីរបស់ភាគីជប៉ុន ដែលកំពុងមានការខ្វះខាតកំលាំងពលកម្ម។ នេះបើតាមលោក អ៊ិត សំហេង។

សូមរំលឹកថា ជប៉ុនបានចាប់ផ្តើមរៀបចំបង្កើតឱ្យមានគម្រោងថ្មី សម្រាប់បង្កើនលំហូរនៃកម្លាំងពលកម្មពីបរទេស ហើយនឹងមានការអនុវត្តនាអំឡុងខែមេសាឆ្នាំ២០១៩ខាងមុខ ដើម្បីដោះស្រាយបញ្ហាកខ្វះកម្លាំងពលកម្មជំនាញនៅប្រទេសជប៉ុន។ វិស័យដែលជប៉ុនកំពុងខ្វះកម្លាំងពលកម្មខ្លាំងជាងគេ គឺកសិកម្ម សំណង់ ថែទាំមនុស្ស ឬមើលក្មេង។ ជាមួយគ្នានេះ ជប៉ុនបាននឹងកំពុងរៀបចំឱ្យមានសេចក្តីព្រាង និងកិច្ចព្រមព្រៀងសហប្រតិបត្តិការជាមួយបណ្តាប្រទេសបញ្ជូនទាំងអស់ ដែលបានអនុញ្ញាតឱ្យបញ្ជូលទាំងកម្មសិក្សាការីបច្ចេកទេស និងអ្នកធ្វើការជំនាញបច្ចេកទេស ទៅប្រទេសជប៉ុន។

លោក ហេង សួរ អ្នកនាំពាក្យក្រសួងការងារកម្ពុជា បានបញ្ជាក់ថា ការបញ្ជូនពលរដ្ឋខ្មែរទៅធ្វើការនៅប្រទេសជប៉ុនលើកក្រោយៗទៀត នឹងត្រូវធ្វើឡើងក្នុងនាមពលករច្បាស់លាស់ ដែលការពារដោយច្បាប់ជប៉ុន មិនមែនក្នុងនាមកម្មសិក្សាការី ដូចមុនៗទេ ខណៈកម្មសិក្សាការីនៅជប៉ុនមានច្បាប់មួយគ្រប់គ្រងដាច់ដោយឡែក។

# កម្ពុជាឈរលើលេខ ៧ មានពលករទៅធ្វើការនៅប្រទេសជប៉ុនច្រើន

http://news.sabay.com.kh/ ថ្ងៃនេះ ម៉ោង 09:19

នៅក្នុងចំណោមដៃគូរបស់ប្រទេសជប៉ុនដែលបញ្ជូនពលករទៅធ្វើការនៅទីនោះ គឺមានចំនួន១៥ប្រទេស ហើយកម្ពុជាឈរលើលេខរៀងទី៧។ បើតាមទិន្នន័យពីក្រសួងការងារថ្មីៗឲ្យដឹងថា រហូតមកដល់ពេលនេះ កម្ពុជាបានបញ្ជូនពលករ កម្មសិក្សាការីទៅធ្វើការនៅប្រទេសជប៉ុន មានចំនួន ប្រមាណជិត ១ម៉ឺននាក់។

ក្នុងជំនួបពិភាក្សាការងារជាមួយលោក មីគី វ៉ាត់ណាបេ (Miki Watanabe) ប្រធាន គណៈកម្មាធិការអេចិន្ត្រៃយ៍កិច្ចការបរទេស និងការពារជាតិជប៉ុន កាលពីព្រឹកថ្ងៃទី១០ ខែមករា ឆ្នាំ២០១៩ នៅទីស្តីការក្រសួង ឯកឧត្តម អ៊ិត សំហេង រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះ បណ្តាលវិជ្ជាជីវៈ បានមានប្រសាសន៍ថា នៅពេលខាងមុខនឹងមានក្រុមហ៊ុនជប៉ុនបើកជាបន្ត បន្ទាប់ ដើម្បីបណ្តុះបណ្តាល និងងាយស្រួលបញ្ជូនកម្មសិក្សាការីពីកម្ពុជាទៅជប៉ុនស្របពេល ដែលរដ្ឋាភិបាលជប៉ុនបានកែប្រែច្បាប់ថ្មី។ ឯកឧត្តមបានបញ្ជាក់ថា ក្រុមហ៊ុននេះ គឺជាក្រុម ហ៊ុនចម្រុះខាងផ្នែកឧស្សាហកម្ម និងផ្នែកសេវាកម្ម ដែលបានគ្រប់គ្រងបុគ្គលិកប្រមាណ២ម៉ឺននាក់ នៅប្រទេសជប៉ុន ដែលត្រូវការកម្លាំងបន្ថែមទៀត។ឯកឧត្តមរដ្ឋមន្ត្រីបានបន្តថា ដើម្បីអនុវត្តន៍នូវគម្រោងថ្មីនេះបាន នាពេលខាងមុខរដ្ឋាភិបាល

ប្រទេសទាំងពីរ កម្ពុជា-ជប៉ុន ពិសេសក្រសួងការងារកំពុងរៀបចំឱ្យមានចុះកិច្ចព្រមព្រៀងសហប្រតិបត្តិការជាមួយក្រសួងពាក់ព័ន្ធរបស់ជប៉ុន សម្រាប់អនុវត្តន៍នូវប្រព័ន្ធថ្មី និងច្បាប់ថ្មីរបស់ភាគីជប៉ុន។

គួរបន្ថែមថា ជប៉ុនបានចាប់ផ្តើមរៀបចំបង្កើតឱ្យមានគម្រោងថ្មី សម្រាប់បង្កើនលំហូរនៃកម្លាំងពលកម្មពីប្រទេសផ្សេងៗ និងសម្រាប់អនុវត្តន៍នូវកំឡុងខែមេសា ឆ្នាំ២០១៩ខាងមុខនេះ ដើម្បីដោះ ស្រាយបញ្ហាកខ្វះកម្លាំងពលកម្មជំនាញនៅប្រទេសជប៉ុន។ ជាមួយគ្នានេះ ជប៉ុនបាននិងកំពុងរៀបចំឱ្យមានសេចក្តីព្រាង និងកិច្ចព្រមព្រៀងសហប្រតិបត្តិការជាមួយបណ្តាប្រទេស បញ្ជូន ទាំងអស់ ដែលបានអនុញ្ញាតឱ្យបញ្ជូលទាំងកម្មសិក្សាការីបច្ចេកទេស និងអ្នកធ្វើការជំនាញ បច្ចេកទេស ទៅប្រទេសជប៉ុន។

## ផ្ទុះរឿងលោកអនុសេនីត្រី ជន់ ឈាន ហៅ ជ្រក់ ដាក់កំលាំងពលករស្ពាយឈើជាច្រើននាក់ក្នុងមួយៗថ្ងៃអោយទៅលួចកាប់ឈើគ្រញូង ធ្លង់ ក្នុងដីប្រទេសថៃ

https://www.facebook.com/cpnnews.info/ សារព័ត៌មាន ចក្រភពព័ត៌មាន CPN News 11-01-2019

ខេត្តឧត្តរមានជ័យៈល្បីទៀតហើយលោកអនុសេនីយ៍ត្រី ជន់ ឈាន ហៅជ្រក់ មេបញ្ជាការកងអនុសេនាតូចលេខ៣ចំណុះ ផ្នែកសឹងរងនៃស្រុកអន្លង់វែងប្រើអំណាចនិងតួនាទីជាទាហ៊ានសក្តិ៍បីដាក់កំលាំងពលកអោយឡើងទៅលួចកាប់ឈើគ្រញ៉ូងនិងឈើធ្នង់នៅទឹកដីប្រទេស ថៃពេល ពលកស្ពាយឈើចុះមកវិញលោក ជន់ ឈាន ហៅ ជ្រក់ចង់លេងប្លន់ស្លឹកដោយកំរាមកំហែង និងទិញឈើក្នុងតំម្លៃថោកហើយ ចង់គាប់ស៊ីឡាក់តែម្តង។ ជាក់ស្តែងនៅថ្ងៃទី១០ ខែ មករា ឆ្នាំ ២០១៩នេះមានការលើកឡើងពីពលរដ្ឋរស់នៅក្នុងភូមិដងទង សង្កាត់ កូនក្រៀល ក្រុងសំរោងខេត្តឧត្តរមានជ័យ បានរៀបរាប់ថាលោកអនុសេនីយ៍ ជន់ ឈានហៅជ្រក់មេបញ្ជាការកងអនុសេនាតូចលេខ៣ចំណុះអោយផ្នែកសឹករងនៃស្រុកអន្លង់វែង បានអោយដឹងថា ក្រុមដែលចូលទៅលួចអារឈើក្នុងទឹកដីប្រទេសថៃបានស្ពាយឈើមកលក់អោយលោកជន់ ឈានហៅជ្រក់ក្នុងនោះមានឈើគ្រញ៉ូងមុខកាត់០៨ឬ០៩និង១០ប្លនជ្រុងលោកទិញនិងគាបតំម្លៃអោយថោកជាងមេឈ្មួញឯទៀតជាងពាក់កណ្តាលចំណែកឈើធ្នង់មានមុខកាត់ ៤០បណ្តោយមួយម៉ែត្រពីតឹកទិញមួយគីឡូក្នុងតំម្លៃ១២០០០រៀលប៉ុណ្ណោះ បើក្រុមណាមិនលក់អោយនឹងចាប់ឈើនេះយកទាំងអស់សូម្បីតែលុយមួយរៀលក៏មិនអោយដែរ។

សូមបញ្ជាក់: ពលរដ្ឋរស់នៅភូមិដងទងបានសំដែងការខកចិត្តថាពួកគាត់ជាពលរដ្ឋក្រីក្ររកមួយថ្ងៃស៊ីមួយមិនគួណាលោកជន់ ឈានហៅជ្រក់មេបញ្ជាការអនុសេនាតូចលេខ៣បើអំណាចនិងតួនាទីជាទាហ៊ានគាប់សង្កត់ពួកគាត់ដល់ម្លឹងនោះទេ ដោយអោយពួកគាត់ឡើងទៅលួចកាប់ឈើនៅក្នុងទឹកដីប្រទេសថៃទាំងប្រថុយជីវិតដោយមិនគិតពីអាយុជីវិតបែជាលោកទិញឈើតំម្លៃថោកជាងគេពាក់កណ្តាល ហើយបើសិនជាពួកគាត់ហ៊ានទៅលក់ឈើអោយថារែកផ្សេងលោកជន់ ឈានហៅជ្រក់និងបញ្ជាអោយកូនចៅរបស់លោកមកចាប់ឈើយកក្លាមសូម្បីតែមួយរយរៀលមិនបានផងចឹងហើយមានតែសំរេចចិត្តលក់ព្រោះបើពួកគាត់មិនលក់នោះទេស្មើនិងអត់។

ជុំវិញការចោទខាងលើនេះភ្នាក់ងារCPN.newsយើងនៅព្រឹកថ្ងៃទី ១១ ខែ មករានេះ មិនទាន់អាចសុំការបំភ្លឺពីលោកអនុសេនីយ៍ត្រីជន់ ឈានហៅជ្រក់បានទេព្រោះខលទៅបានបិទទូសព្ទ័ ។ ដោយ: សាន់រិទ្ធ

## បើកហាងម៉ាស្សាបន្ទប់បម្រើសេវាផ្លូវភេទ ថ្ងៃនេះសមត្ថកិច្ចចាប់បញ្ជូនថៅកែ២នាក់ប្តី-ប្រពន្ធ ទៅតុលាការចាត់ការតាមច្បាប់

http://www.freshnewsasia.com/ 2019-01-11

**(ភ្នំពេញ)៖** នៅព្រឹកថ្ងៃទី១១ ខែមករា ឆ្នាំ២០១៩នេះ នគរបាលនៃនាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន ក្រសួងមហាផ្ទៃ បានបញ្ជូន២នាក់ប្តី-ប្រពន្ធ ដែលជាម្ចាស់ហាងម៉ាស្សាកោសជប់យីហោ «បាតដៃ

សម្រួលសរសៃបែបបុរាណខ្មែរ» ជ្រោកក្រោមហាងផាត់មុខ និងធ្វើសក់ឃីហោ «ស្រីពៅ សាឡុន» ដែលបានលួចបង្កប់សេវាផ្លូវភេទ ទៅកាន់សាលាដំបូងរាជធានីភ្នំពេញ ដើម្បីបន្តចាត់ការតាមនីតិវិធីច្បាប់ពាក់ព័ន្ធ ករណីបើកហាងម៉ាស្សាផ្តល់សេវា រួមភេទដោយខុសច្បាប់។

ជនសង្ស័យទាំង២នាក់ខាងលើនេះ ត្រូវបានសមត្ថកិច្ចបង្ក្រាបបាន កាលពីវេលាម៉ោង៨៖២០នាទីយប់ថ្ងៃទី៨ ខែមករា ឆ្នាំ២០១៩ កន្លងទៅត្រង់ចំណុចផ្ទះលេខ៨៧ EoE តាមបណ្តោយផ្លូវ១៣៨ ភូមិ៥ សង្កាត់ផ្សារដេប៉ូទី២ ខណ្ឌទួលគោក រាជធានីភ្នំពេញ។ ប្រតិបត្តិការចុះបង្ក្រាបហាងម៉ាស្សាកោសជប់ ដែលលួចលាក់បង្កប់សេវាផ្លូវភេទខាងលើនោះ ក្រោមមានការដឹកនាំផ្ទាល់ពីលោកឧត្តមសេនីយ៍ទោ សំបូរ មាណ្ណារិទ្ធ អនុប្រធាននាយកដ្ឋាន និងលោកឧត្តមសេនីយ៍ទោ ឯម សុជឿន អនុប្រធាននាយកដ្ឋាន បានដឹកនាំកម្លាំងចុះបង្ក្រាប និងឆែកឆេរទីតាំងលួចលាក់បង្កប់សេវាកម្មផ្លូវភេទខាងលើ។ ជាលទ្ធផល កម្លាំងនគរបាលបានឃាត់ខ្លួនមនុស្សចំនួន៨នាក់ ក្នុងនោះ បានឃាត់ខ្លួនប្តីប្រពន្ធមួយគូ ដែលជាដែលជាហាងម៉ាស្សាខាងលើ ដែលបុរសជាប្តីមានឈ្មោះ សុខ រតនា អាយុ២៧ឆ្នាំ ស្នាក់នៅកន្លែងកើតហេតុ។ នៅក្នុងប្រតិបត្តិការនោះ នគរបាលបានរកឃើញនារីម៉ាស្សាចំនួន៥នាក់ទៀត ជាជនរងគ្រោះ និងបុរសម្នាក់ទៀត ដែលត្រូវជាភ្ញៀវ រួមទាំងវត្ថុមួយចំនួនទៀតផងដែរ៕

## ស្ត្រីពលករខ្មែរ០២នាក់និងកូនក្នុងផ្ទៃ៨ខែ បានស្លាប់បាត់បង់ជីវិតនៅក្នុងហេតុការណ៍គ្រោះថ្នាក់ចរាចរណ៍មួយនៅក្នុងស្រុកស៊ីរ៉ាឆា ខេត្តឈុនបុរី ប្រទេសថៃ

https://www.facebook.com/CambodiaLabour/ January 9 at 2:13 PM 2019

ស្ត្រីពលករខ្មែរ០២នាក់ និងកូនក្នុងផ្ទៃ៨ខែ បានស្លាប់បាត់បង់ជីវិតនៅក្នុងហេតុការណ៍គ្រោះថ្នាក់ចរាចរណ៍មួយនៅក្នុងស្រុកស៊ីរ៉ាឆា ខេត្តឈុនបុរី ប្រទេសថៃ តាមប្រភពព័ត៌មានថៃ បានប្រាប់អោយដឹងថា ពលករខ្មែរពីនាក់ម្តាយ ឈ្មោះ ឆាំ អាយុ ៤៨ឆ្នាំ និង ឈ្មោះ សៀម អាយុ ២២ ឆ្នាំ ត្រូវជាកូនស្រី ដែលកំពុងមានផ្ទៃពោះ ៨ខែ បានបើកបរម៉ូតូឌុបគ្នាទៅតាមផ្លូវជាតិស្ថិតនៅក្នុងស្រុកស៊ីរ៉ាឆា ខេត្តឈុនបុរី ប្រទេសថៃ ត្រូវម៉ូតូមួយគ្រឿងទៀតបើកបរដោយជនជាតិថៃបានបុកគ្នាជាមួយម៉ូតូជនរងគ្រោះបណ្តាលអោយស្ត្រីទាំងពីស្លាប់ភ្លាមៗនៅកន្លែងកើតទាំងម្តាយទាំងកូនក្នុងផ្ទៃហេតុការណ៍គ្រោះថ្នាក់នេះបានកាលពីថ្ងៃអង្គារ ទី០៨ ខែមករា ឆ្នាំ២០១៩ កន្លងទៅ ។

## ទូតកម្ពុជា ដោះស្រាយបញ្ហា ពលរដ្ឋខ្មែររងគ្រោះនៅថៃ២ករណី

https://www.dap-news.com/ ByID:114 Posted on 10 January 2019 | 16:15

ភ្នំពេញ៖ មន្ត្រីស្ថានទូតកម្ពុជា នៅទីក្រុងបាងកក ប្រទេសថៃ បានជួយដោះស្រាយបញ្ហាពលរដ្ឋខ្មែរ ដែលរងគ្រោះនៅ ប្រទេសថៃ ចំនួន២ករណី ដោយសារចាញ់បោកមេខ្យល់ និងបញ្ហាវិវាទការងាររវាងថៅកែ និងកូនចៅ។

យោងតាមបណ្តាញសង្គមហ្វេសប៊ុក របស់ស្ថានទូតខ្មែរប្រចាំប្រទេសថៃ នៅថ្ងៃទី១០ ខែមករា ឆ្នាំ២០១៩នេះ បានឲ្យដឹងថា មន្ត្រីស្ថានទូតបានសម្របសម្រួល ជាមួយអាជ្ញាធរថៃ ជួយពលរដ្ឋខ្មែររងគ្រោះចំនួន៤នាក់ ដែលរងគ្រោះចាញ់បោកមេខ្យល់ នាំយកទៅកោះសាម៉ុយ អស់លុយ៨០០០បាតក្នុងម្នាក់ៗ ហើយគ្មានការងារធ្វើ និងគ្មានប្រាក់ជាប់ខ្លួន , ២-មន្ត្រីស្ថានទូត បានទទួលពាក្យបណ្តឹងពីពលរដ្ឋខ្មែរ ដែលរត់មកស្ថានទូតវេលាម៉ោង ១១យប់ ថ្ងៃទី៦ មករា ដោយស្នើសុំស្នាក់នៅស្ថានទូតមួយយប់ និងស្នើសុំស្ថានទូតជួយគាត់ ព្រោះគាត់មានបញ្ហាវិវាទជាមួយកូនថៅកែ ។ ប្រភពបន្តថា បន្ទាប់មកអាជ្ញាធរថៃ បានដឹកពលរដ្ឋខ្មែររងគ្រោះ ចំនួន២នាក់ ត្រឡប់ទៅប្រទេសខ្មែរវិញ តាមច្រកអន្តរជាតិប៉ោយប៉ែត និងបានជួយដឹកជញ្ជូនជនរងគ្រោះខ្មែរ២នាក់ ពីកោះសាម៉ុយមកកាន់ស្ថានទូតកម្ពុជា នៅទីក្រុងបាងកកផងដែរ៕ ដោយ៖ នឿត សម្ផស្ស

# ថ្ងៃទី១៤ ខែមករា ឆ្នាំ២០១៩

## ឈប់ចំណាកស្រុកទៅថៃ! អ្នកស្រី ចាន់ធឿន ខាកមកដាំបន្លែ និងចិញ្ចឹមមាន់ រកចំណូលបានច្រើនជាង

https://thmeythmey.com/ 13, Jan 2019 , 8:59 am

ភ្នំពេញ៖ អ្នកស្រី អួន ចាន់ធឿន បានវិលត្រឡប់មកស្រុកកំណើតដាំបន្លែ និងចិញ្ចឹមមាន់វិញ បន្ទាប់ពីចំណាកស្រុកទៅប្រទេសថៃ រយៈពេល២ឆ្នាំ។ អ្នកស្រី ចាន់ធឿន ជាកសិករដាំបន្លែ និងចិញ្ចឹមមាន់លក្ខណៈគ្រួសារ នៅស្រុកសន្ទុក ខេត្តកំពង់ធំ។ បើតាមអ្នកស្រី ចាន់ធឿន របរដាំបន្លែ និងចិញ្ចឹមមាន់ បានធ្វើឲ្យជីវភាពគ្រួសារអ្នកស្រីធូរជារជាងធ្វើកម្មករចំណាកស្រុកនៅថៃ ដោយមួយខែអ្នកស្រី អាចរកចំណូលបាន ៨០ម៉ឺនរៀល។ មានវ័យ៣៤ឆ្នាំ អ្នកស្រី អួន ចាន់ធឿន និងស្វាមី បានសម្រេចចិត្តត្រឡប់មកធ្វើការនៅស្រុកកំណើតវិញ ក្រោយពេលចំណាកស្រុកនៅប្រទេសថៃរយៈពេល២ឆ្នាំ។ អ្នកស្រី ចាន់ធឿន និងស្វាមី បានចំណាកស្រុកទៅថៃ បន្ទាប់ពីឃើញអ្នកជិតខាងរកចំណូលបានច្រើនពីការងារធ្វើជាកម្មករនៃក្រុមហ៊ុនមួយនៅប្រទេសថៃ។ ការចំណាកស្រុកនេះ មិនបានធ្វើឲ្យអ្នកស្រី ចាន់ធឿន រកប្រាក់ចំណូលបានច្រើនដូចអ្នកជិតខាងនោះទេ។ ផ្ទុយទៅវិញ អ្នកស្រី ចាន់ធឿន ដាំបន្លែ និងចិញ្ចឹមមាន់នៅផ្ទះ រកចំណូលបាន៨០ម៉ឺន បូកនឹងចំណូលស្វាមីរបស់អ្នកស្រីដែលរកបានជាង៨០ម៉ឺនរៀលក្នុងមួយខែ។

ក្នុងបទសម្ភាសជាមួយសារព័ត៌មានថ្មីៗ អ្នកស្រី អួន ចាន់ធឿន បានរៀបរាប់យ៉ាងដូច្នេះ៖ «ដោយសារអ្នកភូមិរកចំណូលបានច្រើនពីការចំណាកស្រុកនេះ ទើបទៅតាមគេដែរ។ គេទៅចំកន្លែងល្អ តែយើងទៅមិនត្រូវកន្លែងដូចគេ»។ អ្នកស្រី ចាន់ធឿន ហាក់មានអារម្មណ៍អន់ចិត្ត ដែលសម្រេចចិត្តចំណាកស្រុកនៅថៃ។ ស្ត្រីរស់នៅខេត្តកំពង់ធំរូបនេះ បានមកដាំបន្លែ និងចិញ្ចឹមមាន់វិញ ដែលទទួលបានបណ្តុះបណ្តាលពីអង្គការសេដាក។ បើតាមអ្នកស្រី ចាន់ធឿន កសិកម្មមានសារៈសំខាន់សម្រាប់អ្នកស្រី ជាពិសេសបញ្ហាសុខភាព។ ក្រៅពីដាំបន្លែ និងចិញ្ចឹមមាន់ អ្នកស្រី ចាន់ធឿន បានស្រែបន្ថែម រួមទាំងបង្កើតក្រុមសន្សំមួយនៅក្នុងភូមិផងដែរ៕

## នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន បើកវគ្គបណ្តុះបណ្តាលពង្រឹងសមត្ថភាពដល់នគរបាលរាជធានី-ខេត្ត ចំនួន៥ថ្ងៃ

http://cambodiapolice.com/policekh/ 10:25 am 14 មករា 2019

**ភ្នំពេញ ៖** នៅព្រឹកថ្ងៃទី១៤ ខែមករា ឆ្នាំ២០១៩នេះ នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន នៃអគ្គស្នងការដ្ឋាននគរបាលជាតិ បានបើកវគ្គបណ្តុះបណ្តាលស្តីពីយុទ្ធវិធីប្រតិបត្តការ និងការប្រើប្រាស់អាវុធ ក្រោមអធិបតីភាព ឯកឧត្តម ឧត្តមសេនីយ៍ទោ ប៉ាក់ យូលាង ប្រធានស្តីទី នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន តំណាង លោកជំទាវនាយឧត្តមសេនីយ៍ យក់ សុខា អគ្គស្នងការរងនគរបាលជាតិ។

ឯកឧត្តម ឧត្តមសេនីយ៍ទោ ប៉ាក់ យូលាង ប្រធានស្តីទី នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន មានប្រសាសន៍ ក្នុពិធីបើកវគ្គបណ្តុះបណ្តាលថា ស្ថានភាពបទល្មើសពាក់ព័ន្ធការជួញដូរមនុស្ស និងអំពើអាជីវកម្មផ្លូវភេទលើស្ត្រី និងកុមារនៅកម្ពុជា នៅតែជាបញ្ហាដែលត្រូវយកចិត្តទុកដាក់រួមគ្នាដើម្បីប្រយុទ្ធប្រឆាំង ឆ្លងតាមកិច្ចសហប្រតិបត្តការណ៍រវាងនគរបាលជាតិកម្ពុជាជាមួយ និងអង្គការមេត្រីអន្តរជាតិ និងសេចក្តីអំណារអន្តរជាតិកន្លងមកទទួលបានលទ្ធផលជាច្រើនក្នុងការស៊ើបអង្កេត បង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទលើអនីតិជនជាបន្តបន្ទាប់។ ឯកឧត្តម បន្តទៀតថា លទ្ធផលទាំងនេះបញ្ជាក់អោយឃើញច្បាស់ពីការខិតខំប្រឹងប្រែងរបស់នគរបាលជាតិកម្ពុជាក្នុងការស្រាវជ្រាវស៊ើបអង្កេតបទល្មើសជួញដូរមនុស្ស និងអាជីវកម្មផ្លូវភេទលើស្ត្រី និងកុមារ។ ឯកឧត្តម ឧត្តមសេនីយ៍ទោ ប៉ាក់ យូលាង **បញ្ជាក់ថា "បើទោះបីជាកម្ពុជាទទួលបានសន្តិភាពពេញលេញ ហើយការប្រើប្រាស់អាវុធត្រូវបានកាត់បន្ថយយ៉ាងច្រើន ប៉ុន្តែចំពោះមន្ត្រីនគរបាលជំនាញដែលជាអ្នកអនុវត្តច្បាប់បាននិងកំពុងបំពេញភារកិច្ចក្នុងការបង្ក្រាបបទល្មើស ចាប់ជនសង្ស័យ និងសង្គ្រោះជនរងគ្រោះ ចាំបាច់ត្រូវតែមានការស្វែងយល់**

បន្ថែមនូវវិធីសាស្ត្រការពារខ្លួន និងការប្រើប្រាស់អាវុធពេលប្រតិបត្តការបង្ក្រាបបទល្មើស ក្នុងការចាប់ខ្លួនជនសង្ស័យ និងសង្គ្រោះជនរងគ្រោះប្រកបដោយសុវត្ថិភាព ព្រមទាំងការសង្គ្រោះបឋមពេលមានរបួសនៅកំឡុងពេលប្រតិបត្តិការនេះផងដែរ"។

គួរបញ្ជាក់ថា វគ្គបណ្តុះបណ្តាលរយៈពេល៥ថ្ងៃនេះ មានការចូលរួមពីសំណាក់អង្គការចំនួនពីរ គឺអង្គការមេត្រីអន្តរជាតិ (AIM SWAT) និងសេចក្តីអំណរអន្តរជាតិ (JOY INTERNATIONAL) ដែលមានគ្រូឧទ្ទេសនាមដែលមានបទពិសោធខ្ពស់មកពីសហរដ្ឋអាមេរិក និងមានគ្រូជំនួយជានគរបាលស្ត្រីចំនួន ០២រូប ព្រមទាំងមានការចូលរួមពីសិក្ខាកាមជា នាយ នាយរងនគរបាលពីតាមរាជធានី-ខេត្តចំនួន៧គឺៈ ភ្នំពេញ កំពត ពោធិសាត់ តាកែវ កំពង់ចាម កំពង់ឆ្នាំង និងកំពង់ស្ពឺ៕

## កម្ពុជា-វៀតណាម ចាត់វិធានម៉ឺងម៉ាត់ទប់ស្កាត់និងបង្ក្រាបបទល្មើសគ្រប់ប្រភេទនៅតាមព្រំដែន

http://information.gov.kh/ ចេញផ្សាយ ថ្ងៃទី 14 ខែ មករា ឆ្នាំ 2019 វិទ្យុជាតិកម្ពុជា៖

ដោយ ធីណា ឌីណេះ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃអះអាងថា នឹងបង្កើនវិធានការម៉ឺងម៉ាត់ ទប់ស្កាត់និងបង្ក្រាបបទល្មើសគ្រប់ប្រភេទនៅតាមច្រករបៀងព្រំដែនជាមួយប្រទេសជិតខាង ដើម្បីការពារសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ និងសុវត្ថិភាពសង្គម។ បន្ទាប់ពីបានដឹកនាំគណៈប្រតិភូអញ្ជើញចូលរួមក្នុងកិច្ចប្រជុំលើកទី១០ ស្តីពីកិច្ចសហប្រតិបត្តិការ និងការអភិវឌ្ឍជាប់ព្រំដែនកម្ពុជា-វៀតណាម កាលពីចុងសប្តាហ៍នេះ សម្តេច ក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ បានអះអាងថា ភាគីកម្ពុជានិងវៀតណាមបានប្តេជ្ញារួមគ្នាបង្កើនប្រសិទ្ធភាពបង្ក្រាបបទល្មើសឧក្រិដ្ឋកម្មឆ្លងដែន ដែលជាកង្វល់រួមនៃប្រទេសទាំង២។

សម្តេចក្រឡាហោមបានសង្កត់ធ្ងន់ថា ឆ្នាំ២០១៩នេះ ភាគីទាំង២និងបន្តអនុវត្តការងារសំខាន់ៗមួយចំនួនរួមមាន៖ បន្តទប់ស្កាត់ និងបង្ក្រាបបទល្មើសគ្រប់ប្រភេទនៅតាមច្រករបៀង និងតាមភូមិសាស្ត្រស្មុគស្មាញមួយចំនួន ជាពិសេសបទល្មើសគ្រឿងញៀន បទល្មើសព្រៃឈើ និងបទល្មើសធនធានធម្មជាតិផ្សេងៗ តាមបណ្តាខេត្តជាប់ព្រំដែន ដូចជា ខេត្តត្បូងឃ្មុំ ក្រចេះ រតនគិរី និងមណ្ឌលគិរី ។ បន្ថែមពីនេះទៀតជំរុញចាត់វិធានការតឹងរ៉ឹង ទប់ស្កាត់និងបង្ក្រាបការលួចឆ្លងដែនខុសច្បាប់ បន្តកិច្ចសហប្រតិបត្តិការគ្រប់គ្រងតាមខ្សែបន្ទាត់ព្រំដែន និងសហការដោះស្រាយបញ្ហាផ្សេងៗដោយ សន្តិវិធី ឈរលើគោល ការណ៍គោរពឯករាជ្យ និងអធិបតេយ្យភាពគ្នាទៅវិញទៅមក។

សូមបញ្ជាក់ថា សម្តេចក្រឡាហោមបានអញ្ជើញទៅបំពេញទស្សនកិច្ចផ្លូវការនៅប្រទេសវៀតណាម រយៈពេល ០៥ថ្ងៃ ចាប់ពីថ្ងៃទី០៩ ដល់ថ្ងៃទី១៣ ខែមករា ឆ្នាំ២០១៩ ដើម្បីចូលរួមកិច្ចប្រជុំថ្នាក់មន្ត្រីជាន់ខ្ពស់លើកទី១០ ស្តីពីកិច្ចសហប្រតិបត្តិការ និងការអភិវឌ្ឍ រវាងបណ្តាខេត្តជាប់ព្រំដែនកម្ពុជា-វៀតណាម នាទីក្រុងហូជីមិញ ប្រទេសវៀតណាម៕

## ក្រុមទីប្រឹក្សាទទួលបន្ទុកពលករប្រចាំប្រទេសថៃ បានចុះទៅជួយដោះស្រាយបញ្ហាជូនពលករ ករណីក្រុមហ៊ុនមិនបើកប្រាក់ឈ្នួលជូនពួកគាត់

https://www.facebook.com/ ទីប្រឹក្សាទទួលបន្ទុកពលករប្រចាំប្រទេសថៃ January 12 at 11:54 AM •

ខេត្តសមុទ្រប្រាកាន ប្រទេសថៃ៖ កាលពីថ្ងៃព្រហស្បតិ៍ ៥កើត ខែបុស្ស ឆ្នាំច សំរិទ្ធស័ក ព.ស ២៥៦២ ត្រូវនឹងថ្ងៃទី១០ ខែមករា ឆ្នាំ២០១៩ ក្រុមទីប្រឹក្សាទទួលបន្ទុកពលករប្រចាំប្រទេសថៃ សហការជាមួយមន្ត្រីការិយាល័យសុខមាលភាពនិងគាំពារពលករខេត្តសមុទ្រប្រាកាន បានចុះទៅជួបពលករខ្មែរ ចំនួនប្រហែល ៤០នាក់ នៅការដ្ឋានសំណង់មួយកន្លែងរបស់ក្រុមហ៊ុនសំណង់ Natural Thai Location Co.,Ltd ដែលស្ថិតនៅក្នុងស្រុកមឿងសមុទ្រប្រា

កាន ខេត្តសមុទ្រប្រាកាន ដើម្បីដោះស្រាយបញ្ហាជូនពលករករណីក្រុមហ៊ុនមិនបើកប្រាក់ឈ្នួលជូនពួកគាត់ អស់រយៈពេលជាង៤០ថ្ងៃមកហើយ ដោយទទួលបានលទ្ធផលដូចខាងក្រោម៖

-និយោជក យល់ព្រមឱ្យពលករចូលមកបម្រើការងារជាធម្មតាវិញ ហើយនិយោជកនឹងបើកប្រាក់ឈ្នួលជូនពលករ នៅថ្ងៃទី ១៦ ខែមករា ឆ្នាំ២០១៩។

- ពលករឯកភាពគ្នាយល់ព្រមចូលធ្វើការវិញជាធម្មតា និងឯកភាពរងចាំបើកប្រាក់ឈ្នួលនៅថ្ងៃទី ១៦ ខែមករា ឆ្នាំ២០១៩។

កិច្ចដោះស្រាយបញ្ហាការមិនបើកប្រាក់ឈ្នួលរបស់ពលករ ត្រូវបានបញ្ចប់ ដោយពលករមានសេចក្តីរីករាយអបអរសាទរ ចំពោះដំណោះស្រាយខាងលើ។

## ថ្ងៃទី១៥ ខែមករា ឆ្នាំ២០១៩

## អភិបាលខេត្តកំពង់ធំ៖ មន្ត្រីទាំងអស់ត្រូវខិតខំទប់ស្កាត់ជួញដូរមនុស្សឱ្យបាន ដើម្បីកុំឱ្យក្រុមហ៊ុនទុច្ចរិតអាចឆ្លៀតឱកាសបានបន្តទៀត

http://www.freshnewsasia.com/ 2019-01-14

**(កំពង់ធំ)៖** លោក សុខ លូ អភិបាលខេត្តកំពង់ធំ និងជាប្រធានគណៈកម្មាធិការប្រយុទ្ធប្រឆាំងជួញដូរមនុស្សខេត្ត បានថ្លែងជម្រុញឱ្យមន្ត្រីទាំងអស់ ក៏ដូចជា ដៃគូពាក់ព័ន្ធត្រូវខិតខំបង្ការ ទប់ស្កាត់តាមរយៈការអប់រំផ្សព្វផ្សាយ គ្រប់រូបភាព គ្រប់ទីកន្លែង និងតាមគ្រប់មធ្យោបាយធ្វើយ៉ាងណាក៏ដោយ កុំឱ្យមានក្រុមទុច្ចរិតអាចបោកប្រាស់ ប្រជាពលរដ្ឋឲ្យលង់ខ្លួនខាតបង់លុយកាក់ នឹងធ្លាក់ខ្លួនជាជនរងគ្រោះបានបន្តទៀត។ លោក សុខ លូ បានថ្លែងយ៉ាងដូចនេះ នាថ្ងៃទី១៤ ខែមករា ឆ្នាំ២០១៩ ក្នុងឱកាសដែលលោកអញ្ជើញជាអធិបតី ចូលរួមប្រារព្ធពិធីអបអរសាទរប្រយុទ្ធប្រឆាំង ការជួញដូរមនុស្ស ក្នុងទិវាជាតិលើកទី១២ ដែលពិធីនោះក៏មានការអញ្ជើញចូលរួម ពីប្រធានអង្គភាពមន្ទីរជុំវិញខេត្ត អាជ្ញាធរក្រុង ស្រុក កងកម្លាំងប្រដាប់អាវុធ សិស្សានុសិស្សជាង៤០០នាក់។

លោកស្រី លំ គន្ធារី អភិបាលរងខេត្ត និងជាប្រធានលេខាធិការដ្ឋាន ប្រយុទ្ធប្រឆាំងជួញដូរមនុស្ស បានធ្វើរបាយការណ៍សង្ខេប ពីគោលបំណងគឺចង់ឲ្យឃើញថា រាជរដ្ឋាភិបាលនៃកម្ពុជា នៅតែបន្តយកចិត្តទុកដាក់កាន់តែខ្លាំងក្លា ក្នុងការការពារប្រជាពលរដ្ឋ និងប្រទេសជាតិ ដែលមានភាពរងគ្រោះទាំងឡាយ ដោយឧក្រិដ្ឋកម្មជួញដូរមនុស្ស ដែលបានបង្កឱ្យមានវិនាសសកម្មសារជាថ្មី ដល់មនុស្សជាតិហើយបាន និងកំពុងក្លាយជាទាសភាព សម័យទំនើបគួរឲ្យភ័យខ្លា និងស្អប់ខ្ពើម។ សភាពការណ៍បទល្មើសកើតឡើង ៣០លើក គឺករណីប៉ុនប៉ងរំលោភសេពសន្ថវៈ៥ លើករណីអំពើហិង្សាក្នុងគ្រួសារ១៨ លើកករណីអំពើហិង្សា ប្រព្រឹត្តដោយសហព័ន្ធ ឬអនីតិសង្វាសជនចំនួន ៣លើក នឹងករណីរំលោភសេពសន្ថវៈចំនួន៥លើក។

លោក សុខ លូ បានលើកឡើងថា រដ្ឋាភិបាលក៏ដូចជាដៃគូពាក់ព័ន្ធបានខិតខំបង្ការ ទប់ស្កាត់តាមរយៈការអប់រំផ្សព្វផ្សាយ គ្រប់រូបភាព គ្រប់ទីកន្លែងតាមគ្រប់មធ្យោបាយយ៉ាងណាក៏ដោយ ក៏នៅមានក្រុមទុច្ចរិតមួយចំនួន ដែលនៅតែអាចបោកប្រាស់ ប្រជាពលរដ្ឋឲ្យលង់ខ្លួនខាតបង់លុយកាក់ នឹងធ្លាក់ខ្លួនជារងគ្រោះបាន។ ដូច្នេះក្នុងការបង្ការទប់ស្កាត់ ទាមទារឲ្យមានការបង្កើតជាជម្រើស សម្រាប់ការរស់នៅរបស់គ្រួសារបន្ថែមទៀត និងតាមដានសកម្មភាពក្រុមហ៊ុនទុច្ចរិតមួយចំនួន ដែលមិនមានការទទួលខុសត្រូវ ឲ្យប្រឈមមុខជាមួយច្បាប់ឱ្យបាន។ លោកបានបន្ថែមថា អំពើជួញដូរមនុស្ស អំពើធ្វើអាជីវកម្មលើមនុស្ស អំពើហិង្សាផ្លូវភេទលើស្ត្រី និងកុមារអំពើហិង្សាក្នុងគ្រួសារ បញ្ហាគ្រឿងញៀន និងបទល្មើសមួយចំនួន ទោះបីជាត្រូវបានទប់ស្កាត់ បង្ក្រាបជាបន្តបន្ទាប់យ៉ាងណាក៏ដោយ ក៏បញ្ហាទាំងអស់នេះ នៅតែកើតមានជាហូរហែរ និងតាមរូបភាពប្លែកៗ ដែលបង្កើតជាកង្វល់របស់រាជរដ្ឋាភិបាល អាជ្ញាធរគ្រប់លំដាប់ថ្នាក់ និងប្រជាពលរដ្ឋគ្រប់ទីកន្លែងផងដែរ ដូចនេះហើយមន្ត្រីទាំងអស់ ក៏ដូចជាដៃគូពាក់ព័ន្ធត្រូវខិតខំបង្ការ ទប់ស្កាត់

តាមរយៈការអប់រំផ្សព្វផ្សាយ គ្រប់រូបភាព គ្រប់ទីកន្លែង និងតាមគ្រប់មធ្យោបាយ ធ្វើយ៉ាងណាក៏ដោយ កុំឱ្យមានក្រុមទុច្ចរិតអាចបោកប្រាស់ ប្រជាពលរដ្ឋឲ្យលង់ខ្លួនខាតបង់លុយកាក់ នឹងធ្លាក់ខ្លួនជាជនរងគ្រោះបានបន្តទៀត។

លោក សុខ លូ ក៏បានកោតសរសើរ ចំពោះគ្រប់កិច្ចខិតខំប្រឹងប្រែងរបស់ថ្នាក់ដឹកនាំក្រុង ស្រុក មន្ទីរអង្គភាព និងមន្រ្តីរាជការ អង្គការមិនមែនរដ្ឋាភិបាលក្នុងខេត្ត និងអន្តរជាតិ ព្រមទាំងវិស័យឯកជនទាំងឡាយ ដែលតែងបានប្រឹងប្រែងរួមគ្នា ដោះស្រាយបញ្ហាចំពោះមុខដោយមិនខ្លាចនឿយហត់ ប្រឆាំងដាច់ខាតទៅនឹងសកម្មភាព របស់ប្រជាជន ស្របទៅតាមទិសដៅនៃគោលនយោបាយរាជរដ្ឋាភិបាល។ ប្រសិនបើមិនមានការខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាល និងមន្រ្តីយើងយ៉ាងសកម្មនោះទេ អំពើជួញដូរមនុស្ស អំពើកេងប្រវ័ញ្ចរំលោភបំពាននោះ និងរីករាលដាលច្រើនឡើងៗ រីឯប្រជាពលរដ្ឋជាច្រើនកាន់ តែប្រឈមនឹងគ្រោះអន្តរាយ ហើយសង្គមជាតិនឹងមិនមានស្ថិរភាពនោះទេ៕

## ម្ដាយស្គាល់គ្នានិងគេ ខំផ្ញើកូនស្រីឲ្យទៅធ្វើការនៅថៃ ជួយគ្រួសារ ដូចផ្ញើកូនស្រីទៅឲ្យជនថោកទាប រំលោភអញ្ចើង

https://khmer.social/social/ Pheak Tra January 15, 2019

បន្ទាយមានជ័យៈ ថ្ងៃទី១៤ ខែមករា ឆ្នាំ២០១៩ វេលាម៉ោង ១១ និង ៥០នាទី កម្លាំងជំនាញការិយាល័យបទល្មើសជួញដូរមនុស្ស ដឹកនាំដោយលោកវរសេនីយ៍ទោ ព្រហ្ម ថេង ប្រធានមន្ទីរយុត្តិធម៌ បានចុះប្រតិបត្តិការបង្ក្រាបករណី រំលោភសេពសន្ថវៈ ប្រព្រឹត្តកាលពីអំឡុងខែធ្នូ ឆ្នាំ២០១៨ នៅចំណុចទឹកដីប្រទេសថៃ និងឃាត់ខ្លួនជនសង្ស័យបានចំនួន ០១នាក់ ។ លោកវរសេនីយ៍ទោ ព្រហ្ម ថេង បានអោយដឹងថា ៖ យោងពាក្យបណ្ដឹងរបស់ឈ្មោះ ថ.ជ (ត្រូវជាម្ដាយរបស់ជនរងគ្រោះ) ភេទ ស្រី អាយុ៥៣ឆ្នាំ បច្ចុប្បន្នរស់នៅភូមិខ្លាងាប់ ឃុំទួលពង្រ ស្រុកម៉ាឡៃ ខេត្តបន្ទាយមានជ័យ និងដោយអនុវត្តន៍ទៅតាមដីកាបញ្ជាឲ្យចូលខ្លួនលេខ ០៥អ.យ.ខ របស់លោក តេង សាម៉ៃ ព្រះរាជអាជ្ញារងអមសាលាដំបូងខេត្ត លោកបានដឹកនាំកម្លាំងការិយាល័យប្រឆាំងបទល្មើសជួញដូរមនុស្ស ចុះប្រតិបត្តិការបង្ក្រាបករណីខាងលើ រហូតឃាត់ខ្លួនជនសង្ស័យ បានចំនួន ០១នាក់ ឈ្មោះ អែល អ៊ឹម ភេទ ប្រុស អាយុ ៥៦ឆ្នាំ ជនជាតិខ្មែរ បច្ចុប្បន្នរស់នៅភូមិ/ឃុំកើតហេតុខាងលើ ។

តាមការបំភ្លឺរបស់ជនរងគ្រោះ ឈ្មោះ ថ.ស.ជ ភេទ ស្រី អាយុ១៨ឆ្នាំ បានបញ្ជាក់ឲ្យដឹងថា ៖ ម្ដាយរបស់ខ្លួនជាអ្នកធ្វើការនៅថៃ បម្រើការងារនៅតាមផ្ទះ (ផ្ទះរបស់ជនសង្ស័យ) ដោយមើលឃើញការងារអាចរកថវិកាបានសមល្មម ម្ដាយខ្លួនបានសុំជនសង្ស័យខាងលើ យកខ្លួនទៅធ្វើការងារជាមួយដែរ (គោលបំណងកន្លែងផ្សេង) លុះចូលដល់ទឹកដីថៃ ខ្លួនក៏ត្រូវជនសង្ស័យអោយស្នាក់នៅកន្លែងមួយដែលជនសង្ស័យជាអ្នករៀបចំជាមួយនិងប្រពន្ធរបស់ជនសង្ស័យ តែពេលដែលប្រពន្ធជនសង្ស័យបានចូលបន្ទប់ទឹក ស្រាប់តែជនសង្ស័យបានមករកខ្លួនពេលកំពុងដេកលក់ ពេលដឹងខ្លួនបានដឹងថាជនសង្ស័យដេកពបពីលើខ្លួនហើយខ្លួនបានរើបម្រះរួច រត់ទៅឲ្យប្រពន្ធជនសង្ស័យជួយ លុះដល់យប់បន្ទាប់ពេលខ្លួនកំពុងដេកលក់ ជនសង្ស័យបានចាប់រំលោភខ្លួនរហូតបានសម្រេច ០១លើក និងបានគម្រាមថាបើប្រាប់អ្នកទីបីឲ្យដឹងជនសង្ស័យនឹងធ្វើបាបមិនឲ្យរួចខ្លួនឡើយ និងបានរំលោភមកលើខ្លួនជាបន្តបន្ទាប់រហូតសម្រេចបាន ០៤លើក ដោយមានការភ័យខ្លាច ខ្លួនក៏យកឥវ៉ាន់រត់ចេញពីកន្លែងរបស់ជនសង្ស័យទៅរស់នៅកន្លែងផ្សេង ។

លោកវរសេនីយ៍ឯក ម៉ែន ភិរម្យ មេបញ្ជាការរងកងរាជអាវុធហត្ថខេត្ត ទទួលការងារយុត្តិធម៌ បានបញ្ជាក់បន្ថែមថា ៖ បន្ទាប់ពីធ្វើការសាកសួរ ជនសង្ស័យបានសារភាពថា ៖ ខ្លួនពិតជាបាននាំជនរងគ្រោះទៅធ្វើការនៅប្រទេសថៃ និងបានស្នាក់នៅជាមួយគ្នាចំនួន ០៤ថ្ងៃ ដោយឃើញជនរងគ្រោះនៅក្មេង និងស្រស់ស្អាតខ្លួនទ្រាំមិនបានក៏ចាប់ផ្ដុំរំលោភនាង ដោយគិតថានៅប្រទេសថៃមិនអាចមានបញ្ហាអ្វីនោះទេ ។ ផ្អែកលើចម្លើយសារភាពរបស់ជនសង្ស័យ យោងតាមពាក្យបណ្ដឹង និងតាមការបំភ្លឺរបស់ជនរងគ្រោះ ឃើញមានតម្រុយពិរុទ្ធភាពនៃបទល្មើសជាក់លាក់ជនសង្ស័យខាងលើ ពិតជាបានប្រព្រឹត្តបទល្មើស រំលោភសេពសន្ថវៈ យ៉ាងពិតប្រាកដ កម្លាំងជំនាញកងរាជអាវុធហត្ថ

ខេត្ត បានកសាងសំណុំរឿងបញ្ជូនជនសង្ស័យ ទៅតុលាការ ដើម្បីចាត់ការទៅតាមនីតិវិធី ។ ប្រភព៖ បញ្ជាការដ្ឋានកងរាជអាវុធហត្ថ ខេត្តបន្ទាយមានជ័យ

## អង្គភាពប្រយុទ្ធប្រឆាំងការជួញដូរមនុស្សនិងទាហ៊ានថៃបានចាប់ខ្លួនថៅកែថៃក្នុងករណីប្រើដែកវ៉ែធ្វើបាបពលករខ្មែររួចហើយហែកប៉ាស្ព័រពលករខ្មែរចោល

https://www.facebook.com/ ទឹកចិត្ត ពលករ ឆ្លងដែន is with Tan Tan. 14-01-2019

ទីប្រឹក្សាទទួលបន្ទុកពលករប្រចាំស្ថានទូតខ្មែរ ប្រចាំប្រទេសថៃ បានសហការជាមួយស្នងការដ្ឋាននគរបាលខេត្តប៉ាធុមថានី នៅប្រទេសថៃ និងអង្គភាពប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស និងទាហ៊ានថៃ និងមន្ត្រីការងារខេត្តប៉ាធុមថានី និងនគរបាលអន្តោប្រវេសន៍នៅខេត្តប៉ាធុមថានី បានចុះទៅចាប់ខ្លួនថៅកែថៃក្នុងករណីថៅកែថៃប្រើដែកវ៉ែធ្វើបាបពលករខ្មែររួចហើយហែកប៉ាស្ព័រពលករខ្មែរចោល និងអន្តរាគមន៍រំដោះពលករខ្មែរមួយក្រុមធ្វើការលក់ផ្លែឈើបន្ទាប់ពីត្រូវថៅកែប្រើអំពើហឹង្សាវាយដំមកលើពលករជាច្រើនលើក។

# ថ្ងៃទី១៦ ខែមករា ឆ្នាំ២០១៩

## មេតូមិភាគ ៥ខ្មែរ និងមេការពារព្រំដែនច័ន្ទបូរី-ត្រាតថៃសន្យារឹតបន្តឹងបទល្មើសតាមព្រំដែនប្រទេសទាំងពីរឲ្យកាន់តែប្រសើរ

http://bayontv.com.kh/ 15/01/2019

បាត់ដំបង៖ ឧត្តមសេនីយ៍ឯក ប៊ុន សេង មេបញ្ជាការរងកងទ័ពជើងគោក និងជាមេបញ្ជាការយោធភូមិភាគទី ៥ និងលោកឧត្តមនាវីត្រី បាំរ៉ុងរ៉ាក់ សះកាវ៉ាត់កាណុន មេបញ្ជាការរងកងកម្លាំងការពារព្រំដែនថៃច័ន្ទបូរី-ត្រាតបានសន្យារួមគ្នាថានឹងរឹតបន្តឹង និងទប់ស្កាត់បទល្មើសនៅតាមព្រំដែននៃប្រទេសទាំងពីរ ឲ្យកាន់តែមានប្រសិទ្ធភាពបន្ថែមទៀតជាពិសេសគ្រឿងញៀន និងការនាំចូលនូវរថយន្តចង្កូតស្តាំតែម្តង។

ការអះអាងរបស់ភាគីទាំងពីរនេះ គឺបានធ្វើឡើងនៅព្រឹកថ្ងៃទី១៥ ខែមករា ឆ្នាំ២០១៩ នេះនៅលើទឹកដីយោធភូមិភាគ៥ ខេត្តបាត់ដំបង នៅក្នុងកិច្ចប្រជុំថ្នាក់យោធភូមិភាគនៃប្រទេសទាំងពីរ។ នៅក្នុងកិច្ចប្រជុំភាគីទាំងពីរបានសម្តែងការស្វាគមន៍ នូវកិច្ចសហប្រតិបត្តិការដ៏ល្អប្រសើររវាងយោធភូមិភាគទី៥ និងកងកម្លាំងការពារព្រំដែនច័ន្ទបូរី-ត្រាត ក៏ដូចជាចំណងមេត្រីភាពមិត្តភាពកិច្ចសហប្រតិបត្តិការល្អ លើគ្រប់វិស័យរវាងកងយោធពលខេមរភូមិន្ទ និងកងទ័ពភូមិន្ទថៃ ដូចអ្វីដែលថ្នាក់ដឹកនាំនៃប្រទេសទាំងពីរចង់បាន។ នៅក្នុងកិច្ចប្រជុំនេះភាគីទាំងពីរបានអះអាងរួមគ្នាថា «ត្រូវតែខិតខំការពារ និងទប់ស្កាត់នូវបទល្មើសតាមព្រំដែន ដូចជាការឆ្លងដែនខុសច្បាប់, ការជួញដូរគ្រឿងញៀន, ការនាំចូលនូវរថយន្តចង្កូតស្តាំ, ប្រឆាំងភេរវកម្ម និងបទល្មើសផ្សេងៗជាច្រើនទៀតឲ្យកាន់តែមានប្រសិទ្ធភាពបំផុត ដើម្បីឲ្យស្របទៅតាមសុឆន្ទៈរបស់រាជរដ្ឋាភិបាលនៃប្រទេសទាំងពីរ ដែលចង់ឃើញនូវព្រំដែនមួយប្រកបដោយសន្តិភាព ស្ថិរភាព មិត្តភាព សហប្រតិបត្តិការ និងការអភិវឌ្ឍដ៏ប្រសើរនោះ»។

នៅក្នុងកិច្ចប្រជុំនោះដែរភាគីទាំងពីរ ក៏បានសន្យានឹងខិតខំធ្វើយ៉ាងណា ដើរតាមការណែនាំរបស់ថ្នាក់ដឹកនាំនៃប្រទេសទាំងពីរ ដែលជំរុញឲ្យកងទ័ពតាមក្រវាត់ព្រំដែនកម្ពុជា-ថៃជួបប្រាស្រ័យគ្នាឲ្យបានញឹកញាប់ ក្នុងគោលបំណងបង្កើនមិត្តភាពស្និតស្នាល តាមរយៈលេងនូវកីឡារួមគ្នា និងជួបពិភាក្សាគ្នាជាដើមនោះ៕

## ស្ត្រីម្នាក់សុំឧទ្ធរណ៍បន្ថយទោស រឿងបើកម៉ាស្សាបង្កប់សេវាផ្លូវភេទ

https://www.postkhmer.com/ គឹម សារុំ | Publication date 16 January 2019 | 09:41 ICT

**ភ្នំពេញ៖** ស្ត្រីជាប់ចោទម្នាក់កាលពីម្សិលមិញបានទទួចសុំដល់ចៅក្រមនៅសាលាឧទ្ធរណ៍ឲ្យបន្ថយទោសដល់ខ្លួនពាក់ព័ន្ធករណីបើកហាងម៉ាស្សាបង្កប់សេវាបម្រើផ្លូវភេទ ប្រព្រឹត្តកាលពីឆ្នាំ ២០១៥ នៅសង្កាត់ទួលសង្កែ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ខណៈសំណុំរឿងនេះត្រូវតុលាការថ្នាក់ក្រោមផ្តន្ទាទោសដាក់ពន្ធនាគារ ៦ ឆ្នាំ។ តាម

កំណត់ហេតុរបស់តុលាការបង្ហាញថា ស្ត្រីជាប់ចោទឈ្មោះ លឹម ណៃអន អាយុ ៣៨ ឆ្នាំបានបើកកន្លែង ម៉ាស្សាកោសជប់ ១ កន្លែង មានឃីហោ ៩៩៩ ស្ថិតនៅក្នុងភូមិសង្កាត់ទួលសង្កែ ខណ្ឌឬស្សីកែវ រាជធានីភ្នំពេញហើយត្រូវបាននគរបាលនៃការិយាល័យប្រឆាំងការជួញដូរមនុស្សរាជធានីភ្នំពេញចុះបង្ក្រាបបានកាលពីរសៀលថ្ងៃទី ១០ ខែវិច្ឆិកា ឆ្នាំ ២០១៥។ កំណត់ហេតុបន្តថា ក្នុងប្រតិបត្តិការនោះសមត្ថកិច្ចឃាត់ខ្លួនបាននារីម៉ាស្សាកោសជប់សរុប ៥ នាក់ប៉ុន្តែក្រោយមកសមត្ថកិច្ចបានដោះលែង ៤ នាក់វិញ ដោយឃាត់ខ្លួនទុកតែស្ត្រីជាម្ចាស់ហាងម្នាក់ប៉ុណ្ណោះ។ ទន្ទឹមនឹងនោះសមត្ថកិច្ចបានឆែកឆេរក្នុងហាងម៉ាស្សាហើយរកឃើញស្រោមអនាម័យទាំងប្រើរួចនិងមិនទាន់ប្រើមួយចំនួន។

កាលពីនៅដំណាក់កាលនគរបាលយុត្តិធម៌ ស្ត្រីជាប់ចោទឈ្មោះ លឹម ណៃអន រូបនេះ បានប្រាប់សមត្ថកិច្ចថាគាត់បាន បើកកន្លែងម៉ាស្សាកោសជប់ពិតមែន ក៏ប៉ុន្តែគាត់មិនបានបើក បម្រើសេវាផ្លូវភេទទេ។ ប៉ុន្តែអាចកូនចៅរបស់គាត់លួចប្រើប្រាស់សេវានេះព្រោះពួកគេធ្លាប់ ឲ្យកម្រៃដល់គាត់ម្នាក់ ១ ម៉ឺនរៀល ក្រោយពីបម្រើសេវាផ្លូវភេទជាមួយភ្ញៀវរួច។ ប៉ុន្តែពេលខ្លះពួកគេ (នារីម៉ាស្សា) ក៏លួចទៅរួមភេទ ជាមួយភ្ញៀវនៅខាងក្រៅដែរ។ សំណុំរឿងនេះត្រូវសាលាដំបូងបើកសវនាការកាលពីថ្ងៃទី ២០ ខែមីនា ឆ្នាំ ២០១៦ និងប្រកាសសាលក្រមនៅថ្ងៃទី ២៧ ខែឆ្នាំដដែលដោយផ្តន្ទាទោសស្ត្រីជាប់ចោទដាក់ពន្ធនាគារ ៦ ឆ្នាំចោទពីបទសញ្ជារកម្មមានស្ថានទម្ងន់ទោសដោយទាក់ទងនឹងចារីតាមបញ្ញត្តិមាត្រា ២៧ ច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្សនិងធ្វើអាជីវកម្មផ្លូវភេទនិងមាត្រា ២៨៨ នៃក្រមព្រហ្មទណ្ឌ។

នៅក្នុងបន្ទប់សវនាការកាលពីម្សិលមិញស្ត្រីជាប់ចោទ លឹម ណៃអន បានប្រាប់ចៅក្រមថា៖ «ខ្ញុំប្តឹងមកសាលាឧទ្ធរណ៍ពេល នេះដោយសារខ្ញុំចង់ឲ្យសាលាឧទ្ធរណ៍បន្ថយទោសដល់ខ្ញុំព្រោះ ខ្ញុំមានកូនតូចនៅក្នុងបន្ទុក ៣ នាក់គ្មានអ្នកថែទាំហើយពួកគេ មិនបានរៀនសូត្របានត្រឹមត្រូវទេ។ ម្យ៉ាងម្តាយខ្ញុំចាស់ជរាហើយ។ ខ្ញុំដឹងថា ខ្ញុំមានកំហុស»។

លោកព្រះរាជអាជ្ញា ជុំ សែនសទ្ធា តំណាងមហាអយ្យការសន្និដ្ឋានថា៖ «ស្ត្រីជាប់ចោទបានទទួលស្គាល់កំហុសហើយការប្តឹងមកឧទ្ធរណ៍ដោយសារគាត់ចង់សុំតុលាការបន្ថយទោសដល់គាត់។ ប៉ុន្តែខ្ញុំសូមតម្កល់សាលក្រមរបស់សាលាដំបូងរាជធានីភ្នំពេញដដែល ហើយចំពោះការស្នើសុំបន្ថយទោសរបស់ជនជាប់ចោទសូមក្រុមប្រឹក្សាពិចារណាតាមច្បាប់ចុះ»។

ទោះយ៉ាងណា លោក លី វីរៈ មេធាវីការពារសិទ្ធិឲ្យស្ត្រីជាប់ចោទសន្និដ្ឋានថា ពាក់ព័ន្ធអំពើសញ្ជារកម្មនេះ គឺកូនក្តីលោកមិនបានដឹងថានារីម៉ាស្សាទាំងនោះលួចទៅបម្រើសេវារួមភេទទេហើយកូនក្តីរបស់លោកក៏គ្មានចេតនាក្នុងរឿងនេះដែរ។ លោកបញ្ជាក់ប្រាប់ចៅក្រមថា៖ «ហាងរបស់កូនក្តីខ្ញុំគ្រាន់តែបើកបម្រើម៉ាស្សាកោសជប់ទេតែនារីម៉ាស្សាបានលួចបម្រើសេវាផ្លូវភេទ។ ម្យ៉ាងកូនក្តីខ្ញុំមានកូនតូចដែលត្រូវការម្តាយមើលថែទាំនិងម្តាយចាស់ដូច្នេះសូមក្រុមប្រឹក្សាជំនុំជម្រះមេត្តាសម្រេចតាមការស្នើសុំរបស់កូនក្តីខ្ញុំផង»។

បន្ទាប់ពីជំនុំជម្រះ លោកស្រី ចាន់ ម៉ាឌីណា ប្រធានក្រុមប្រឹក្សាជំនុំជម្រះ បានថ្លែងថា សាលដីកានៃសំណុំរឿងនេះ នឹងប្រកាសនៅថ្ងៃទី ២៨ ខែមករា ខាងមុខ៕

## ស្ត្រីបម្រើការងារតាមផ្ទះ ទទួលប្រាក់ខែមិនសូវច្រើន តែជួបបញ្ហាប្រឈមច្រើន

https://thmeythmey.com/ 16, Jan 2019 , 8:59 am

ភ្នំពេញ៖ ស្ត្រីបម្រើការងារតាមផ្ទះ ងាយនឹងប្រឈមការទទួលរងនូវអំពើហិង្សា និងការបៀតបៀនផ្លូវកាយ និងផ្លូវចិត្ត ពីផ្ទះម្ចាស់។ បើតាមការបញ្ជាក់របស់ អ្នកស្រី យឹម សុធី ប្រធានសមាគមអ្នកបម្រើការងារតាមផ្ទះ។ អ្នកស្រី យឹម សុធី បញ្ជាក់ទៀតថា ស្ត្រីដែលងាយនឹងទទួលរងការបៀតបៀនផ្លូវភេទ ភាគច្រើនជាស្ត្រីទន់ខ្សោយដែលខ្វះការអប់រំ និងខ្វះការអនុវត្តច្បាប់ការពារស្ត្រីនៅម៉ោងការងារ។ តាមរយៈកម្មវិធី «ស្ត្រីកម្ពុជា គាំទ្រសន្តិភាព និងការបញ្ឈប់សង្គ្រាម» ដែលរៀបចំដោយ គណៈកម្មាធិការនារីអន្តរជាតិដើម្បីសន្តិភាព(IWPG) អ្នកស្រី យឹម សុធី ប្រធាន

សមាគមអ្នកបម្រើការងារតាមផ្ទះ មានក្តីព្រួយបារម្ភ ចំពោះស្ត្រីដែលបម្រើការងារតាមផ្ទះដែលជួបបញ្ហាផ្សេងៗ ដូចជាស្ត្រីត្រូវបានគេបៀតបៀនផ្លូវភេទ រំលោភសិទ្ធិម៉ោងការងារ និងស្ត្រីដែលទទួលរងការចោទប្រកាន់ពីម្ចាស់ផ្ទះ។ បញ្ហាទាំងនេះ អ្នកស្រី នឹងព្យាយាមដោះស្រាយបន្ថែមទៀត ដើម្បីធ្វើយ៉ាងណា ឲ្យស្ត្រីទាំងនោះ រួមគ្នាចេះតវ៉ារកយុត្តិធម៌ ដើម្បីលុបបំបាត់ការរំលោភបំពានផ្លូវកាយ និងផ្លូវចិត្ត។ អ្នកស្រី បានអះអាងថា ប្រសិនស្ត្រីបម្រើការងារតាមផ្ទះ មានបញ្ហាផ្សេងៗពីម្ចាស់ផ្ទះ ឬតាមកន្លែងការងារ ខាងអង្គការសមាគមអ្នកបម្រើការងារតាមផ្ទះរបស់ខ្លួន នឹងមានវិធានការដោះស្រាយរវាងនិយោជក និងនិយោជិតដោយសន្តិវិធី។ អ្នកស្រី យឹម សុធី ប្រាប់ថា៖«ស្ត្រីជួបបញ្ហាធ្ងន់ធ្ងរជាមួយនិយោជក យើងក៏មានការការពារពួកគាត់ ដោយដោះស្រាយតាមច្បាប់ផងដែរ។ លើសពីនេះ យើងនឹងធ្វើការជាមួយដៃគូពាក់ព័ន្ធ ដើម្បីផ្សព្វផ្សាយពីបញ្ហាផ្សេងៗដែលកើតមានឡើងចំពោះស្ត្រី ធ្វើយ៉ាងណា ឲ្យស្ត្រីបានយល់ដឹងពីការការពារខ្លួន មុននឹងទៅបម្រើការងារតាមផ្ទះ និងចេះដោះស្រាយបញ្ហាជាមួយម្ចាស់ផ្ទះខ្លួនឯងផងដែរ»។ ប្រធានសមាគមអ្នកបម្រើការងារតាមផ្ទះរូបនេះបន្ថែមថា ស្ត្រីដែលបម្រើការងារតាមផ្ទះ មានប្រមាណជាង៦០០នាក់ បានសហការជាមួយសមាគមអ្នកបម្រើការងារតាមផ្ទះ ហើយពួកគេទទួលបានប្រាក់ខែគោល ចាប់ពី១៥០ ដល់១៧០ ដុល្លារក្នុងមួយខែ។

ថ្វីដ្បិតស្ត្រីទទួលបានប្រាក់ខែគោលជិត២០០ដុល្លារ និងមានកន្លែងស្នាក់នៅ និងការហូបចុកល្អ ពិតមែន ប៉ុន្តែស្ត្រីដែលមានអាយុចន្លោះ៣០ឆ្នាំ នៅមិនទាន់ទទួលបានសិទ្ធិការពារខ្លួននៅឡើយទេ។«ទោះបីច្បាប់ទើបតែចេញមែន ប៉ុន្តែការអនុវត្តច្បាប់នៅមិនទាន់មានប្រសិទ្ធភាពនៅឡើយទេ។ ពួកគេនៅតែទទួលបានការមាក់ងាយ និងការស្តីបន្ទោសពីម្ចាស់ផ្ទះដដែល»។ នេះការលើកឡើងរបស់អ្នកស្រី យឹម សុធី ជាមួយនឹងការស្នើឲ្យរាជរដ្ឋាភិបាលផ្តល់សច្ចាប័នលើអនុសញ្ញា ស្តីពីច្បាប់អន្តរជាតិ ដើម្បីការពារស្ត្រីឲ្យមានសន្តិភាព និងសុខសុវត្ថិភាពស្ត្រីក្នុងម៉ោងការងារ។

ស្ត្រីដែលបម្រើការងារតាមផ្ទះទូទាំងរាជធានី-ខេត្ត មានជាង២៥ម៉ឺននាក់។ ស្ត្រីទាំងនោះធ្វើការជាស្ត្រីមើលថែកូន បោសសំអាតផ្ទះ បោកសម្លៀកបំពាក់ ធ្វើម្ហូប លាងចានជាដើម។ ខេត្តដែលមានស្ត្រីបម្រើការងារតាមផ្ទះច្រើនជាងគេ គឺខេត្តពោធិ៍សាត់ កំពង់ធំ និងក្រចេះ ហើយពួកគេមានអាយុចាប់ពី១៨ឆ្នាំ ដល់៥០ឆ្នាំ។ ស្ត្រីមួយចំនួនទៀត ក៏បានចំណាកស្រុកទៅក្រៅប្រទេស ធ្វើការជាអ្នកបម្រើតាមផ្ទះផងដែរ។

ជាមួយគ្នាផងដែរ រដ្ឋាភិបាល បានចាត់ទុកការងារបម្រើតាមផ្ទះ ជាការងារគ្មានថ្ងៃឈប់សម្រាកដូចនឹងការងារផ្សេងៗនោះទេ។ រដ្ឋាភិបាល ក៏បានស្នើឲ្យម្ចាស់ផ្ទះទាំងអស់ ផ្តល់ប្រាក់បៀវត្សឲ្យបានខ្ពស់ ដល់អ្នពួកគេ ដើម្បីឲ្យពួកគេមានលទ្ធភាពគ្រប់គ្រាន់ សម្រាប់យកទៅផ្គត់ផ្គង់ជីវភាពគ្រួសារ ។ ប្រមុខរដ្ឋាភិបាល ក៏កំពុងរកដំណោះស្រាយលើបញ្ហាកម្មករក្នុងប្រព័ន្ធ និងក្រៅប្រព័ន្ធនេះផងដែរ៕

**ឃាត់ខ្លួនពលរដ្ឋខ្មែរម្នាក់ពីបទក្លែងផាកប័ណ្ណព្រំដែនកម្ពុជា-ថៃ**( BORDERPASS )

https://www.facebook.com/CambodiaLabour/ ព័ត៌មានពលករខ្មែរ 16-01-2019

កាលពីថ្ងៃចន្ទ ទី១៤ ខែមករា ឆ្នាំ២០១៩ កន្លងទៅ កម្លាំងសមត្ថកិច្ចអន្តោប្រវេសន៍ថៃ ប្រចាំច្រកទ្វារព្រំដែនអន្តរជាតិខ្លងឡឹក ស្រុក អារញ្ញ ខេត្តស្រះកែវ ប្រទេសថៃ ឃាត់ខ្លួនពលរដ្ឋខ្មែរម្នាក់ ឈ្មោះ សុខ សរ អាយុ ៤០ឆ្នាំ ពីបទក្លែងបន្លំឯកសារប័ណ្ណព្រំដែនកម្ពុជា - ថៃ (CAMBODIA-THAILAND BORDERPASS) តាមការសួររបស់សមត្ថកិច្ច ពលរដ្ឋខ្មែររូបនោះបានប្រាប់អោយដឹងថាប័ណ្ណព្រំដែនកម្ពុជា-ថៃ (BORDERPASS) នេះគាត់បានជួល អ្នករត់ការធ្វើនៅក្នុងក្រុងប៉ោយប៉ែតក្នុងតម្លៃ 1800បាត ដោយមិនដឹងថាជា BORDERPASS ក្លែងក្លាយ ។ បច្ចុប្បន្នពលរដ្ឋខ្មែររូបនោះត្រូវសមត្ថកិច្ចថៃកសាង សំណសំណុំរឿងដើម្បីចាត់វិធានការតាមផ្លូវច្បាប់។

## ប្រតិបត្តិការត្រួតពិនិត្យឯកសារស្នាក់នៅ ពលករបរទេសចំនួន២០០នាក់

https://www.facebook.com/CambodiaLabour/ ព័ត៌មានពលករខ្មែរ 15-01-2018

ប្រតិបត្តិការត្រួតពិនិត្យឯកសារស្នាក់នៅ ពលករបរទេស នៅក្នុងតំបន់ទេសចរណ៍ ក្រុងប៉ាតាយ៉ា ស្រុកបាងឡាម៉ុងខេត្តឈុនបុរី កាលវេលាម៉ោង០៦:០០ ថ្ងៃអង្គារ ទី១៥ ខែមករា ឆ្នាំ២០១៩ ។ យោងតាមរបាយការណ៍សមត្ថកិច្ចអន្តោប្រវេសន៍ខេត្តឈុនបុរី បាននាំខ្លួនពលករបរទេសញាតិខ្មែរនិងភូមា សរុបចំនួន២០០នាក់ យកមកធ្វើការត្រួតពិនិត្យឯកសារស្នាក់នៅធ្វើការ នៅអធិការដ្ឋានតម្រួតអន្តោប្រវេសន៍ ចមធៀន ក្រុងប៉ាតាយ៉ា តាមនិតិវិធីច្បាប់ ។

## អាមេរិកស្ថិតនៅលេខរៀងទី១០ក្នុងចំណោមប្រទេសគ្រោះថ្នាក់បំផុតសម្រាប់ស្ត្រី

http://nokorwatnews.com/ 15-01-2019

មហាអំណាចពិភពលោក អាមេរិក ដែលជាប្រទេសមានសិទ្ធិសេរីភាពពេញលេញ ពិសេសគឺស្ត្រី ស្មើភាពគ្នាជាមួយបុរស។ ប៉ុន្តែ តាមរបាយការរបស់ Wonders List បានផ្សាយជាសាធារណបង្ហាញឲ្យឃើញ ថា មហាអំណាចអាមេរិក ជាប្រទេសមួយស្ថិតនៅក្នុងចំណោម១០ ដែលគ្រោះថ្នាក់បំផុតសម្រាប់ស្ត្រី ។

តាមរបាយការណ៍របស់ Wonders List ស្ដីពីបញ្ជីឈ្មោះប្រទេស ដែលមានគ្រោះថ្នាក់បំផុត សម្រាប់ស្ត្រីនៅឆ្នាំ២០១៩ ក្នុងនោះមាន ឥណ្ឌា អាហ្វហ្គានីស្ថាន ស៊ូម៉ាលី … ជាដើម ដែលជាតំបន់ត្រូវបានគេចាត់ទុកថា ស្ត្រីតែងតែរងការរំលោភបៀតបៀនផ្លូវភេទ។

តាម Wonders List ឥណ្ឌាជាប្រទេសនាំមុខ នៅក្នុងបញ្ជីឈ្មោះ ប្រទេសទាំងនោះ មានគ្រោះថ្នាក់បំផុតសម្រាប់ស្ត្រីនៅក្នុងឆ្នាំ២០១៩ ។ ភាពគ្រោះថ្នាក់របស់ស្ត្រីកើតឡើង ដោយបញ្ហា៣យ៉ាង ក្នុងនោះមាន ទំនៀបទម្លាប់វប្បធម៌ អំពើហឹង្សាផ្លូវភេទ និងការជួញដូរមនុស្ស ។ សូមបញ្ជាក់ផងដែរថា មានស្ត្រីឥណ្ឌាប្រមាន៧០ភាគរយគឺជាជនរងគ្រោះនៅក្នុងការវាយប្រហាររំលោភបំពានផ្លូវភេទ ធ្វើការលើសកម្លាំង ។

ចំណែកអាហ្វហ្គានីស្ថាន ក៏ជាតំបន់ដែលមិនមានសុវត្ថិភាពដល់ស្ត្រីនោះឡើយនៅក្នុងឆ្នាំ២០១៩ ។ នៅក្នុងប្រទេសនេះ មានស្ត្រី៨០ភាគរយ មិនចេះអក្សរ ហើយមានស្ត្រីជាច្រើនស្លាប់ពេលសម្រាលកូន។

ដោយឡែកស៊ីរីគឺជាប្រទេស ឈរលំដាប់ទី៣ ក្នុងបញ្ជី និងជាប្រទេស ដែលស្ត្រីរងការបៀតបៀនផ្លូវភេទ ជាច្រើន។ ក្រៅពីនេះនៅមានប្រទេសជាច្រើនទៀត ដែលជាគ្រោះថ្នាក់បំផុតសម្រាប់ស្ត្រី ឆ្នាំ២០១៩ គឺ ១-ឥណ្ឌា ២-អាហ្វហ្គានីស្ថាន ៣-ស៊ីរី ៤-ស៊ូម៉ាលី ៥-សាឌីអារ៉ាប៊ី ៦-ប៉ាគីស្ថាន ៧-សាធារណរដ្ឋ កុងហ្គោ ៨-យេម៉ែន ៩-នីហ្សេរីយ៉ា ហើយអាមេរិកស្ថិតនៅលេខរៀងទី១០ នៃប្រទេសដែលមាន ភាពគ្រោះថ្នាក់បំផុតសម្រាប់ស្ត្រី ៕

# ថ្ងៃទី១៨ ខែមករា ឆ្នាំ២០១៩

## ឧត្តមសេនីយ៍ទោ ប៉ាក់ យូលាង ប្រាប់សិក្ខាកាមយកចំណេះវិជ្ជាទៅបំរើមូលដ្ឋាន

http://cambodiapolice.com/policekh/ 1:13 pm 18 មករា 2019

ភ្នំពេញ៖ ឯកឧត្តម ឧត្តមសេនីយ៍ទោ ប៉ាក់ យូលាង ប្រធានស្ដីទី នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជនផ្តាំផ្ញើរអោយសិក្ខាកាម ដែលទទួលបានចំណេះវិជ្ជាពីការសិក្សាយកទៅបំរើក្នុងមូលដ្ឋាននិងជួយបណ្តុះបណ្តាលដល់កងកម្លាំងផ្សេងៗទៀតពេលត្រឡប់ទៅកាន់កន្លែងបំរើការងារវិញ។ មានប្រសាសន៍ខណៈដែលឯកឧត្តម ឧត្តមសេនីយ៍ទោ ប៉ាក់ យូលាង ប្រធានស្តីទីនាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន តំណាងលោកជំទាវនាយឧត្តមសេនីយ៍ យក់ សុខា អគ្គស្នងការរងនគរបាលជាតិ អញ្ជើញជាអធិបតីភាព ក្នុងពិធីបិទវគ្គបណ្តុះបណ្តាលពង្រឹងសមត្ថភាពដល់នគរបាលរាជធានី-ខេត្ត ចំនួន៥ថ្ងៃ នៅព្រឹកថ្ងៃទី១៨ មករា ឆ្នាំ២០១៩នេះ នៅនាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន នៃអគ្គស្នងការដ្ឋាននគរបាលជាតិ។

ឯកឧត្តម ឧត្តមសេនីយ៍ទោ ប៉ាក់ យូលាង បានបន្ថែមអោយដឹងថា៖ ស្ថានភាពបទល្មើសពាក់ព័ន្ធការជួញដូរមនុស្ស និងអំពើអាជីវកម្មផ្លូវភេទលើស្ត្រី និងកុមារនៅកម្ពុជា នៅតែជាបញ្ហាដែលត្រូវយកចិត្តទុកដាក់រួមគ្នា ដើម្បីប្រយុទ្ធប្រឆាំង ឆ្លងតាមកិច្ចសហប្រតិបត្តការណ៍រវាងនគរបាលជាតិកម្ពុជាជាមួយ និងអង្គការមេត្រីអន្តរជាតិ និងសេចក្តីអំណរអន្តរជាតិកន្លងមកទទួលបានលទ្ធផលជាច្រើនក្នុងការស៊ើបអង្កេត បង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទលើអនីតិជនជាបន្តបន្ទាប់។ ក្នុងពិធីបិទវគ្គនោះផងដែរឯកឧត្តម ក៏បានថ្លែងអំណរគុណដល់អង្គការទាំងពីរ គឺអង្គការមេត្រីអន្តរជាតិ (AIM SWAT) និងសេចក្តីអំណរអន្តរជាតិ (JOY INTERNATIONAL) ដែលបានជួយបណ្តុះបណ្តាលដល់សិក្ខាកាមដើម្បីយកចំណេះវិជ្ជាទៅបំរើដល់សង្គមដូចជាការបង្ក្រាបបទល្មើស ចាប់ជនសង្ស័យ និងសង្គ្រោះជនរងគ្រោះ ចាំបាច់ត្រូវតែមានការស្វែងយល់បន្ថែមនូវវិធីសាស្ត្រការពារខ្លួន និងការប្រើប្រាស់អាវុធពេលប្រតិបត្តការបង្ក្រាបបទល្មើស ក្នុងការចាប់ខ្លួនជនសង្ស័យ និងសង្គ្រោះជនរងគ្រោះប្រកបដោយសុវត្ថិភាព ព្រមទាំងការសង្គ្រោះបឋមពេលមានរបួសនៅកំឡុងពេលប្រតិបត្តិការនេះផងដែរ។

គួរបញ្ជាក់ថា វគ្គបណ្តុះបណ្តាលរយៈពេល៥ថ្ងៃនេះ មានការចូលរួមពីសំណាក់អង្គការចំនួនពីរ គឺអង្គការមេត្រីអន្តរជាតិ (AIM SWAT) និងសេចក្តីអំណរអន្តរជាតិ (JOY INTERNATIONAL) ដែលមានគ្រូឧទ្ទេសនាមដែលមានបទពិសោធខ្ពស់មកពីសហរដ្ឋអាមេរិក និងមានគ្រូជំនួយជានគរបាលស្ត្រីចំនួន ០២រូប ព្រមទាំងមានការចូលរួមពីសិក្ខាកាមជា នាយ នាយរងនគរបាលពីតាមរាជធានី-ខេត្តចំនួន៧គឺ៖ ភ្នំពេញ កំពត ពោធិសាត់ តាកែវ កំពង់ចាម កំពង់ឆ្នាំង និងកំពង់ស្ពឺ៕

## "អាជ្ញាធរថៃ បញ្ជូនពលករខ្មែរ ខុសច្បាប់ ០៧នាក់ តាមច្រកព្រំដែនកោះកុង"

https://www.facebook.com/CambodiaLabour/ ព័ត៌មានពលករខ្មែរ 17-01-2019

នគរបាលប៉ុស្តិ៍ច្រកទ្វារអន្តរជាតិចាំយាមទទួលពលករខ្មែរឆ្លងដែនខុសច្បាប់ពីភាគីថៃ៧នាក់ កោះកុង៖ កម្លាំងនគរបាលប៉ុស្តិ៍ច្រកទ្វារអន្តរជាតិចាំយាម បានទទួលពលករខ្មែរឆ្លងដែនខុសច្បាប់ ពីភាគីថៃ ៧នាក់ ស្រីម្នាក់ នាល្ងាចថ្ងៃទី១៦ ខែមករា ឆ្នាំ២០១៩។ ពលករខ្មែរឆ្លងដែនខុសច្បាប់ ដែលភាគីថៃ ប្រគល់មកឲ្យកម្ពុជាវិញ ត្រូវបានកម្លាំងនគរបាលប៉ុស្តិ៍ច្រកទ្វារអន្តរជាតិចាំយាម បានធ្វើការអប់រំណែនាំ រួច អនុញ្ញាតិឲ្យត្រឡប់ទៅផ្ទះវិញ៕

## មានការណាត់ជួបប្រជុំគ្នាមួយ រវាងកងកម្លាំងកម្ពុជា និងទាហានថៃ ថៃសុំអោយជួយទប់ស្កាត់ពលរដ្ឋខ្មែរឆ្លងដែនកាប់ឈើក្រញូងក្នុងទឹកដីថៃ

https://www.facebook.com/cpnnews.info/ CPN News 17-01-2019

ឧត្តរមានជ័យ: នៅវេលាម៉ោង១០និង២០នាទីថ្ងៃទី១៧ ខែមករា ឆ្នាំ២០១៩ មានការណាត់ជួបប្រជុំគ្នារវាងកងកម្លាំងកម្ពុជា និងទាហានថៃ នៅតំបន់ ស ទល់មុខភូមិសាស្ត្រប៉ុស្តិ៍ ព្រះប្រឡាយនៅចំណុច VA(45.89.6) សមាសភាពចូលរួមខាងកម្ពុជា .កម្លាំងប៉ុស្តិ៍ព្រះប្រឡាយចំនួន០៥នាក់ ដឹកនាំដោយលោកអនុ ម៉ែន ផេន នាយប៉ុស្តិ៍សហការណ៍ជាមួយយោធាចំនួន១០នាក់ ដឹកនាំដោយលោក ធុន តន មេបញ្ជាការរង សឹករងស្រុកត្រពាំងប្រាសាទ។ ភាគីទាហានថៃចំនួន០៨នាក់ ដឹកនាំដោយលោ ចក្សួនស័ក យុនថង មេបញ្ជាការរងកងរយ២៣ឈុតខ្មៅ។

*ខ្លឹមសារប្រជុំ៖ ខាងថៃសំណូមពរអោយជួយទប់ស្កាត់ពលរដ្ឋខ្មែរ លួចឆ្លងដែនកាប់ឈើ ក្នុងទឹកដីថៃចំណុចទល់មុខភូមិសាស្ត្រ ឃុំអូរស្វាយ ស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ ខាងកម្ពុជាក៏បានឯកភាព៕ ដោយ:សាន់រិទ្ធ

## អ្នកដំណើរចេញចូលកម្ពុជាឆ្លងកាត់ច្រកទ្វារព្រំដែនអន្តរជាតិប៉ោយប៉ែត១ឆ្នាំជាង១៣លាននាក់

http://www.rasmeinews.com/ January 18, 2019, 9:42 AM

ដោយ:ភ្នំស្វាយ/បន្ទាយមានជ័យ: លោកឧត្តមសេនីយ៍ទោស៊ឹមសំអាតនាយប៉ុស្តិ៍នគរបាលច្រកទ្វារអន្តរជាតិប៉ោយប៉ែតដែលត្រូវផ្លាស់ចេញបានឱ្យដឹងកាលពីរសៀលថ្ងៃទី១៧ ខែមករា ឆ្នាំ២០១៩ថា: កន្លងមកការសម្រួលបែបបទចេញ-ចូលជូនអ្នកដំណើរឆ្លងកាត់ច្រកទ្វារព្រំដែនអន្តរជាតិប៉ោយប៉ែត សហការនឹងសមត្ថកិច្ចស្ថាប័នពាក់ព័ន្ធនៅច្រកទ្វារព្រំដែនអន្តរជាតិប៉ោយប៉ែត-ខ្លងលឹកបានល្អ ក្នុងនោះ អ្នកដំណើរចេញ ចូលមាន : អ្នកដំណើរចូលមាន : ៦.៧២៨.៩៤៦នាក់ ក្នុងនោះមាន១២៧សញ្ជាតិ មានជនបរទេស៥១៦.៣០៤ នាក់ ។

អ្នកដំណើរចេញពីប្រទេស មានចំនួន៦.៨៤៤.៧៦៩នាក់ មាន១២៣សញ្ជាតិ។ ក្នុងនោះមានជនបរទេស៥២៦.៦៥២នាក់។ ដោយឡែកមានពលករខ្មែរឆ្លងដែនខុសច្បាប់ ដែលអាជ្ញាធរថៃចាប់បញ្ជូនមកចំនួន៨៨៨លើកមនុស្ស ៣០.៥៣០នក់។ ក្នុងនោះស្ត្រី១/៣ និងកុមារ១/១០។ ចំពោះកិច្ចសហប្រតិបត្តិការប៉ុស្តិ៍បានសហការយ៉ាងល្អជាមួយសមត្ថកិច្ច និងអាជ្ញាធរពាក់ព័ន្ធច្រកទ្វារនិងអាជ្ញាធរដែនដី ព្រមទាំងភាគីថៃ ដោះស្រាយបញ្ហាដែលកើតឡើងចំពោះ ពលរដ្ឋខ្មែរ និងទប់ស្កាត់ បង្ក្រាបបទល្មើសនានា។

លោកឧត្តមសេនីយ៍ទោស៊ឹមសំអាតនាយប៉ុស្តិ៍ចាស់ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិប៉ោយប៉ែត ផ្លាស់ចេញ ហើយឡើងជាអនុប្រធាននាយកដ្ឋានច្រកទ្វារទី១នៃអគ្គនាយកដ្ឋានអន្តោប្រវេសន៍ ក្រសួងមហាផ្ទៃដោយដាក់ជំនួសមកវិញនូវលោកវរសេនីយ៍ទោខឹមចិត្រាអតីតនាយប៉ុស្តិ៍នគរបាលការពារព្រំដែេនគោកច្រកទ្វារតំបន់ជ្រៃធំ ខេត្តកណ្តាល ជាមេប៉ុស្តិ៍ថ្មី ។

លោកខឹមចិត្រានាយប៉ុស្តិ៍ថ្មីបានថ្លែងអំណរគុណចំពោះការជឿទុកចិត្តនិងប្រគល់ភារកិច្ចជូនលោក ហើយលោកសូមប្តេជ្ញាចិត្តថានឹងខិតខំបំពេញភារកិច្ចអោយបានល្អនិងប្រកបដោយការទទួលខុសត្រូវ ។ លោកង៉ោ ម៉េងជ្រួនអភិបាលរងខេត្តបន្ទាយមានជ័យក៏ដូច លោកនាយឧត្តមសេនីយ៍ យុន សំបូរ អគ្គនាយករងនៃអគ្គនាយកដ្ឋានអន្តោប្រវេសន៍ បានសាទរនិងណែនាំអោយនាយប៉ុស្តិ៍ ក៏ដូចនាយរង នាយផ្នែកមន្ត្រីនគរបាលប៉ុស្តិ៍ច្រកទ្វារអន្តរជាតិប៉ោយប៉ែត់ទាំង១០៥នាក់បន្តខិតខំបំពេញភារកិច្ចអោយបានលទ្ធផលល្អបន្ថែមទៀត។ នាយឧត្តមសេនិយ៍ណែនាំអោយមន្ត្រីនគរបាលបន្តខិតខំរៀនភាសាអង់គ្លេស សិក្សាពីច្បាប់ បទដ្ឋានជាតិ អន្តរជាតិដែលអគ្គនាយកដ្ឋានអន្តោប្រវេសន៍ក្រសួងមហាផ្ទៃ. ក្រសួងការបរទេសចេញ ។ ជាងនេះទៅទៀត មន្ត្រីនគរបាលអន្តោប្រវេសន៍ត្រូវរៀបចំគោលគំនិតកិច្ចការ :ទី១- ឈរលើគោលការណ៍សម្រេចដែលថ្នាក់លើដាក់អោយ ។ ទី២- គោលការណ៍គោរពការងារជំនាញ ។ ទី៣- គោលការណ៍ច្បាប់ និងទិដ្ឋភាពនយោបាយ និងទី៤- គោលការណ៍ប្រមូលផ្តុំគំនិតអនុវត្ត តែសុំគោលការណ៍សម្រេចពីថ្នាក់លើ ។ ហើយត្រូវចេះរក្សាការសម្ងាត់ និងលាក់ការណ៍ខ្ពស់ ។ៃS/

## ពលករខ្មែរធ្វើការនៅថៃបារម្ភពីបរិស្ថានកខ្វក់នៅលើអាកាសក្នុងទីក្រុងបាងកកប៉ះពាល់សុខភាព

https://www.rfa.org/khmer/news/ ដោយ សន ចាន់រដ្ឋា 2019-01-16

ពលករខ្មែរធ្វើការងារនៅទីក្រុងបាងកក ប្រទេសថៃ មួយចំនួនកំពុងខ្វល់ខ្វាយអំពីបរិស្ថានកខ្វក់នៅលើអាកាសប៉ះពាល់ដល់សុខភាព ហើយធ្វើឲ្យធ្លាក់ខ្លួនឈឺមិនអាចធ្វើការងាររកប្រាក់ចំណូលបាន។ ក្តីបារម្ភនេះ បន្ទាប់ពីនាយករដ្ឋមន្ត្រីថៃបានប្រកាសឲ្យពលរដ្ឋរបស់ខ្លួនប្រុងប្រយ័ត្ន ហើយបើមិនចាំបាច់មិនត្រូវចេញពីក្នុងផ្ទះនោះទេ ព្រោះខ្យល់កខ្វក់នេះប៉ះពាល់ដល់សុខភាពមនុស្សធ្ងន់ធ្ងរ។

ពលករធ្វើការផ្នែកសន្តិសុខនៅទីក្រុងបាងកក លោក គុណ កក្កដា ថ្លែងប្រាប់អាស៊ីសេរីនៅរសៀលថ្ងៃទី១៦ មករាថា ចាប់ពីពួកគាត់ទទួលដំណឹងបរិស្ថានកខ្វក់នៅលើអាកាសគ្របដណ្ដប់ទីក្រុងបាងកកមក ពួកគាត់មានការភ័យព្រួយយ៉ាងខ្លាំង ព្រោះខ្លាចធ្លាក់ខ្លួនឈឺប៉ះពាល់ដល់ការងារ៖ «ព្រោះអីកាលណាយើងមានបញ្ហាសុខភាពទៅយើងធ្វើការឲ្យគេអត់បានទេ ដូច្នេះខ្ញុំព្រួយបារម្ភបញ្ហានេះយ៉ាងខ្លាំង។ ខ្ញុំសំណូមពរឲ្យរដ្ឋាភិបាលថៃជួយដោះស្រាយបញ្ហានេះឲ្យបានឆាប់ផង មិនមែនព្រួយបារម្ភតែពលករខ្មែរទេ ជនជាតិថៃក៏បារម្ភដែរ ព្រោះខ្លាចអត់ការងារធ្វើ ដូច្នេះហើយសូមអ្នកពាក់ព័ន្ធជួយឲ្យបានឆាប់ ព្រោះពលករខ្មែរជាច្រើននាក់ដែលព្រួយបារម្ភខ្លាចអត់ការងារធ្វើ»។

ចំណែកពលការិនីធ្វើការងារផ្នែកលក់បាយនៅទីក្រុងបាងកក គឺអ្នកស្រី សាយ សាន អះអាងថា ប្រសិនបើអ្នកស្រីធ្លាក់ខ្លួនឈឺដោយសារការស្រូបល្អងធូលីកខ្វក់ចូលទៅក្នុងខ្លួននោះ ថៅកែជនជាតិថៃនឹងរកពលករផ្សេងចូលធ្វើការជំនួសភ្លាម ហើយនៅពេលនោះធ្វើឲ្យប៉ះពាល់ដល់ក្រុមគ្រួសារនៅឯស្រុកខ្មែរជាមិនខាត ព្រោះពួកគាត់ពឹងផ្អែកទាំងស្រុងទៅលើប្រាក់ចំណូលដែលផ្ញើពីប្រទេសថៃ៖ «យើងក៏ការពារខ្លួនឯងដែរ ព្រោះអីសុខភាពវាជាការសំខាន់ ខ្ញុំព្រួយបារម្ភបើសិនជាខ្ញុំឈឺនៅស្រុកថៃនេះអាចទៅព្យាបាលនៅមន្ទីរបាន ប៉ុន្តែបារម្ភរឿងការបើយើងឈឺសុខភាពមិនល្អធ្វើការងារមិនបានគឺ លំបាកហើយ ព្រោះយើងរស់នៅទីនេះត្រូវការអាស្រ័យការងាររកប្រាក់ចិញ្ចឹមក្រពះប្រចាំថ្ងៃ»។

ពលករទាំង ២រូបអំពាវនាវឲ្យពលករខ្មែរដែលត្រៀមឆ្លងដែនទៅធ្វើការនៅប្រទេសថៃអំឡុងពេលនេះសូមឲ្យមានការប្រុងប្រយ័ត្ន ដោយមានម៉ាសគ្របច្រមុះពាក់ការពារប្រព័ន្ធដកដង្ហើម ហើយបើមិនចាំបាច់កុំចូលទីក្រុងបាងកកអំឡុងពេលនេះ។

អាស៊ីសេរីមិនអាចទាក់ទងអ្នកនាំពាក្យក្រសួងសុខាភិបាល ដើម្បីសុំការពន្យល់អំពីវិធានការណែនាំផ្នែកសុខភាពដល់ពលករខ្មែរនៅទីក្រុងបាងកកបានទេនៅថ្ងៃទី១៦ មករា ដោយទូរស័ព្ទមិនមានអ្នកទទួល។

ចំណែក អ្នកនាំពាក្យអគ្គនាយកដ្ឋានប៉ូលិសអន្តោប្រវេសន្ត លោក កែវ វណ្ណថន មានប្រសាសន៍យ៉ាងខ្លីថា ខាងលោកមិនមានទាក់ទងលើបញ្ហានេះទេ៖ «អូ! ខាងខ្ញុំអត់ទទួលខាងនឹងទេ អន្តោប្រវេសន្តអត់ទទួលខាងនេះទេ បាទអត់ពាក់ព័ន្ធខាងខ្ញុំទេ សុំទោសបានហើយអីចឹងបាទ!»។

ទូរទស្សន៍ថៃភីប៊ីអែស(Thai PBS)ផ្សាយឲ្យដឹងថា អាជ្ញាធរទីក្រុងបាងកក កាលពីព្រឹកថ្ងៃអង្គារបានបញ្ជាឲ្យអាជ្ញាធរក្រោមឱវាទបញ្ចេញរថយន្តបូមទឹកលាងសំអាតតាមផ្លូវសាធារណៈ និងបាញ់ទឹកទៅលើអាកាសដើម្បីជួយកាត់បន្ថយបរិស្ថានកខ្វក់នៅទីក្រុងបាងកក។ ចំណែកឯកងទ័ពអាកាសក៏បានបើកយន្តហោះទៅលើអាកាសបង្កើតទឹកភ្លៀងសិប្បនិមិត្ត និងបានដឹកទឹកចំនួន៣ម៉ឺនលីត្រ(៣០,០០០) បានហោះចំនួន ១២ជើងបាញ់ទឹកពីលើអាកាសនៅតំបន់ទីក្រុងបាងកក ដើម្បីជួយសម្រួលដល់ការដកដង្ហើមរបស់មនុស្សនៅរសៀលថ្ងៃដដែលនេះដែរ។ បន្ថែមពីនេះពេទ្យទាហានអាកាសរបស់ថៃក៏បានផ្សព្វផ្សាយអប់រំដល់ប្រជាពលរដ្ឋរបស់ខ្លួនឲ្យយល់ដឹងអំពីភាពកខ្វក់នៅក្នុងអាកាសនេះ ដោយបានចែកម៉ាសពាក់ការពារប្រព័ន្ធដកដង្ហើមចំនួន ៣ម៉ឺនម៉ាស (៣០.០០០) ជូនដល់ពលរដ្ឋនៅទីនោះផងដែរ។

កាសែត The Nation នៅថ្ងៃអង្គារ ទី១៥ មករា បានស្រង់សំដីរបស់ប្រធាន នាយកដ្ឋានពាណិជ្ជកម្មផ្ទៃក្នុង (Internal Trade Department) ថៃ លោក វិឆ័យ ប៉ូចាណាគីត (Wichai Pochanakit) ដែលព្រមានដល់ហាងលក់ម៉ាស់ mask គ្របច្រមុះ មិនឲ្យដំឡើងថ្លៃ ហើយថា អ្នកល្មើសនឹងការព្រមាននេះនឹងរងការផាកពិន័យ ១៤ម៉ឺនបាត ឬដាក់ពន្ធនាគាររយៈ ៧ឆ្នាំ ឬត្រូវទទួលទោសទាំងពីរនេះ។

យុទ្ធនាការនេះធ្វើឡើងបន្ទាប់ពីអាជ្ញាធរថៃពិនិត្យឃើញថា ផ្សែង និងល្អងធូលីកខ្វក់នៅលើអាកាសក្នុងទីក្រុងបាងកកមួយរយៈនេះ ឡើងដល់កម្រិតប្រកាសអាសន្ន។ បរិស្ថានកខ្វក់នេះ កើនឡើងខ្លាំងចាប់ពីថ្ងៃទី១៦ ដល់ថ្ងៃទី១៨ មករា ដែលអាចបន្តរហូតដល់ចុងខែមករា។ ផ្សែង និងល្អងធូលីកខ្វក់នេះកើតឡើងដោយសារផ្សែងរថយន្តខ្ជួល

ខ្ជាញ់ច្រើនពេក និងផ្សែងចេញពីរោងចក្រឧស្សាហកម្មទៅលើអាកាសមានបរិមាណច្រើន ខណៈដែលទីក្រុងមួយនេះគ្រាន់តែរថយន្តមានដល់ទៅជិត១០លានគ្រឿងឯណោះ។

សព្វថ្ងៃនៅប្រទេសថៃមានពលករខ្មែរធ្វើការងារជាង ១លាននាក់ ក្នុងនោះពលកររាប់ម៉ឺននាក់កំពុងធ្វើការនៅទីក្រុងបាងកក។

នាយករដ្ឋមន្ត្រីថៃ ក៏បានប្រកាសប្រាប់ពលរដ្ឋខ្លួនដែរថា ក្នុងរយៈពេលផ្សែង និងល្អងធូលីកខ្វក់នេះកំពុងឡើងខ្ពស់ ប្រសិនបើមិនមានការចាំបាច់ទេ សូមកុំចេញពីផ្ទះ ហើយបើត្រូវចេញពីផ្ទះត្រូវពាក់ម៉ាសគ្របច្រមុះ ដើម្បីកាត់បន្ថយការដកដង្ហើមចូលល្អងផ្សែងកខ្វក់៕

## ថ្ងៃទី២១ ខែមករា ឆ្នាំ២០១៩

### អាជ្ញាធរថៃដោះលែងអ្នកទោសខ្មែរ២នាក់ដាច់ដោយឡែកពីគ្នា

https://kohsantepheapdaily.com.kh/ ថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០១៩ ម៉ោង ១៤:០១ ឱម សារឿន

ខេត្តឧត្តរមានជ័យ ៖ អ្នកទោសខ្មែរ២នាក់ត្រូវបានក្រុមអាជ្ញាធរថៃធ្វើការដោះលេងឱ្យមានសេរីភាពដោយបញ្ជូនមកប្រគល់ឱ្យក្រុមអាជ្ញាធរកម្ពុជាវិញម្នាក់តាមមាត់ច្រកទ្វារអន្តរជាតិជាំនិងម្នាក់ទៀតបញ្ជូនមកប្រគល់មាត់ច្រកទ្វារតំបន់ជប់គគីរកាលពីថ្ងៃទី១៨ មករា ២០១៩ ក្នុងថ្ងៃតែមួយ។ អ្នកទោសខ្មែរដែលក្រុមអាជ្ញាធរថៃធ្វើការដោះលេងម្នាក់ឈ្មោះសារឿន ហឿត ភេទប្រុស អាយុ២២ឆ្នាំ រស់នៅភូមិអម្ពិល ឃុំអម្ពិល ស្រុកបន្ទាយអម្ពិល ខេត្តឧត្តរមានជ័យ និងម្នាក់ទៀតឈ្មោះអ៊ី ជី ភេទប្រុស អាយុ២៨ឆ្នាំ រស់នៅភូមិជាំ ឃុំត្រពាំងប្រីយ៍ ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ។

មន្ត្រីដែលបម្រើការងារនៅមាត់ច្រកទ្វារបានឱ្យដឹងថា អ្នកទោសខ្មែរដែលក្រុមអាជ្ញាធរថៃដោះលែងនាំខ្លួនយកមកប្រគល់ឱ្យក្រុមអាជ្ញាធរកម្ពុជាវិញនោះឈ្មោះសារឿន ហឿត ត្រូវបានទាហានថៃចាប់ខ្លួនកាលពីថ្ងៃទី២៥ កក្កដា ២០១៨ ស្ថិតនៅក្នុងឃុំប្រាសាទ ស្រុកបានត្រួត ជាប់ពន្ធនាគារនៅស្រុកណាំងរ៉ង ខេត្តបុរីរ៉ាំ ប្រទេសថៃ និងម្នាកទៀតឈ្មោះអ៊ី ជី ត្រូវបានក្រុមទាហានថៃចាប់ខ្លួនកាលពីថ្ងៃទី២០ តុលា ២០១៧ ជាប់ពន្ធនាគារ នៅស្រុកខាន់តាឡាក់ ខេត្តស៊ីសាកេត ប្រទេសថៃ ដោយចោទប្រកាន់ពីបទឆ្លងដែនខុសច្បាប់កាប់ឈើគ្រញូងនៅក្នុងទឹកដីថៃ បន្ទាប់ពីបានទទួលអ្នកទោសខ្មែរទាំង២នាក់ខាងលើ សមត្ថកិច្ចបានធ្វើការអប់រំរួចឱ្យវិលត្រឡប់ទៅជួបជុំគ្រួសារក្នុងថ្ងៃដដែលផងដែរ៕

### បញ្ជូនជនសង្ស័យ៣នាក់ទៅតុលាការពាក់ព័ន្ធករណីជួញដូរផ្លូវភេទ

http://www.rasmeinews.com/ January 21, 2019, 6:58 AM

ដោយៈសេងឃួន/ក្រចេះ៖ កម្លាំងនគរបាលប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជននៃស្នងការដ្ឋាននគរបាលខេត្តក្រចេះ នឹងបញ្ជូនជនសង្ស័យប្រុសស្រីចំនួន៣នាក់ពាក់ព័ន្ធករណីជួញដូរផ្លូវភេទទៅកាន់តុលាការនៅរសៀលថ្ងៃទី២១ខែមករា ឆ្នាំ២០១៩នេះ។ មន្ត្រីជំនាញនគរបាលបានឱ្យដឹងថាការឃាត់ខ្លួនដឹកនាំដោយលោកស្រីនៅតេនាស្នងការរងប្រឆាំងការជួញដូរមនុស្ស ក្រោមការសម្របសម្រួលពីលោកកែវសុជាតិព្រះរាជអាជ្ញាខេត្តក្រចេះបានឃាត់ខ្លួនជនប្រុសស្រីចំនួន៣នាក់ ពាក់ពន្ធករណីជួញដូរផ្លូវភេទនៅចំណុចផ្ទះគោសជប់ស្ថិតក្នុងភូមិក្បាលស្នួលឃុំស្នួល ស្រុកស្នួលខេត្តក្រចេះកាលពីថ្ងៃទី១៩ខែមករា ឆ្នាំ២០១៩។ មន្ត្រីនគរបាលរូបនោះបានបញ្ជាក់ថាការឃាត់ខ្លួនជនសង្ស័យទាំង៣នាក់នេះក្រោយពីឆែកឆេរផ្ទះមួយកន្លែងមានបន្ទប់ចំនួន៣ដោយសង្ស័យបម្រើសេវាកម្មផ្លូវភេទស្ថិតក្រោមឃីហោកោសជប់ដែលស្ថិតក្នុងភូមិក្បាលស្នួល ឃុំស្នួល ស្រុកស្នួលខេត្តក្រចេះ។

ជនសង្ស័យទី១៖ឈ្មោះ អិន ចាន់ដារ៉ា ភេទប្រុស អាយុ ៣២ឆ្នាំ រស់នៅ ឃុំជើងគ្រាវ ស្រុករលាប្អៀ ខេត្តកំពង់ឆ្នាំង។ទី២៖ឈ្មោះអេង លក្ខិណា ភេទ ស្រីអាយុ១៧ឆ្នាំ រស់នៅភូមិក្បាលដំរី ឃុំក្រែក ស្រុកពញាក្រែក ខេត្តត្បូងឃ្មុំ ។ ទី៣៖ឈ្មោះ ឈូក រចនា ភេទស្រី អាយុ ១៧ឆ្នាំ រស់នៅភូមិអូរឬស្សី សង្កាត់អូរឬស្សី ក្រុងក្រចេះខេត្តក្រចេះ។ មន្ត្រី

នគរបាលរូបនោះបានបន្តថា ក្រោយពីសមត្ថកិច្ច ឃាត់ខ្លួន និងឆែកឆេ ដកហូតបានវត្ថុតាង រួមមាន ទូរស័ព្ទចំនួន២គ្រឿង ស្រោមអនាម័យប្រើប្រាស់រួចមួយចំនួននិងស្រោមអនាម័យ មិនទាន់ប្រើជាច្រើន សម្ភារៈប្រើប្រាស់គ្រឿងញៀនមួយចំនួន។

បច្ចុប្បន្នជនសង្ស័យប្រុសស្រីខាងលើ និងវត្ថុតាងត្រូវបានឃាត់ខ្លួនបណ្ដោះអាសន្ននៅស្នងការដ្ឋាននគរបាលខេត្តក្រចេះ ដើម្បីកសាងសំណុំរឿងបញ្ជូនជនប្រុសស្រីទៅកាន់សាលាដំបូងខេត្តនៅរសៀលថ្ងៃទី២១ ខែមករា ឆ្នាំ ២០១៩ នេះដើម្បីវិធានការតាមនីតិវិធីច្បាប់៕S/

## ពលករខ្មែរនៅថៃដែលត្រូវថៅកែបញ្ឈប់ពីការងារបានចូលធ្វើការវិញក្រោយដូរថៅកែ

https://www.rfa.org/khmer/news/ ដោយ សេក បណ្ឌិត 2019-01-20

តំណាងពលករខ្មែរធ្វើការនៅរោងចក្រ SC WADO ក្នុងខេត្តឈុនបុរី ប្រទេសថៃ ឱ្យដឹងថា នៅពេលនេះពលករខ្មែរដែលត្រូវថៅកែរោងចក្រនេះបញ្ឈប់ពីការងារកាលពីចុងឆ្នាំ២០១៨ កន្លងទៅ ពួកគេបានធ្វើការងារវិញហើយ។ សង្គមស៊ីវិលធ្វើការងារទាក់ទងពលករចំណាកស្រុកស្វាគមន៍ការសម្របសម្រួលរបស់ថៅកែរោងចក្រនេះ។ តំណាងពលករដែលធ្វើការនៅ រោងចក្រSC WADO លោក រស់ ប៊ុនធឿន ឱ្យអាស៊ីសេរី ដឹងនៅថ្ងៃទី២០ មករា ថា ក្រោយរោងចក្រនេះបានប្ដូរពីថៅកែថៃ មកថៅកែជាជនជាតិជប៉ុន ថៅកែរោងចក្រថ្មីបានអនុញ្ញាតឱ្យពលករខ្មែរដែលត្រូវបញ្ឈប់ពីការងារទាំងប៉ុន្មានចូលធ្វើការងារវិញ។ លោកបន្តទៀតថា ថៅកែថ្មីបានផ្ដល់ប្រាក់ខែគោល និងប្រាក់អត្ថប្រយោជន៍ផ្សេងទៀតដល់ពលករខ្មែរស្មើនឹងពលករជាជាតិថៃដែរ ហើយថែមទាំងផ្ដល់លិខិតឆ្លងដែនឱ្យពលករខ្មែរជាអ្នករក្សាទុកដោយខ្លួនឯងថែមទៀតផង៖ «បុគ្គលិកម្នាក់ៗគេសប្បាយចិត្តនឹងការងារពេលបានដំណឹងល្អពីរោងចក្រហៅចូលធ្វើការងារអ៊ីចឹងទៅគេចូលធ្វើវិញទៅ»។ តំណាងពលកររូបនេះ ឱ្យដឹងទៀតថា មូលហេតុដែលថៅកែរោងចក្រផ្ដល់អត្ថប្រយោជន៍ការងារស្មើនឹងពលរដ្ឋថៃ ព្រោះថៅកែរោងចក្របានចុះសង្កេតដោយផ្ទាល់ឃើញថា ពលករខ្មែរបំពេញការងាររបស់ខ្លួនបានល្អដូចពលករជនជាតិថៃដែរ៖ «ធ្វើការងារមានលុយគុណថ្ងៃសៅរ៍ ថ្ងៃអាទិត្យធម្មតាដូចថៃ ដល់អ៊ីចឹងខ្មែរយើងមានកម្លាំងនឹងធ្វើការងារ ពីមុននឹងយើងមិនបានអាទិភាពដូចថៃទេ»។

កាលពីចុងឆ្នាំ២០១៨ ក្នុងអំឡុងខែវិច្ឆិកា ថៅកែរោងចក្រ SC WADO ក្នុងខេត្តឈុនបុរី ប្រទេសថៃ បានបញ្ឈប់ពលករខ្មែរជាង ៥០នាក់ពីការងារ ដោយលើកហេតុផលថា គ្មានការងារឱ្យធ្វើ។ ពលករប្រាប់ថា អ្នកដែលត្រូវបញ្ឈប់ពីការងារថៅកែមិនបានផ្ដល់លិខិតឆ្លងដែនឱ្យពួកគេវិញទេ។

មន្ត្រីកម្មវិធីនៃមជ្ឈមណ្ឌលសម្ពន្ធភាពការងារ និងសិទ្ធិមនុស្ស (CENTRAL) លោក ឌីថេ ហូយ៉ា មានប្រសាសន៍ថា លោកស្វាគមន៍នូវការផ្ដល់ដំណោះស្រាយនេះ។ ប៉ុន្តែ លោកយល់ថា ករណីនេះផ្អែកតាមច្បាប់ការងារក្រុមហ៊ុនត្រូវទទួលខុសត្រូវលើការខាតបង់របស់ពលករក្នុងអំឡុងបាត់បង់ការងារ។ លោកបន្តទៀតថា ក្នុងករណីមានវិវាទការងារភាគីពាក់ព័ន្ធធ្វើយ៉ាងឱ្យមានការគោរពសិទ្ធិការងារ សិទ្ធិមនុស្ស និងដោះស្រាយឱ្យបានទាន់ពេលជួយដល់ពលករ៖ «ខ្ញុំឱ្យមានយន្តការរដ្ឋចូលរួមធ្វើអន្តរាគមន៍ណា ភាគីទាំងបីត្រូវសហការគ្នាក្រុមហ៊ុននាំពលករ ក្រុមហ៊ុននៅប្រទេសទទួល ហើយអាជ្ញាធររដ្ឋក្នុងនាមជាអាណាព្យាបាលដែលមានស្ថានទូតស្ថានកុងស៊ុលគួរតែជួយធ្វើអន្តរាគមន៍ឱ្យមានប្រសិទ្ធភាព»។

ក្រុមពលករឱ្យដឹងថា ការសម្រេចរបស់ថៅកែដែលហៅពលករខ្មែរឱ្យចូលធ្វើការងារ បន្ទាប់ពីមានសារព័ត៌មានផ្សាយ ការបញ្ឈប់ពលករខ្មែរជាបន្តបន្ទាប់ដែលធ្វើឱ្យថៅកែរោងមានព្រួយបារម្ភពីទង្វើរបស់ខ្លួន ខណៈមានការចោទប្រកាន់ថា ការបញ្ឈប់នេះជាការរំលោភសិទ្ធិការងារ៕

## "វេទិកាសាធារណៈស្តីអំពីស្តាប់បញ្ហាពលករចំណាកស្រុកលើកទី២"

https://www.facebook.com/CambodiaLabour/ 20-01-2019

នៅព្រឹកថ្ងៃអាទិត្យ ទី២០ ខែមករា ឆ្នាំ២០១៩ មូលនិធិ labour rights promotion network ( LPN ) ប្រទេសថៃ រៀបចំវេទិកាសាធារណៈស្តីអំពី"ស្តាប់បញ្ហាពលករបរទេសនៅក្នុងប្រទេសថៃ" ជាលើកទីពីរ វេទិកាសាធារណៈបានរៀបចំឡើងនៅក្នុងសាលាបឋមសិក្សាវាត់ស៊ីនុផារ៉ាម ស្ថិតក្នុងស្រុកមហាឆៃ ខេត្តសាមុតសាខន។ ក្នុងវេទិកាសាធារណៈស្តាប់បញ្ហាពលករបរទេសលើកទីពីរនេះ មានការអញ្ជើញចូលរួមពីសំណាក់ បងប្អូនពលករភូមា សមាគមពលករភូមានៅក្នុងប្រទេសថៃ , តំណាងពលករខ្មែរនៅក្នុងប្រទេសថៃ ជាពិសេសទៅទៀតមានការអញ្ជើញចូលរួមពីសំណាក់អគ្គនាយកដ្ឋានតម្រួតប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ,អគ្គនាយកដ្ឋានតម្រួតអន្តោប្រវេសន៍ ,មន្ទីរគាំពារសិទ្ធិនិងសុខម៉ាភាពពលករ, មន្ទីរធានារ៉ាប់រងប្រកាន់សង្គម ,និងអាជ្ញាធរពាក់ព័ន្ធមួយចំនួនទៀត ។

វេទិកាសាធារណៈស្តីអំពី"ស្តាប់បញ្ហាពលករបរទេស" លើកទីពីរនេះបានផ្តោតសំខាន់ទៅបញ្ហាការធ្វើការរស់នៅរបស់ពលករបរទេសនៅក្នុងប្រទេសថៃ ដែលកំពុងជួបប្រទះលើបញ្ហាមួយចំនួនដូចជា ច្បាប់ការងារ,សិទ្ធិអាស្រ័យ, ធានារ៉ាប់រងប្រកាន់សុខភាព,អំពើជិះជាន់កម្លាំងពលកម្ម,អំពើជួញដូរមនុស្ស,ជាដើម។ រាល់បញ្ហារបស់បងប្អូនពលករបរទេសបានស្នើទៅរាជរដ្ឋាភិបាលថៃ ក្នុងវេទិកាសាធារណៈនេះខាងមន្ត្រីរាជរដ្ឋាភិបាលថៃ និងយកទៅពិចារណាដើម្បីដោះស្រាយបញ្ហាជូនពួកគាត់នៅពេលអនាគត។ Labour Rights Promotion Network

## តុលាការសិង្ហបុរីផ្តន្ទាទោសប្តីប្រពន្ធមួយគូ ដែលធ្វើទារុណកម្មអ្នកបម្រើជនជាតិមីយ៉ាន់ម៉ា យ៉ាងសាហាវព្រៃផ្សៃ

http://khmeread.com/posts/ January 21, 2019 09:56AM

ដោយធ្វើទារុណកម្មអស់ជាច្រើនខែ អ្នកបម្រើម្នាក់ត្រូវបានគេបង្ខំឱ្យធ្វើសកម្មភាពគ្រោះថ្នាក់ដោយខ្លួនឯងជាច្រើនដង រួមទាំងការចាក់ទឹកក្តៅលើខ្លួន និងផឹកទឹកកខ្វក់លាយជាមួយនឹងម្សៅសាប៊ូ។ Phyu Phyu Mar ក៏មិនបានទទួលប្រាក់ខែ ៧០០ ដុល្លារក្នុងមួយខែផងដែរក្នុងរយៈពេលធ្វើការងាររបស់នាង ជាមួយជនរំលោភបំពានរបស់នាង ហើយទម្ងន់របស់នាងបានស្រកចុះពី ៥០ គីឡូក្រាមមកនៅត្រឹមតែ ៣៨ គីឡូក្រាមដោយសារតែខ្វះអាហារ។

នៅថ្ងៃសុក្រទី ១៨ ខែមករាចៅក្រម Olivia Low បានរកឃើញ Linda Seah Lei Sie អាយុ ៣៩ ឆ្នាំ និងស្វាមីរបស់នាងឈ្មោះ Lim Toon Leng អាយុ ៤៤ ឆ្នាំមានទោសកំហុសពីបទរំលោភបំពានលើជនជាតិភូមា បន្ទាប់ពីការកាត់ទោសរយៈពេល ១៥ ថ្ងៃកន្លងមកនេះ។

Seah ដែលគ្រប់គ្រងហាងកែសម្ផស្ស Anew Me Beauty នៅមជ្ឈមណ្ឌលផ្សារទំនើប Centrepoint នៅផ្លូវ Orchard ត្រូវបានកាត់ទោសពីបទបំពារបំពាន ៥ ករណី ហើយមួយករណីបានបណ្តាលឱ្យអ្នកបម្រើនោះផឹកទឹកដែលមានជាតិពុលទៀត។ ចៅក្រមបានរកឃើញប្តីរបស់នាងមួយករណីដោយបានដាក់ក្បាលនាងក្នុងផ្ទះរបស់នាងមានពិរុទ្ធពីបទរំលោភបំពានមួយផងដែរ។ គូស្វាមីភរិយាជនជាតិសិង្ហបុរីនេះ ដែលមានកូនស្រីអាយុ ៥ ឆ្នាំបានប្រព្រឹត្តបទល្មើសនៅក្នុងផ្ទះល្វែងរបស់ពួកគេនៅ Punggol Walk ក្នុងចន្លោះពីខែសីហាដល់ខែតុលាឆ្នាំ ២០១៦ ៕

# ថ្ងៃទី២៣ ខែមករា ឆ្នាំ២០១៩

## ជប៉ុនផ្តល់ថវិកា $២ លានដល់គម្រោងឆ្លើយតបអំពើហិង្សាលើកុមារ

https://www.postkhmer.com/ វ៉ន ដារ៉ា | Publication date 23 January 2019 | 10:14 ICT

ភ្នំពេញៈ រាជរដ្ឋាភិបាលកម្ពុជា រដ្ឋាភិបាលជប៉ុន និងមូលនិធិសហប្រជាជាតិដើម្បីកុមារ (Unicef) បានប្រកាសផ្សព្វផ្សាយគម្រោងបង្ការ និងឆ្លើយតបនឹងអំពើហិង្សាលើកុមារ ក្នុងប្រទេស កម្ពុជា ក្នុងការពន្លឿនចំណាត់ការដើម្បីបញ្ចប់រាល់គ្រប់ទម្រង់ នៃអំពើហិង្សាលើកុមារ។ នេះបើតាមសេចក្តីប្រកាសព័ត៌មានរួមមួយកាលពីម្សិលមិញ។ សេចក្តីប្រកាសរួមនេះឲ្យដឹងថាក្រោមកិច្ចគាំទ្រថវិកាពីជំនួយអភិវឌ្ឍផ្លូវការរបស់ប្រទេសជប៉ុន ដែលមានទឹកប្រាក់សរុបចំនួន ២ លានដុល្លារអាមេរិកគម្រោងនេះ នឹងជួយបង្កើនសមត្ថភាពរបស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការពន្លឿនការអនុវត្តផែនការ សកម្មភាព ដើម្បីទប់ស្កាត់ និងឆ្លើយតប ចំពោះអំពើហិង្សាលើកុមារ ឆ្នាំ ២០១៧-២០២១ ពង្រីកអន្តរាគមន៍សំខាន់ៗ សាកល្បងវិធានការច្នៃប្រឌិតថ្មីៗ និងអនុវត្តក្របខ័ណ្ឌ INSPIRE ដែលជាកម្រងយុទ្ធសាស្ត្រ ៧ ចំណុច ដើម្បីបញ្ចប់អំពើហិង្សាលើកុមារប្រកបដោយប្រសិទ្ធភាព។ បើតាមសេចក្តីប្រកាសព័ត៌មាននេះកម្ពុជា មានកុមារជាងពាក់កណ្តាលក្នុងចំណោមកុមារទាំងអស់បានទទួលរងអំពើហិង្សាយ៉ាងហោចណាស់ក្នុងមួយទម្រង់ មុនពេលពួកគេឈានដល់អាយុ ១៨ ឆ្នាំ។ សេចក្តីប្រកាសបញ្ជាក់ថា៖ «បើទោះបីជាមានបញ្ហាធ្ងន់ធ្ងរជាច្រើន ទាក់ទងនឹងកិច្ចការពារដែលកុមារបានជួបប្រទះក៏ដោយក៏ប្រព័ន្ធកិច្ចគាំពារកុមាររបស់កម្ពុជាភាគច្រើនមិនទទួលបានមូលនិធិគាំទ្រគ្រប់គ្រាន់ឡើយ»។

លោក វង សូត រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ថ្លែងនៅក្នុងពិធីចុះហត្ថលេខាផ្តល់ជំនួយនេះនៅក្រសួងពីម្សិលមិញថា ដើម្បីរួមចំណែកដល់ការសម្រេចឲ្យបាននូវគោលដៅអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាព ក្រសួងសង្គមកិច្ច កំពុងដឹកនាំកិច្ចខិតខំប្រឹងប្រែងនៅថ្នាក់ជាតិ ដើម្បីពង្រឹងប្រព័ន្ធកិច្ចការពារកុមារ។ លោកបន្តថា៖ «ការបង្កើតឲ្យមាននូវប្រព័ន្ធកិច្ចការពារកុមារមួយដែលមានការសម្របសម្រួលទូទាំងប្រទេស ព្រមជាមួយបុគ្គលិកមានជំនាញ និងសមត្ថភាព នឹងជួយដល់កុមារដែលបានទទួលរងអំពើហិង្សាការកេងប្រវ័ញ្ចនិងការរំលោភបំពាន ឲ្យទទួលបានការថែទាំ និងកិច្ចគាំទ្រ ដែលពួកគេត្រូវការព្រមទាំងជួយបង្ការអំពើហិង្សានៅពេលអនាគត»។ លោក វង សូត លើកឡើងថា ទន្ទឹមនឹងការអភិវឌ្ឍសកលភាវូបនីយកម្ម និងបច្ចេកវិទ្យា បញ្ហាជាច្រើនបាននិងកំពុងប្រឈមសម្រាប់ប្រទេសអភិវឌ្ឍន៍ និងប្រទេសកំពុងអភិវឌ្ឍន៍នោះគឺ «បញ្ហាអំពើហិង្សាលើកុមារ»។ «អំពើហិង្សាលើកុមារ គឺជាសកម្មភាពដែលមិនអាចអត់ឱនបាន ទោះនៅក្នុងរូបភាពណាក៏ដោយ ព្រោះថា អំពើហិង្សាធ្វើឲ្យប៉ះពាល់ដល់ការអភិវឌ្ឍរបស់កុមារ សីលធម៌សង្គម សេចក្តីថ្លៃថ្នូរ និងការអភិវឌ្ឍធនធានមនុស្សនាពេលអនាគត»។ បើតាមលោក វង សូតកម្ពុជាបានក្លាយជាប្រទេសឈានមុខក្នុងបណ្តាប្រទេសអាស៊ានដែលបានធ្វើការអង្កេត សិក្សាស្រាវជ្រាវពីស្ថានភាពអំពើហិង្សាលើកុមារ ដែលមានលក្ខណៈវិទ្យាសាស្ត្រ ក្នុងការកំណត់ពីទំហំ វិសាលភាព ការផ្តល់ភ័ស្តុតាងជាក់លាក់នៃអំពើហិង្សាលើកុមារទាំងផ្លូវភេទ ផ្លូវកាយ និងផ្លូវចិត្ត ដែលកុមារបានជួបប្រទះនិងកំពុងប្រឈម។

លោក Hidehisa HORINOUCHI ឯកអគ្គរាជទូតជប៉ុនប្រចាំកម្ពុជា បានទទួលស្គាល់ថាកិច្ចការពារកុមារ គឺជាវិស័យអាទិភាពមួយ។ លោកថា រដ្ឋាភិបាលជប៉ុនបានផ្តល់ហិរញ្ញប្បទានឥតសំណងជាទឹកប្រាក់ចំនួន ២ លានដុល្លារអាមេរិក ដល់អង្គការយូនីសេហ្វ ដើម្បីគាំទ្រដល់ក្រសួងពាក់ព័ន្ធក្នុងការអនុវត្តសកម្មភាពកិច្ចការពារកុមារ។ «ខ្ញុំជឿជាក់ថា ហិរញ្ញប្បទានឥតសំណងនេះ មានសារៈប្រយោជន៍សម្រាប់ការអភិវឌ្ឍមួយដ៏ល្អដល់ស្មារតីកុមារជាច្រើន ដែលពួកគេនឹងរួមចំណែកអភិវឌ្ឍអនាគតរបស់ប្រទេស កម្ពុជា» ។

លោកស្រី Natascha Paddison ប្រធានស្តីទីអង្គការយូនីសេហ្វប្រចាំកម្ពុជា ថ្លែងថា គម្រោងនេះ នឹងបន្តពង្រឹងសមត្ថភាពរបស់រាជរដ្ឋាភិបាលកម្ពុជា ដើម្បីឲ្យមានប្រព័ន្ធកិច្ចការពារកុមារមួយដែលដំណើរការនិងសម្របសម្រួលល្អ ដើម្បីអាចបង្ការ និងឆ្លើយតប ទៅនឹងអំពើហិង្សាលើកុមារឲ្យកាន់តែមានប្រសិទ្ធភាព។

«ជាលទ្ធផល កុមារងាយរងគ្រោះជាង ១ លាននាក់ នឹងទទួលបានកិច្ចការពារកាន់តែប្រសើរ ដើម្បីចៀសផុតពីអំពើហិង្សាតាមរយៈក្របខ័ណ្ឌស្ថាប័ន និងក្របខ័ណ្ឌច្បាប់ដែលល្អជាងមុន។ ការអនុវត្តគម្រោងនេះប្រកបដោយជោគជ័យនោះនឹងធ្វើឲ្យប្រទេសកម្ពុជា ក្លាយជាប្រទេសឈានមុខគេ ក្នុងតំបន់សម្រាប់ការប្រយុទ្ធប្រឆាំងដើម្បីបញ្ចប់អំពើហិង្សាលើកុមារ»៕ Contact author: វ៉ន ដារ៉ា

## ថ្ងៃទី២៤ ខែមករា ឆ្នាំ២០១៩

### និស្សិតក្រីក្រជាច្រើននាក់រងគ្រោះដោយសារ តែចាញ់បោកអគ្គនាយកសាលាភាសាជប៉ុន CL

http://nokorwatnews.com/ 23-01-2019

ភ្នំពេញ ៖ មាននិស្សិតមកពីតាមបណ្តា ស្រុក និងខេត្តជាច្រើននាក់បានរងគ្រោះ អស់ប្រាក់ជាច្រើនពាន់ដុល្លារ ដោយសារតែអគ្គនាយកមជ្ឈមណ្ឌលបណ្តុះបណ្តាលភាសា ជប៉ុន CL មិនគោរពតាមពាក្យសន្យា ហើយ បានប្រើល្បិចទុច្ចរិតបោកប្រាស់ យកលុយពួកគាត់អស់រាប់ពាន់ដុល្លារក្នុងម្នាក់ៗដោយមិនបានចេញទៅប្រទេសជប៉ុន ដូចការសន្យានោះឡើយ ។ រឿងនិស្សិតក្រីក្រដែលមកពីតាម បណ្តាស្រុក និងខេត្តហើយសិក្សាភាសា ជប៉ុនដើម្បីចេញរកការងារធ្វើនៅប្រទេសជប៉ុន តែ ត្រូវបានចាញ់បោកអគ្គនាយក មជ្ឈមណ្ឌល បណ្តុះបណ្តាលភាសាជប៉ុន CL ខាងលើនេះ មានរហូតដល់ជិត២០នាក់ សុទ្ធសឹង តែជាកូនចៅប្រជាពលរដ្ឋក្រីក្រ។

ជនរងគ្រោះជាច្រើននាក់បានអស់ សង្ឃឹម ពេលទៅជួបជាមួយនឹងអគ្គនាយក ដើម្បីសុំថវិកាមកវិញ តែគ្មានការឆ្លើយតប ទើបពួកគេទៅពឹងពាក់មេធាវីឲ្យជួយ និងបានដាក់ពាក្យបណ្តឹងទៅក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈដើម្បីឲ្យជួយ ធ្វើ អន្តរាគមន៍ទៅលើមជ្ឈមណ្ឌលបណ្តុះ បណ្តាលភាសាជប៉ុន CL ដែលបានបោក ប្រាស់យកលុយរបស់ពួកគេក្នុងម្នាក់ៗ អស់រាប់ពាន់ដុល្លារ ។

នៅក្នុងពាក្យបណ្តឹងប្តឹងទៅកាន់ សាលាដំបូងរាជធានីភ្នំពេញក៏ដូចជាទៅក្រសួងការងារឲ្យជួយធ្វើអន្តរាគមន៍រឿងខាងលើនេះគឺក្នុងពាក្យបណ្តឹងនោះបានប្តឹង ឈ្មោះ ឈាង ធុំ និងប្រពន្ធឈ្មោះ អ៊ឹង គឹមលាង ដែលមានអាសយដ្ឋាននៅភូមិ ម៉ល សង្កាត់ដង្កោ ខណ្ឌដង្កោ រាជធានី ភ្នំពេញពាក់ព័ន្ធនឹងករណីឆបោក ។

បើតាមជនរងគ្រោះជានិស្សិតដែល ចាញ់បោកជនខាងលើនេះបានឲ្យដឹងថា ពួកគេទាំងអស់គ្នាបានបំពេញបែបបទ ចូលរៀន ដំបូងដែលតម្រូវឲ្យបង់ប្រាក់ចំនួន៣០០ដុល្លារដើម្បីទៅធ្វើការនៅប្រទេស ជប៉ុន ហើយ បន្ទាប់ពីបានសិក្សាអស់រយៈពេលជាច្រើនខែមក ឈ្មោះ ឈាង ធុំ បានឲ្យជនជាតិជប៉ុនម្នាក់មកធ្វើកិច្ចសម្ភាសន៍ពួកខ្លួនទាំងអស់គ្នាដោយអះអាងថាខ្លួនគេជានិយោជកនៅឯប្រទេសជប៉ុន ប៉ុន្តែជាក់ ស្តែងជនជាតិជប៉ុនរូបនេះគ្រាន់តែជាបុគ្គលិកក្រុមហ៊ុនឯកជនមួយដែលស្ថិតក្នុង ប្រទេសកម្ពុជាប៉ុណ្ណោះ ។ ក្រោយមក ឈ្មោះ ឈាង ធុំ បានប្រើឧបាយកលទុច្ច រិតនិងបានប្រាប់ពួកខ្លួនជានិស្សិតដែល កំពុងសិក្សានៅក្នុងមជ្ឈមណ្ឌលបណ្តុះ បណ្តាលភាសាជប៉ុន CL ខាងលើថាបានប្រឡងជាប់ទៅធ្វើការនៅប្រទេសជប៉ុនហើយដោយតម្រូវឲ្យជនរងគ្រោះទាំងអស់បង់ប្រាក់ដើម្បីរៀបចំឯកសារទិដ្ឋាការ (វីសា) ដើម្បីទៅធ្វើការនៅប្រទេសជប៉ុនដែលក្នុងនោះឈ្មោះ ឈាង ឈុំ បានឲ្យជន រងគ្រោះបង់ប្រាក់ ក្នុងម្នាក់ៗ១.៧០០ដុល្លារនិងមានខ្លះទៀតអស់រហូតជិត ៥.០០០ ដុល្លារតែលទ្ធផលអ្វីៗទាំងនោះអត់មាន បានប្រយោជន៍អ្វី បន្តិចសោះដោយរង់ចាំពីមួយទៅមួយថ្ងៃរហូតជាច្រើនខែទើបដឹងថា ពួកគេចាញ់បោកអគ្គនាយកមជ្ឈមណ្ឌល បណ្តុះបណ្តាលភាសាជប៉ុន CL ខាងលើ នេះ ។

បើតាមប្រភពព័ត៌មានខាងលើបានឲ្យ ដឹងថា ឈ្មោះ ឈាង ធុំ បានដើរតួនាទី ខ្លួនឯងជាអគ្គនាយកផង និងជាប្រធាន ក្រុមប្រឹក្សាភិបាលផង ហើយពេលក្រសួង ការងារកោះអញ្ជើញមិនដែលឃើញវត្ត មានលោក ឈាង ធុំ ចូលខ្លួននោះទេ គឺលេចមុខអ្នកផ្សេងទៅវិញ ។ ប្រភពបានឲ្យដឹងទៀតថា មិនមែនជន រងគ្រោះជិត២០នាក់ប៉ុណ្ណោះទេ ដែលចាញ់បោកលោក ឈាង ធុំ ផ្ទុយទៅវិញមានជនរងគ្រោះជាច្រើននាក់ទៀតក៏រងគ្រោះបែបនេះដែរហើយពួកគេបាន សំណូមពរឲ្យ លោក អិត សំហេងរដ្ឋមន្ត្រី ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈមេត្តាជួយពិនិត្យលើទីតាំងមជ្ឈមណ្ឌលបណ្តុះបណ្តាល ភាសាជប៉ុន CL ខាងលើ នេះផងកុំឲ្យប្រជាពលរដ្ឋក៏ដូចជាអ្នកក្រោយៗទៀតរងគ្រោះដូចពួកខ្លួនខាតទាំងពេលវេលាបាត់បង់ទាំងប្រាក់ហើយមិនបានចេញទៅក្រៅ ប្រទេសទៀត ។

ជុំវិញការលើកឡើងរបស់ជនរងគ្រោះ ដែលជានិស្សិតខាងលើនេះ ភ្នាក់ងារយក ព័ត៌មាននគរវត្តមិនអាចសុំការបកស្រាយ ពីលោក ឈាង ធុំ និងភរិយាបាននោះទេ ដោយគ្មានលេខទូរស័ព្ទទំនាក់ទំនង ៕ អារុណរះ

## កម្ពុជាត្រូវត្រៀមខ្លួនទៅធ្វើការនៅជប៉ុនដើម្បីបានប្រាក់ខែខ្ពស់

https://kohsantepheapdaily.com.kh/ ថ្ងៃទី ២៣ ខែ មករា ឆ្នាំ ២០១៩ ម៉ោង ១៧:០៤

រាជធានីភ្នំពេញ ៖ ខណៈដែលពលករកម្ពុជា បានកំពុងតែបំរើការងារនៅតាមបណ្តាប្រទេសនានារាប់លាននាក់ ពិសេសប្រទេសថៃដែលមានចំនួនច្រើនជាងគេនោះ ប្រជាជនកម្ពុជាប្រមាណជាង៩ពាន់នាក់ បានកំពុងធ្វើការនៅក្នុងប្រទេសជប៉ុនក្នុងនាមជាកម្មសិក្សាការី។ ឥឡូវជប៉ុនបានបើកឱកាសដល់ប្រជាជនកម្ពុជា អាចទៅបំពេញការងារ ក្នុងនាមជាពលករដែលអាចនឹងទទួលបានប្រាក់ខែច្រើនជាងមុន ។ ប្រជាជនកម្ពុជាជាច្រើន សម្រេចចិត្តឆ្លងកាត់ប្រទេសពីប្រទេសមួយទៅប្រទេសមួយរបស់ពលករខ្មែរនោះគឺដើម្បីស្វែងរកប្រាក់ ដើម្បីមកផ្គត់ផ្គង់ជីវភាពគ្រួសារនៅស្រុកកំណើត ដែលអ្នកខ្លះបានកំពុងជួបការខ្វះខាត។

ទាក់ទិននឹងពលករទៅបំរើការងារនៅក្រៅប្រទេសនេះ ពិសេសនោះប្រទេសជប៉ុនត្រូវបានលោក អ៊ិត សំហេង រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈបានឲ្យដឹងថា គិតមកដល់ពេលនេះ កម្ពុជាមានកម្មសិក្សាការីចេញទៅធ្វើការនៅជប៉ុនមានចំនួនប្រមាណជាង៩ពាន់នាក់។ កម្ពុជានិងជប៉ុន កំពុងតែរកវិធី ដើម្បីអោយប្រជាជនកម្ពុជាអាចទៅបំពេញការងារនៅជប៉ុន ក្នុងនាមជាពលករដែលនឹងអាចអោយពួកគេអាចរកប្រាក់ចំណូលបានច្រើនជាងការបំពេញការងារក្នុងនាមជាកម្មសិក្សាការី ៕

## តំពូលស៊ើបឡើងវិញ ករណីស្ត្រីនាំក្មេងស្រីគឲ្យគេរំលោភសេពសន្ថវៈ

https://www.postkhmer.com/ គីម សារុំ | Publication date 24 January 2019 | 09:46 ICT

ភ្នំពេញៈ តុលាការកំពូលពីម្សិលមិញបានប្រកាសសាលដីកាសំណុំរឿងស្ត្រីជាប់ចោទម្នាក់ដោយសម្រេចស៊ើបអង្កេតឡើងវិញ (ចាត់របៀប) បន្ទាប់ពីជំនុំជម្រះអសាធារណៈកាលពីថ្ងៃទី ៩ មករា ពាក់ព័ន្ធនឹងការនាំក្មេងស្រី (គ) មិនគ្រប់អាយុម្នាក់ឲ្យបុរសម្នាក់រំលោភសេពសន្ថវៈប្រព្រឹត្តក្នុងឆ្នាំ ២០១៣ នៅរាជធានីភ្នំពេញ។ នៅក្នុងបន្ទប់សវនាការពីម្សិលមិញ លោកចៅក្រម សឹង បញ្ញាវុឌ្ឍ បានអានសាលដីកាចំពោះមុខស្ត្រីជាប់ចោទនិងកំបាំងមុខក្មេងស្រីរងគ្រោះថា ក្រោយពីបានស្តាប់ការសន្និដ្ឋានរបស់តំណាងមហាអយ្យការនិងស្តាប់ការសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទនិងក្រោយស្តាប់ចម្លើយរបស់ក្មេងស្រីរងគ្រោះនិងស្ត្រីជាប់ចោទពេលសវនាការមក ក្រុមប្រឹក្សាជំនុំជម្រះយល់ឃើញថា៖ «សំណុំរឿងនេះហាក់មិនទាន់មានភ័ស្តុតាងឲ្យបានច្បាស់លាស់ទាក់ទងនឹងស្ត្រីជាប់ចោទទេ។ដូច្នេះតុលាការកំពូលសម្រេចចាត់របៀបសំណុំរឿងនេះឡើងវិញ»។

បន្ទាប់ពីប្រកាសសាលដីកានេះ ស្ត្រីជាប់ចោទ ឈ្មោះ អែម សុភា អាយុ ៥៤ ឆ្នាំ មិនអាចសុំអត្ថាធិប្បាយបានទេ ប៉ុន្តែកាលពីថ្ងៃបើកសវនាការជំនុំជម្រះអសាធារណៈនាថ្ងៃទី ៩ មករាឆ្នាំ ២០១៩ ស្ត្រីជាប់ចោទបានប្រាប់ភ្នំពេញប៉ុស្តិ៍ថា ដំបូងឡើយគាត់មានកូនស្រីម្នាក់ជាមនុស្សគរៀននៅសាលាគថ្លង់ជាមួយក្មេងស្រីរងគ្រោះ (ស.គ) អាយុ ១៤

ឆ្នាំ ក្នុងខណ្ឌច្បារអំពៅ។ ស្ត្រីជាប់ចោទបន្តថាពេលចូលរៀននោះកូនរបស់គាត់និងក្មេងរងគ្រោះជាពួកម៉ាកគ្នាហើយក្មេងរងគ្រោះឧស្សាហ៍ទៅលេងផ្ទះគាត់នៅចាក់អង្រែក្រោម។នៅថ្ងៃមួយក្មេងរងគ្រោះបានស្នាក់នៅផ្ទះគាត់ ១ យប់ដោយគាត់ឲ្យនាងដេកជាមួយកូនស្រីគាត់ហើយមិនបានប៉ះពាល់អ្វីដល់ក្មេងរងគ្រោះទេ។ ប៉ុន្តែ ២ ខែក្រោយមកមានអង្គការមួយឈ្មោះក្តីសង្ឃឹមថ្មីនៃកុមារកម្ពុជាបានប្តឹងទៅសមត្ថកិច្ចឲ្យចាប់ខ្លួនគាត់តែម្តង។ សំណុំរឿងនេះ បើតាមស្ត្រីជាប់ចោទប្រាប់ភ្នំពេញប៉ុស្តិ៍ពេលបើកសវនាការថាគាត់ត្រូវបានសាលាដំបូងរាជធានីភ្នំពេញផ្តន្ទាទោសកាលពីខែកុម្ភៈឆ្នាំ ២០១៤ ដាក់ពន្ធនាគារ ១៥ ឆ្នាំចោទពីបទលក់ដូរមនុស្សដោយមានគោលបំណងនិងរំលោភសេពសន្ថវៈតាមមាត្រា ១៥ នៃច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្សនិងធ្វើអាជីវកម្មផ្លូវភេទ។ ស្ត្រីជាប់ចោទ បានប្រាប់ថា៖ «តាមពាក្យបណ្តឹងថា គេហែកដៃ ហែកជើងនាងរំលោភ ប៉ុន្តែតាមពិតគ្មានទេ។ ព្រោះពេលបើកសវនាការនៅសាលាដំបូងរាជធានីភ្នំពេញមានសាក្សីចូលបំភ្លឺ រីឯលិខិតកោសល្យវិច័យវិញមានស្នាមកោសលុបផង ខ្ញុំពិតជាមិនបានធ្វើអ្វីលើក្មេងស្រីម្នាក់នេះទេ...»។

កាលពីម្សិលមិញភ្នំពេញប៉ុស្តិ៍មិនអាចទាក់ទងទៅអង្គការក្តីសង្ឃឹមនៃកុមារកម្ពុជាបានទេ ប៉ុន្តែកាលពីខែកុម្ភៈឆ្នាំ ២០១៤ លោក សុខ ផល្លា នាយកប្រតិបត្តិនៃអង្គការនេះធ្លាប់បានប្រាប់កាសែតភ្នំពេញប៉ុស្តិ៍ថាជនរងគ្រោះរូបនេះគឺជាក្មេងកំព្រាដែលមានផ្ទុកមេរោគអេដស៍តាំងពីកំណើត ដោយឪពុកម្តាយនាងបានស្លាប់ដោយសារជំងឺអេដស៍នៅខេត្តកោះកុងតាំងពីនាងអាយុ ៥ ខែ។កាលពីឆ្នាំ ២០០៧ ក្មេងស្រីរងគ្រោះត្រូវបានអង្គការក្តីសង្ឃឹមថ្មីយកទៅចិញ្ចឹមក្នុងមណ្ឌលក្តីសង្ឃឹមថ្មីនៅខេត្តកំពង់ស្ពឺហើយក្រោយមកត្រូវបានបញ្ជូនមកស្នាក់ក្នុងមណ្ឌលក្តីសង្ឃឹមថ្មីនៅក្រុងតាខ្មៅខេត្តកណ្តាលដើម្បីងាយស្រួលធ្វើដំណើរទៅសិក្សាភាសាគថ្លង់ជាមួយនឹងកុមារគ-ថ្លង់ ជាច្រើនរូបទៀតក្នុងសង្កាត់ច្បារអំពៅ ខណ្ឌមានជ័យ។ លោក សុខ ផល្លា ធ្លាប់បានបញ្ជាក់ថា៖ «នៅថ្ងៃទី១៥ ខែ មិថុនាឆ្នាំ ២០១៣ (ស្រីគ) បានបាត់ខ្លួនពីមណ្ឌលដោយមិនដឹងដំណឹងអ្វីទាំងអស់ធ្វើឲ្យខ្ញុំនិងបុគ្គលទាំងអស់ព្រួយបារម្ភនិងបានចែកគ្នាដើរតាមរកនាង។

លុះដល់ថ្ងៃទី១៨ ខែមិថុនាឆ្នាំ២០១៣ ទើបនាងវិលត្រឡប់ មកកាន់មណ្ឌលវិញដោយមានអាការស្លេកស្លាំងនិងមានស្នាមដំបៅនៅត្រង់កដៃនិងជើង»។ លោក ផល្លា បន្ថែមថា បន្ទាប់ពីការសាកសួរ «ស្រីគ» បានឲ្យដឹងថានាងត្រូវបានស្ត្រីជាប់ចោទឈ្មោះ អែម សុភា ចាប់ចងដៃចងជើងនៅក្នុងផ្ទះរបស់គាត់ហើយបាននាំយកទៅឲ្យរួមភេទជាមួយបុរសចំណាស់ម្នាក់ដែលជាដៃគូលេងល្បែងរបស់គាត់នៅប៉ុលឌីងកាលពីថ្ងៃទី ១៥ ខែមិថុនាឆ្នាំ ២០១៣ ។បន្ទាប់ពីការរួមភេទរួចស្ត្រីជាប់ចោទអែមសុភា បានប្រគល់លុយឲ្យនាងគត្រឹមតែ ២ ពាន់រៀលប៉ុណ្ណោះ។ លោកសុខ ផល្លា បានបញ្ជាក់ទៀតថា៖ «យោងតាមការធ្វើកោសល្យវិច័យពីសំណាក់គ្រូពេទ្យជំនាញទៅលើប្រដាប់ភេទរបស់ក្មេងស្រីរងគ្រោះឃើញថា ប្រដាប់ភេទរបស់នាងមានស្នាមរបួសដែលបណ្តាលមកពីការរំលោភសេពសន្ថវៈ»។

ករណីនេះ អង្គការក្តីសង្ឃឹមថ្មីក្នុងនាមជាអាណាព្យាបាលរបស់ក្មេងស្រីរងគ្រោះបានប្តឹងទាមទារជំងឺចិត្តពីស្ត្រីជាប់ចោទចំនួន ២០ លានរៀល និងសុំឲ្យតុលាការផ្តន្ទាទោសស្ត្រីជាប់ចោទឲ្យបានធ្ងន់ធ្ងរទៅតាមផ្លូវច្បាប់៕

## កម្មករសំណង់ជាង ១០ នាក់ស្លាប់ និងរបួសយ៉ាងអណោចអធ័មក្នុងហេតុការណ៍បាក់ដែកស្ទូចក្នុងការដ្ឋានសាងសង់ខុនដូនៅប្រទេសថៃ

https://khmernote.com/news/ January 24, 2019

ថៃ៖ កម្មករសំណង់ចំនួន៥ នាក់ស្លាប់ និង ៦ នាក់ផ្សេងទៀតបានរងរបួសធ្ងន់ ក្នុងហេតុការណ៍បាក់ដែកស្ទូចដែលគេប្រើសម្រាប់ស្ទូចកម្មករសំណង់ទៅធ្វើការងារនៅកន្លែងខ្ពស់ៗ។ ហេតុការណ៍នេះបានកើតឡើងក្នុងការដ្ឋានសាងសង់អគារខុនដូមួយកន្លែងក្នុងទីក្រុងបាងកកប្រទេសថៃ។ បើតាមសាក្សីនៅកន្លែងកើតហេតុបានប្រាប់ឲ្យដឹងថាក្រោយកើតមានគ្រោះថ្នាក់នេះកម្មករ ៥ នាក់បានស្លាប់ភ្លាមៗតែម្តង ដោយមានអ្នកខ្លះបានស្លាប់ដោយព្យួរសាកសពនៅលើអាកាសទៀតផង។ ដំបូងឡើយគេបានរកឃើញជនរងគ្រោះ ៥ នាក់ប៉ុណ្ណោះ ហើយបន្តិចក្រោយមកទើបគេ

បានប្រទះឃើញជនរងគ្រោះម្នាក់ទៀតដែលត្រូវកប់ដោយបំណែកជណ្តើរ ហើយជនរងគ្រោះដែល គេបានរកឃើញក្រោយគេនោះគឺរងរបួសធ្ងន់ជាងគេ ដែលអាចប្រឈមនឹងការស្លាប់បាត់បង់ជីវិតទៀតផង។ លោក Opas Sripayak ប្រធានក្រុមហ៊ុនសាងសង់ខុនដូខាងលើបានឲ្យដឹងថា នេះជាគ្រោះថ្នាក់ដ៏កម្រមួយសម្រាប់ក្រុមហ៊ុនរបស់លោក ហើយក្រុមហ៊ុននឹងទូទាត់ប្រាក់សំណងគ្រប់ចំនួនទៅកាន់គ្រួសារកម្មករដែលបានស្លាប់ និងរបួស៕

## ថ្ងៃទី២៥ ខែមករា ឆ្នាំ២០១៩

## ឯកឧត្តម អ៊ិត សំហេង៖ គិលានុបដ្ឋាក គិលានុបដ្ឋាយិកាកម្ពុជានឹងទទួលបានទីផ្សារការងារក្នុងកម្រិតអន្តរជាតិ និងប្រាក់កម្រៃខ្ពស់ នៅជប៉ុន

http://www.mlvt.gov.kh/index.php Thursday, 24 January 2019 16:27 Written by MLVT

(ភ្នំពេញ)៖ នេះជាឱកាសថ្មីមួយទៀតដល់និស្សិតដែលកំពុងសិក្សាផ្នែកគិលានុបដ្ឋាកតាមគ្រឹះស្ថានសិក្សានានា ទទួលបានទីផ្សារការងារក្នុងកម្រិតអន្តរជាតិ ទទួលបានប្រាក់កម្រៃខ្ពស់ ពិសេសរួមចំណែកជាមួយ រាជរដ្ឋាភិបាលកម្ពុជា ក្នុងការស្វែងរកការងារជូនប្រជាពលរដ្ឋ តាមរយៈការពង្រីកទីផ្សារការងារ និងលើកស្ទួយមុខមាត់ប្រទេសកម្ពុជា នៅក្នុងតំបន់ ក៏ដូចជាសាកលលោក នេះជាប្រសាសន៍លើកឡើងរបស់ ឯកឧត្តម បណ្ឌិត អ៊ិត សំហេង រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ថ្លែងក្នុងពិធីសម្ពោធជាផ្លូវការក្រុមហ៊ុន ជេ អិល អេស ខេមបូឌាន និងសិក្ខាសាលាស្តីពីការស្វែងយល់ និងឱកាសការងារផ្នែកគិលានុបដ្ឋាកនៅប្រទេសជប៉ុន នៅថ្ងៃទី២៤ ខែមករា ឆ្នាំ២០១៩ នៅសណ្ឋាគារសូហ្វីតែលភូកេត្រា រាជធានីភ្នំពេញ។

ឯកឧត្តមរដ្ឋមន្ត្រីមានប្រសាសន៍ថា ការបណ្តុះបណ្តាលបន្ថែម ដើម្បីបំពេញតាមស្តង់ដាជប៉ុនដល់បេក្ខជនបេក្ខនារី និងការសិក្សាភាសា និង វប្បធម៌ ប្រពៃណីជនជាតិជប៉ុន នឹងជួយពង្រឹងគុណភាពលើការបណ្តុះបណ្តាលគិលានុបដ្ឋាក គិលានុបដ្ឋាយិកាកម្ពុជា ក៏ដូចជាទាក់ទាញចំណាប់អារម្មណ៍របស់ក្មេងជំនាន់ក្រោយៗ អោយចាប់អារម្មណ៍លើជំនាញនេះកាន់តែខ្លាំងក្លា ដើម្បីបំពេញនូវតម្រូវការទីផ្សារការងារជាលក្ខណៈអន្តរជាតិ ។ បុគ្គលិកដែលចប់កិច្ចសន្យាការងារហើយត្រលប់មកធ្វើការក្នុងស្រុកវិញ នឹងក្លាយជាធនធានដ៏ល្អមួយ ដោយពួកគេនឹងយកចំណេះ និងបទពិសោធន៍ពីការងារនៅប្រទេសជប៉ុនមកជួយពង្រឹងវិស័យសុខាភិបាលក្នុងស្រុក។ ឯកឧត្តមបានអំពាវនាវដល់សាធារណជនទាំងអស់ ពិសេសសិស្ស និស្សិត អតីតនិស្សិតដែលបានរៀនចប់និងកំពុងស្វែងរកការងារ ឬកំពុងធ្វើការផ្នែកគិលានុបដ្ឋាក សូមសិក្សាស្វែងយល់ពីឱកាសការងារនៅប្រទេសជប៉ុនពាក់ព័ន្ធនឹងជំនាញគិលានុបដ្ឋាកនេះ អោយបានច្រើន តាមរយៈក្រុមហ៊ុន JLS Cambodian Co.,Ltd ដែលបានរៀបចំសិក្ខាសាលានេះ ។

បច្ចុប្បន្ន ក្រសួងបាននឹងកំពុងសហការ ជាមួយមន្ត្រីជំនាញនៃប្រទេសជប៉ុន ដើម្បីពិនិត្យ និងរៀបចំឱ្យមានកិច្ចព្រមព្រៀងសហប្រតិបត្តិការជាមួយគ្នា ក្នុងគោលបំណង ដើម្បីបង្កើនទីផ្សារការងារ និងឱកាសការងារដល់ប្រជាជនកម្ពុជា។ ដោយជប៉ុន បានចាប់ផ្តើមរៀបចំបង្កើតឱ្យមានគម្រោងថ្មី សម្រាប់បង្កើនលំហូរនៃកម្លាំងពលកម្មពីប្រទេសផ្សេងៗ និងសម្រាប់អនុវត្តនៅអំឡុងខែមេសា ឆ្នាំ២០១៩ខាងមុខនេះ ដើម្បីដោះស្រាយបញ្ហាកង្វះកម្លាំងពលកម្មជំនាញនៅជប៉ុន។ ទន្ទឹមនឹងនេះ រាជរដ្ឋាភិបាលក៏បានផ្តោតការយកចិត្តទុកដាក់ខ្ពស់បំផុត ក្នុងការគាំពារ ការការពារសិទ្ធ និងផលប្រយោជន៍ពលករខ្មែរយើងនៅបរទេស តាមរយៈកិច្ចសហប្រតិបត្តិការជាមួយរដ្ឋាភិបាលនៃប្រទេសទទួល និងការពង្រឹងការអនុវត្តច្បាប់ និងបទដ្ឋាននានា ដោយប្រើប្រាស់គោលការណ៍ យន្តការ និងនីតិវិធី ស្របតាមបទដ្ឋានអន្តរជាតិ។ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ កំពុងបន្តខិតខំពង្រឹងការអនុវត្តឱ្យ ស្របទៅតាមកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ ដែលក្នុងនោះមានចែងអំពី ការបន្តពង្រឹងអភិបាលកិច្ចទេសន្តរប្រវេសន៍ការងារ និងពង្រីកកិច្ចសហប្រតិបត្តិការពហុភាគី និងទ្វេភាគី ដើម្បីបើកទូលាយទីផ្សារការងារស្របច្បាប់នៅក្រៅប្រទេស, ទប់ស្កាត់ទេសន្តរប្រវេសន៍ការងារដោយខុសច្បាប់, លើកកម្ពស់ការគាំពារសិទ្ធិ និងផលប្រយោជន៍ សុខភាព និងសុវត្ថិភាពការងារ, កិត្តិយស និងសេចក្តីថ្លៃថ្នូររបស់ពលករ ការផ្តល់ការសម្របសម្រួលទំនាក់ទំនងជាមួយ

គ្រួសារ និងការធ្វើសមាហរណកម្មពលករទេសន្តរប្រវេសន៍ ដែលធ្វើមាតុភូមិនិវត្ត តាមរយៈការទទួលស្គាល់ជំនាញ, ការផ្ទេររបបសន្តិសុខសង្គមមកក្នុងប្រទេស, ការផ្ដល់ប្រឹក្សាការងារធ្វើ និងការបង្កើតមុខរបរដោយខ្លួនឯង។ គូសបញ្ជាក់ថា បច្ចុប្បន្នទីភ្នាក់ងារជ្រើសរើសឯកជនមានចំនួន ១០៥ ដែលក្នុងនោះទីភ្នាក់ងារជ្រើសរើសឯកជនដែលទទួលអាជ្ញាបណ្ណអនុញ្ញាតអោយធ្វើការជ្រើសរើសបណ្ដុះបណ្ដាល បញ្ជូន និងគ្រប់គ្រងពលករទៅធ្វើការនៅក្រៅប្រទេស ដែលក្នុងនោះមានទីភ្នាក់ងារជ្រើសរើសចំនួន ៩៣ ដែលទទួលបានអាជ្ញាបណ្ណអនុញ្ញាត ពីក្រសួងអោយធ្វើការជ្រើសរើសបណ្ដុះបណ្ដាល បញ្ជូន និងគ្រប់គ្រងកម្មសិក្សាការីទៅធ្វើការនៅប្រទេសជប៉ុន។ គិតត្រឹមខែធ្នូ ឆ្នាំ២០១៨ កម្ពុជាបានបញ្ជូនកម្មសិក្សាការី សរុបចំនួន ៩,១៩៥នាក់ ទៅធ្វើកម្មសិក្សា និងធ្វើការនៅប្រទេសជប៉ុន ដោយពលករម្នាក់ៗទទួលបានប្រាក់ឈ្នួលជាមធ្យមប្រមាណ ១,៥០០ដុល្លារ សហរដ្ឋអាមេរិកក្នុងមួយខែ៕

## រដ្ឋមន្ត្រីក្រសួងការងារ៖ បច្ចុប្បន្នកម្ពុជាមានគ្រឹះស្ថាន សេដ្ឋកិច្ចក្នុងប្រព័ន្ធ និងក្រៅប្រព័ន្ធ ប្រមាណ៦០ម៉ឺន

https://kmnnews.com/kmnnews/ ចេញផ្សាយ ថ្ងៃទី 25 ខែ មករា ឆ្នាំ 2019 8

**កំពត៖** លោក អ៊ិត សំហេង រដ្ឋមន្ត្រីក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ បានថ្លែងថា ក្រោមការដឹកនាំរបស់សម្ដេចតេជោនាយករដ្ឋមន្ត្រី កម្ពុជាបានសម្រេចនូវសមិទ្ធផលដ៏ធំធេងក្នុងការពង្រឹងសន្តិភាព ស្ថិរភាព ដោយបង្កលក្ខណៈងាយស្រួលដល់ការធ្វើវិនិយោគ ដែលរហូតដល់បច្ចុប្បន្ននេះកម្ពុជា មានគ្រឹះស្ថានសេដ្ឋកិច្ចក្នុងប្រព័ន្ធ និងក្រៅប្រព័ន្ធចំនួនប្រមាណជាង៦០ម៉ឺន ដែលបង្កើតការងារដល់ប្រជាពលរដ្ឋរាប់លាននាក់ ។ លោករដ្ឋមន្ត្រីក្រសួងការងារ បានថ្លែងបែបនេះ ធ្វើឡើងក្នុងពិធីជួបសំណេះសំណាលរវាងសម្ដេចតេជោ ហ៊ុន សែន បាន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា និងកម្មករ កម្មការិនី ប្រមាណ១១,៧៣៨នាក់ មកពីរោងចក្រ សហគ្រាសចំនួន១២ នៅរោងចក្រស្បែកជើងពូ-ចិន(POU CHEN Cambodia CO., LTD) ដែលស្ថិតនៅក្នុងភូមិកណ្ដាលទួល ឃុំកំពង់ត្រាចខាងលិច ស្រុកកំពង់ត្រាច ខេត្តកំពត ។ លោករដ្ឋមន្ត្រីបានថ្លែងបន្តថា គ្រឹះស្ថាន សេដ្ឋកិច្ចក្នុងប្រព័ន្ធដែលបានចុះបញ្ជីនៅក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈមានចំនួនសរុបជិត ១ម៉ឺន ៣ពាន់ កើនឡើង ៨ភាគរយ និងមានកម្មករនិយោជិតសរុប ១លាន ៥សែននាក់ កើនជាង ២១ភាគរយ បើធៀបនឹងឆ្នាំ២០១៧ ។ កម្មករ និយោជិតទាំងអស់នេះរកប្រាក់ឈ្នួលជាមធ្យមជាង ៤ពាន់ ៨រយលានដុល្លារអាមេរិក ក្នុងនោះវិស័យកាត់ដេរសម្លៀកបំពាក់ និងផលិតស្បែកជើង មានកម្មករ និយោជិតជាង ៨សែន ៤ម៉ឺននាក់ ដែលមានប្រាក់ឈ្នួលសរុបជាង ២ពាន់ ៨រយលានដុល្លារក្នុងមួយឆ្នាំ ។

ដោយឡែកសហគ្រាស គ្រឹះស្ថានសេដ្ឋកិច្ចក្រៅប្រព័ន្ធសរុបមានចំនួនជិត ៦សែន មានកម្មករជាង ២លាន ៤សែន វិស័យកសិកម្មជាង ៤លាននាក់, ពលករធ្វើការនៅក្រៅប្រទេសមានប្រមាណ ១លាន ២សែននាក់ និងមន្ត្រីសាធារណៈមានចំនួនជាង ៥សែននាក់ ។ លោករដ្ឋមន្ត្រីបញ្ជាក់ថា ការដឹកនាំប្រទេសប្រកបដោយគតិបណ្ឌិត របស់ប្រមុខរាជរដ្ឋាភិបាលកម្ពុជា បានរក្សានូវកំណើនសេដ្ឋកិច្ចជាង៧% ជារៀងរាល់ឆ្នាំ និងបង្កើតការងារជូនកម្មករ និយោជិត អត្រាមានការងារធ្វើ ៩៩,៣% នៃកម្លាំងពលកម្ម សរុបប្រមាណជិត ១០លាននាក់ ៕

## ស្នងការខេត្តពោធិ៍សាត់ជម្រុញភាគីថៃពន្លឿននីតិវិធីក្នុងការបើកច្រកលេខ៥៦ថ្មជាឱ្យបានឆាប់

http://www.rasmeinews.com/ January 25, 2019, 10:38 AM21

ដោយ៖ពស/ពោធិ៍សាត់៖ភាគីកម្ពុជាបានជម្រុញភាគីថៃជួយពន្លឿននីតិវិធីក្នុងការបើកច្រកផ្លូវ៥៦ឱ្យបានឆាប់ដើម្បីជួយសម្រួលជីវភាពប្រជាជននៃប្រទេសទាំងពីរ។ ការស្នើសុំនេះគឺធ្វើឡើងនៅក្នុងកិច្ចជំនួបរបស់ក្រុមប្រតិភូថៃដឹកនាំដោយឧត្តមនាវីត្រីសាយ៉ាន់អែយៈរ៉ារ៉ាត់នាយសេនាធិការបញ្ជាការដ្ឋានការពារព្រំដែនច័ន្ទបូរីត្រាត។ជាមួយលោក

ឧត្តមសេនីយ៍ទោសារុនចាន់ធីស្នងការនគរបាលខេត្តពោធិ៍សាត់ក្នុងសប្តាហ៍នេះ នៅស្នងការដ្ឋាននគរបាលខេត្តពោធិ៍សាត់ ។

លោកឧត្តមនាវីត្រី សាយ៉ាន់ អៃយ:រ៉ារ៉ាត់ បានជម្រាបថាគោលបំណងដែលលោកបានដឹកនាំប្រតិភូសុំចូលជួបសំដែងការគួរសមនាពេលនេះគឺដើម្បីពង្រឹងចំណងមេត្រីភាពជាមួយថ្នាក់ដឹកនាំខេត្តពោធិ៍សាត់(ប្រទេសកម្ពុជា)និងខេត្តច័ន្ទបូរី-ខេត្តត្រាត(ប្រទេសថៃ)។ លើកិច្ចប្រតិបត្តិការបង្ក្រាប បទល្មើសគ្រឿងញៀន ការឆ្លងដែនខុសច្បាប់ និងពង្រឹកកិច្ចសហប្រតិបត្តិការ ការពារខ្សែបន្ទាត់ព្រំដែនរួមគ្នា ឲ្យបានល្អប្រសើរ និងបានសំណូមពរសូមឲ្យភាគីកម្ពុជាជួយផ្សព្វផ្សាយដល់ពលរដ្ឋខ្មែរបានយល់ដឹងអំពីច្បាប់នៅប្រទេសថៃផងដែរ។ លោកឧត្តមនាវីត្រី សាយ៉ាន់ អៃយ:រ៉ារ៉ាត់ ក៏បានសន្យាផងដែរថា ភាគីថៃ និងខិតខំជួយការពារពលរដ្ឋខ្មែរដែលចូលទៅធ្វើការងារនៅក្នុងប្រទេសថៃដោយស្របច្បាប់ផងដែរ។

ស្វាគមន៍ចំពោះដំណើរបំពេញទស្សន:កិច្ចរបស់ក្រុមប្រតិភូថៃក្នុងឱកាសនោះលោកឧត្តមសេនីយ៍ទោសារុនចាន់ធីស្នងការនគរបាលខេត្តពោធិ៍សាត់។ ជាតំណាងដ៏ខ្ពង់ខ្ពស់លោកម៉ៅធនិនអភិបាលខេត្តបានសម្តែងនូវភាពកក់ក្តៅដែលកន្លងមកថ្នាក់ដឹកខេត្ត និងកងកម្លាំងខាងភាគីកម្ពុជាតែងមានកិច្ចសហប្រតិបត្តិការល្អជាមួយគ្នាក្នុងការពារខ្សែបន្ទាត់ព្រំដែននិងការទប់ស្កាត់បង្ក្រាបនានា។ លោកស្នងការមានប្រសាសន៍ថានិងខិតខំបន្តពង្រឹង និងរិតចំណងមេត្រីភាពនេះឲ្យកាន់តែជិតស្និត និងមានភាពជឿជាក់គ្នាទៅវិញទៅមកក្នុងនាមបងប្អូនដែលជាប្រទេសជាប់ភូមិផងរបងជាមួយ និងមានអរិយធម៌វប្បធម៌ស្រដៀងគ្នា។ជាមួយគ្នានេះលោកស្នងការក៏សំណូមពរខាងភាគីថៃសូមរក្សាចំណងមិត្តភាពដ៏ល្អនេះឲ្យបានជានិច្ចនិរន្ត។ នៅក្នុងឱកាសនោះលោកស្នងការនគរបាលខេត្តពោធិ៍សាត់ក៏បានសំណូមពរថ្នាក់ដឹកនាំប្រតិភូថៃសូមជួយបង្កើនថ្ងៃចេញចូលតាមច្រកលេខ៥៦ និងជួយពន្លឿននីតិវិធីក្នុងការបើកច្រកលេខ៥៦ថ្មីជានេះឲ្យបានឆាប់រហ័សផងដែរ។ ដើម្បីសម្រួលក្នុងការដោះដូរទំនិញកសិផលគ្នាទៅវិញទៅមកនៃប្រជាជនប្រទេសទាំងពីរ។ចំពោះបញ្ហានេះខាងភាគីថៃបានសន្យាថានិងខិតខំនាំយកសំណួមពរទាំងនោះទៅជំរាបថ្នាក់ដឹកនាំរបស់ខ្លួនដើម្បីឆ្លើយតបនៅពេលក្រោយ៕S/

## ថ្ងៃទី២៨ ខែមករា ឆ្នាំ២០១៩

## តុលាការឃុំខ្លួនស្ត្រី ២ នាក់ពាក់ព័ន្ធករណីនាំនារីម្នាក់ទៅរៀបការប្តីនៅចិន

https://www.postkhmer.com/ គីម សារុំ | Publication date 28 January 2019 | 10:00 ICT

ភ្នំពេញៈ អយ្យការអមសាលាដំបូងខេត្តត្បូងឃ្មុំបានឃុំខ្លួនស្ត្រីសង្ស័យ ២ នាក់ នៅពន្ធនាគារខេត្តកាលពីថ្ងៃសុក្រ ភ្លាមៗបន្ទាប់ពីសមត្ថកិច្ចបញ្ជូនខ្លួនទៅតុលាការ ក្រោយពេលឃាត់ខ្លួនកាលពីថ្ងៃទី ២៤ មករាឆ្នាំ២០១៩ នៅភូមិចម្ការថ្មី ឃុំគគីរ ស្រុកត្បូងឃ្មុំ ពាក់ព័ន្ធករណីនាំនារីខ្មែរម្នាក់ទៅរៀបការប្តីនៅប្រទេសចិន ប្រព្រឹត្តកាលពីឆ្នាំ២០១៧។

លោក ថេង ជាង អ្នកនាំពាក្យសាលាដំបូងខេត្តត្បូងឃ្មុំប្រាប់ភ្នំពេញប៉ុស្តិ៍ថា ស្ត្រីឈ្មោះ រ៉ោក ផៃធីម ហៅយាយម៉ៅ អាយុ ៦១ ឆ្នាំនិងស្ត្រី ឈ្មោះ ធូក ថេត អាយុ ៣៨ ឆ្នាំ ដែលរស់នៅភូមិអន្លង់ពោង ឃុំទន្លេបិទ ស្រុកត្បូងឃ្មុំ ត្រូវចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តត្បូងឃ្មុំចោទប្រកាន់និងឃុំខ្លួនហើយកាលពីថ្ងៃសុក្រកន្លងមក។ លោកប្រាប់ថា៖ «ស្ត្រីត្រូវចោទទាំង ២ នាក់ ត្រូវចោទប្រកាន់ពីបទនាំចេញដោយមិនស្របច្បាប់ដោយមានគោលដៅតាមបញ្ញត្តិមាត្រា ១០ ច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស»។ បើយោងតាមមាត្រានេះ ប្រសិនបើតុលាការរកឃើញថាពិតជាបានប្រព្រឹត្តមែននោះ ស្ត្រីទាំង ២ នាក់ ត្រូវប្រឈម នឹងការផ្តន្ទាទោសដាក់ពន្ធនាគារពី ៧ ទៅ ១៥ ឆ្នាំ។

លោកស្រី ហៃ ឡាលីន ស្នងការរងផ្នែកប្រឆាំងការជួញដូរមនុស្សនៃស្នងការដ្ឋាននគរបាលខេត្តត្បូងឃ្មុំបាន ថ្លែងថាការចាប់ខ្លួននេះបានធ្វើឡើងក្រោយពីនារីរងគ្រោះបានប្តឹងទៅក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ ហើយខាងក្រសួងបានប្រាប់មកខេត្តត្បូងឃ្មុំ ដែលជាទីកន្លែងកើតហេតុវិញ។ លោកស្រីបញ្ជាក់ថា៖ «ដំបូងគាត់ [ស្ត្រី រងគ្រោះ] ប្តឹងក្រសួងការបរទេស បន្ទាប់មកក៏ប្តឹងទៅសមត្ថកិច្ចខេត្ត ទើបមានការស្រាវជ្រាវឈានចាប់ខ្លួនជនសង្ស័យ បានតែម្តង»។

លោក សុខ ឈុនឡាយ នាយរងការិយាល័យប្រឆាំងការជួញដូរមនុស្សខេត្តត្បូងឃ្មុំបានប្រាប់កាលពីម្សិល មិញថា ក្រោយឃាត់ខ្លួន ស្ត្រីសង្ស័យទាំង ២ នាក់បានឆ្លើយថា ពួកគេបានស្គាល់ស្ត្រីម្នាក់ឈ្មោះ ឆេង ជាមេខ្យល់ធំ ហើយស្ត្រីនោះបានប្រាប់ពួកគេឲ្យរកនារីក្មេងៗទៅរៀបការប្តីនៅប្រទេសចិននឹងបានកម្រៃ ប៉ុន្តែពួកគេ មិនស្គាល់ទី កន្លែងរស់នៅរបស់ស្ត្រីជាមេខ្យល់នោះទេ។ លោកស្រីបន្តថា៖ «រឿងនេះឈ្មោះ ធូក ថេត បានទទួលលុយពីមេខ្យល់ ឈ្មោះ ឆេង ចំនួន ៣០០ ដុល្លារ ក្នុងការនាំស្ត្រីរងគ្រោះទៅប្រទេសចិន រីឯឈ្មោះ រ៉ាក ឆៃធីម គាត់ថា មិនបានទទួល លុយពីមេខ្យល់ឈ្មោះ ឆេង ទេ»។ លោកបានរំឭក ប្រាប់តាមសម្តីជនរងគ្រោះ ឈ្មោះ ស.ន អាយុ ២៣ ឆ្នាំ ថា មុន កើតហេតុនាង [ជនរងគ្រោះ] បានមានទំនាក់ទំនងជាមួយស្ត្រី ឈ្មោះ រ៉ាក ឆៃធីម ហៅយាយម៉ៅ និងស្ត្រីឈ្មោះ ធូក ថេត (ជាកូនរបស់យាយម៉ៅ) ដោយមានស្ត្រីម្នាក់ ឈ្មោះ ឆេង ជាមេខ្យល់ធំ។ បន្ទាប់ពីរត់ការធ្វើឯកសារចប់សព្វគ្រប់ ក្រុមជនសង្ស័យ បានបញ្ជូននាងទៅដល់ប្រទេសចិនក្នុងអំឡុងឆ្នាំ ២០១៧។ លោកថា តាមសម្តីនារីរងគ្រោះ បន្ទាប់ពី ទៅដល់ប្រទេសចិននាងត្រូវបានបុរសជនជាតិចិនម្នាក់បង្ខាំងទុកក្នុងផ្ទះឲ្យបម្រើផ្លូវភេទអស់ពេល ៤ ខែ។បន្ទាប់មក បុរសចិននោះបានលក់នាងបន្តរហូតដល់ ៤ កន្លែងផ្សេងទៀត ប៉ុន្តែលុះដល់ដើមឆ្នាំ ២០១៨ នាងបានរត់គេចខ្លួនរួច និងបានធ្វើដំណើរមកដល់ប្រទេសថៃ។ លោកបានបញ្ជាក់ថា នារីរងគ្រោះត្រូវបានអង្គការ ១ នៅប្រទេសថៃនិងស្ថាន ទូតកម្ពុជាជួយសង្គ្រោះមកកម្ពុជាវិញ នៅខែវិច្ឆិកា ឆ្នាំ ២០១៨ និងបានប្តឹងទៅក្រសួងការបរទេសកម្ពុជាទើបឈាន ដល់ការចាប់ខ្លួនជនសង្ស័យទាំងនេះ៕

## ថ្ងៃទី២៩ ខែមករា ឆ្នាំ២០១៩

## ក្រសួងមហាផ្ទៃ ចុះហត្ថលេខាលើអនុស្សារណៈនៃការយោគយល់គ្នាជាមួយអង្គការ បេសកកម្មយុត្តិធម៌អន្តរជាតិ (IJM)

https://www.interior.gov.kh/news/ January 29, 2019

នាព្រឹកថ្ងៃអង្គារ ០៩រោច ខែបុស្ស ឆ្នាំច សំរឹទ្ធិស័ក ព.ស២៥៦២ ត្រូវនឹងថ្ងៃទី២៩ ខែមករា ឆ្នាំ២០១៩ ឯក ឧត្តម សន្តិបណ្ឌិត តេង សាវង្ស រដ្ឋលេខាធិការក្រសួងមហាផ្ទៃ បានអញ្ជើញជាអធិបតីក្នុងពិធីចុះហត្ថលេខា លើអនុ ស្សារណៈនៃការយោគយល់គ្នា ជាមួយអង្គការ IJM ដែលដឹកនាំដោយលោក PETER William ប្រធានអង្គការ បេសកកម្មយុត្តិធម៌អន្តរជាតិ នៅទីស្តីការក្រសួងមហាផ្ទៃ។ ក្នុងពិធីចុះហត្ថលេខា លើអនុស្សារណៈនៃការយោគយល់ គ្នានេះ ធ្វើឡើងដើម្បីព្រមព្រៀងគ្នានូវចំណុចខ្វះខាត និងបំពេញបន្ថែមនូវចំណុចដែលល្អនិងមានប្រយោជន៍ដល់ភាគី ទាំងពីរ។ ក្នុងនោះដែរ ថ្នាក់ដឹកនាំក្រសួងមហាផ្ទៃ និងថ្នាក់ដឹកនាំអង្គការបេសកកម្មយុត្តិធម៌អន្តរជាតិ បានសន្យា ពង្រឹង និងបង្កើន កិច្ចសហប្រតិបត្តិការជាមួយគ្នាឱ្យកាន់តែល្អប្រសើរឡើងថែមទៀតលើការងារនេះ។

សូមបញ្ជាក់ថា អង្គការបេសកកម្មយុត្តិធម៌អន្តរជាតិ ហៅកាត់ថា(IJM)នេះ គឺជាអង្គការដែលធ្វើ សកម្មភាពទៅលើការកំណត់អត្តសញ្ញាណ និងការចាប់ខ្លួនជនសង្ស័យ ការត្រៀមខ្លួនឡើងសវនាការ ការការពារសាក្សី ការស៊ើបអង្កេតបណ្តាញឧក្រិដ្ឋជន និងការងារស៊ើបអង្កេតលើករណីជួញដូរមនុស្ស៕ មុនីរម្យ ដោយ៖ នាយកដ្ឋានព័ត៌មានវិទ្យា

**ដល់អាជ្ញាធរខេត្តចុះទៅទើបដោះស្រាយបានស្រេច**

https://kohsantepheapdaily.com.kh/ ថ្ងៃទី ២៨ ខែ មករា ឆ្នាំ ២០១៩ម៉ោង ១៧:២២ច័ន្ទ រស្មី

ខេត្តសៀមរាប ៖ បន្ទាប់ពីទទួលបានព័ត៌មានស្ដីពីការបញ្ឈប់ការងារ និងមិនបានបើកប្រាក់ខែអោយក្មេងស្រីចំនួនពីរនាក់នៅហាងបោកអ៊ុតក្នុងក្រុងសៀមរាប អាជ្ញាធរខេត្តបានចាត់មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈចុះពិនិត្យ និងដោះស្រាយជូនពួកគាត់ ។

ប្រធានមន្ទីរបានចាត់លោក អ៊ឹម ចំរើន អនុប្រធានមន្ទីរជាប្រធានក្រុមការងារកិច្ចការទេសន្តរប្រវេសន៍ បានធ្វើការស្រាវជ្រាវចុះសម្របសម្រួលដោយទំនាក់ទំនងជាមួយម្ចាស់ហាងបោកអ៊ុត N V K សេវសីវិសឡនទ្រី ដែលមានម្ចាស់ហាងឈ្មោះ សំ រចនា ជាជនជាតិខ្មែរ (ប្រពន្ធ) ប្តីជាជនជាតិបរទេស និងកម្មករទាំងពីរនាក់រួមមានឈ្មោះ ថន សុជាតា ភេទស្រី ទីកន្លែងកំណើតភូមិស្រយ៉ូវជើង ឃុំស្រយ៉ូវ ស្រុកស្ទឹងសែន ខេត្តកំពង់ធំ និងឈ្មោះ ណិល ស្រីអែម ភេទស្រី នៅឃុំជ្រោយនាងងួន ស្រុកស្រីស្នំ ខេត្តសៀមរាប ។

តាមរយៈការសាកសួរអំពីមូលហេតុម្ចាស់ហាងបានប្រាប់ថា មូលហេតុដែលបញ្ឈប់ និងមិនបានបើកផ្តល់ជូនប្រាក់ខែដោយសារកម្មករទាំងពីរនាក់ខាងលើមិនយកចិត្តដាក់ក្នុងការងារ (ពេលភ្ញៀវមករកសេវាពួកគេមិនទទួលរាក់ទាក់ភ្ញៀវ និងបោកអ៊ុតសំលៀកបំពាក់ភ្ញៀវមិនស្អាត) ធ្វើឲ្យបាត់អតិថិជនជាច្រើន និងធ្វើឲ្យខូចម៉ាស៊ីនបោកខោអាវទៀតផង ។

បន្ទាប់ពីស្តាប់មូលហេតុ រួចលោក អ៊ឹម ចំរើន អនុប្រធានមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្ត បានធ្វើការពន្យល់អំពីច្បាប់ស្តីពីការងារ និងហេតុផលគ្រប់យ៉ាងដល់ម្ចាស់ហាងជៀសវាងមានវិវាទវែងឆ្ងាយជាមួយគ្នានេះ ថៅកែក៏បានព្រមព្រៀងតាមសំណើរបស់មន្ទីរការងារដោយបានព្រមបើកផ្តល់ជូនកម្មករទាំងពីរខាងលើ តាមការព្រមព្រៀងរវាងថៅកែ និងកម្មករ ដោយម្នាក់ទទួលបាន១៣០ដុល្លារ និងម្នាក់ទៀតទទួលបាន១២០ដុល្លារ គិតទៅតាមចំនួនថ្ងៃដែលបានបម្រើការងារ ។

ជាក់ស្តែងនៅព្រឹកថ្ងៃទី២៨ ខែមករា ឆ្នាំ២០១៩នេះ លោក អ៊ឹម ចំរើន អនុប្រធានមន្ទីរការងារនិងបណ្តុះបណ្តាលវិជ្ជាជីវ ខេត្តសៀមរាប បានប្រគល់ថវិកាជូនកម្មករទាំងពីរដែលបម្រើការងារនៅកន្លែងបោកអ៊ុត NVK រួចរាល់ហើយ ។ ទន្ទឹមនឹងការទទួលបានថវិកានេះកម្មករទាំងពីរនាក់ក៏បានថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះចំណាប់ការរបស់អាជ្ញាធរ ពិសេសលោកស្រី យូ សុភា អភិបាលរងខេត្ត និងជាប្រធានលេខាធិការដ្ឋាន គឧបជ និងមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តសៀមរាប ដែលបានយកចិត្តទុកដាក់ក្នុងការអន្តរាគមន៍ជូនដល់ពួកគាត់ ៕

**គណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ប្រជុំបូកសរុបលទ្ធផលការងារប្រចាំឆ្នាំ ២០១៨ និងលើកទិសដៅ២០១៩**

http://information.gov.kh/ ចេញផ្សាយ ថ្ងៃទី 29 ខែ មករា ឆ្នាំ 2019

AKP ព្រះសីហនុ ថ្ងៃទី២៩ ខែមករា ឆ្នាំ២០១៩ -គណៈកម្មាធិការប្រយុទ្ធប្រឆាំង អំពើជួញដូរមនុស្សខេត្តព្រះសីហនុ បានបើកកិច្ចប្រជុំបូកសរុបលទ្ធផលការងារប្រចាំឆ្នាំ២០១៨ និងលើកទិសដៅការងារ២០១៩ នៅសាលាខេត្ត

ព្រះសីហនុ នារសៀលថ្ងៃចន្ទ ៨រោច ខែបុស្ស ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦២ ត្រូវនឹងថ្ងៃទី២៨ ខែមករា ឆ្នាំ២០១៩ ក្រោមអធិបតីភាពលោកស្រី ហៀក ហ៊ីមុល្លី អភិបាលរងខេត្តព្រះសីហនុ។

លោកស្រី ហៀក ហ៊ីមុល្លី បានមានប្រសាសន៍ថា ខេត្តព្រះសីហនុមានការអភិវឌ្ឍយ៉ាងគំហុករយៈពេលពេញមួយឆ្នាំនេះ ហើយក៏លេចចេញនូវបញ្ហាមួយចំនួន ដែលគណៈកម្មាធិការប្រយុទ្ធប្រឆាំង អំពើជួញដូរមនុស្សខេត្តបានសហការជាមួយអង្គការសកម្មភាព ដើម្បីកុមារ អង្គការមូលនិធិ អង្គការសហប្រជាជាតិដើម្បីកុមារ UNICEF លើបញ្ហាសុវត្ថិភាពកុមារ ។ លោកស្រីបន្តថា ក្រុមការងារលេខាធិការដ្ឋានខេត្ត បានចុះអប់រំផ្សព្វផ្សាយពង្រឹងសមត្ថភាពដល់ក្រុមការងារ បានចំនួន ១៤៧លើក មានសមាសភាពចូលរួម ៩.២៧១នាក់ ស្រី ៤.៦៣៩នាក់ ។ ផ្សព្វផ្សាយ បណ្តុះបណ្តាល ស្តីពីការជួញដូរមនុស្ស ការកេងប្រវ័ញ្ចកម្លាំងពលកម្មកុមារ ការធ្វើចំណាកស្រុកដោយប្រថុយប្រថាន ដើម្បីឱ្យពលរដ្ឋយល់ដឹងអំពីបញ្ហាទាំងអស់នេះ ដើម្បីការពារ និងទប់ស្កាត់បានទាន់ពេលវេលា ។ លេខាធិការដ្ឋានខេត្តចុះផ្សព្វផ្សាយអប់រំកិច្ចការសាធារណៈដោយផ្តោតលើអំពើហិង្សាក្នុងគ្រួសារ ការជួញដូរមនុស្ស អនាម័យសុខភាពពិសេសអប់រំមាតា បិតាបញ្ជូនកូនគ្រប់អាយុឱ្យចូលរៀន ។ បើកវគ្គបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈទេសចរណ៍ ការបញ្ញាបយេនឌ័រ ការកេងប្រវ័ញ្ចកម្លាំង ពលកម្មកុមារ ការជួញដូរផ្លូវភេទចំនួន ១៦វគ្គ មានសមាសភាពចូលរួម ៤៩៣នាក់ ស្រី ២២៩នាក់ ។ អប់រំ ផ្សព្វផ្សាយសកម្មភាពជួញដូរផ្លូវភេទ បញ្ហាសុវត្ថិភាពកុមារបាន ១២វគ្គ អ្នកចូលរួម ៦៣៤នាក់ ស្រី ៣៤៣នាក់ ។ ផ្សព្វផ្សាយគោលនយោបាយភូមិ ឃុំមានសុវត្ថិភាព ១១៤លើក អ្នកចូលរួម ៧.០២១នាក់ ស្រី ៣.០២៦នាក់ ។

ជាលទ្ធផលក្នុងឆ្នាំ២០១៨ បង្ក្រាបបាន ២១ករណី ឃាត់ខ្លួន ៣៣មុខសញ្ញា (ជនជាតិចិន ១៤មុខសញ្ញា ស្រី ២មុខសញ្ញា . វៀតណាម ២នាក់ ស្រី) ។ សង្គ្រោះជនរងគ្រោះ ២៥លើក សរុប ៥០នាក់ ក្នុងនោះ ជនជាតិចិន ២៤នាក់ ជនជាតិម៉ុងហ្គោលី ៥នាក់ និងបញ្ជូនសំណុំរឿងទៅសាលាដំបូងខេត្ត ២៦ករណី ៣៧មុខសញ្ញា(ចិន ១៥នាក់ ប្រុស វៀតណាម ២នាក់ ស្រី )។ លោកស្រី ហៀក ហ៊ីមុល្លី បានបញ្ជាក់ថា ទន្ទឹមនោះក៏មានបញ្ហាប្រឈមមួយចំនួនដោយប្រធានក្រុមការងារជំនាញមានភារកិច្ចស្មុគស្មាញ តែពុំមានថវិកាបើកវគ្គបណ្តុះបណ្តាល ផ្សព្វផ្សាយការ ជួញដូរមនុស្សដល់សហគមន៍នៅតាមមូលដ្ឋាន ។ ទិសដៅបន្តស្រាវជ្រាវមុខសញ្ញាជនសង្ស័យតាមសណ្ឋាគារ ផ្ទះសំណាក់ ខារ៉ាអូខេ ក្លិបកម្សាន្តរាត្រី កាស៊ីណូ ។ សហការជាមួយ បណ្តាញស៊ើបការណ៍តាមឆ្នេរសមុទ្រ ដែលប្រកបអាជីវកម្មផ្លូវភេទ ការជួញដូរមនុស្សក្នុងស្រុក និងឆ្លងដែន បម្រើឱ្យការបង្ការ និងបង្ក្រាបបទល្មើសជួញដូរមនុស្ស និងការពារអនីតិជន ឱ្យទទួលបានជោគជ័យ ៕ ដោយ ងូ សុមុនី

## ចុះបង្ក្រាបទីតាំងម៉ាស្សាកោសជប់ និង ឃាត់ខ្លួនថៅកែ២នាក់ និង នារីបម្រើការ២នាក់ នៅខណ្ឌដង្កោ

http://www.rasmeinews.com/ January 29, 2019, 9:25 AM

*ដោយៈចាន់ត/ភ្នំពេញ ៖* ម្ចាស់ទីតាំងម៉ាស្សាកោសជប់ ប្រុសស្រី២នាក់ និងនារីបម្រើការងារ២នាក់ទៀត ដែលស្ថិតនៅផ្ទះលេខ៣៥១ ជាប់ផ្លូវលេខ៣៧១ ក្នុងភូមិម័ល សង្កាត់ដង្កោ ខណ្ឌដង្កោ ត្រូវបានកម្លាំងនគរបាលប្រឆាំងការជួញដូរមនុស្ស និងការពារអនិជន ចុះបង្ក្រាបនិងឃាត់ខ្លួនកាលពីវេលាម៉ោង៧ និង១០នាទីយប់ ថ្ងៃទី២៨ ខែមករា ឆ្នាំ ២០១៩ ដោយពួកគេពាក់ព័ន្ធករណី លួចបង្កប់សេវាបម្រើផ្លូវភេទ ។

ក្នុងប្រតិបត្តិការណ៍ចុះបង្ក្រាបករណីខាងលើនេះ គឺមានការសម្របសម្រួលដោយលោកស្រី ស៊ឺ វណ្ណី ព្រះរាជអាជ្ញារងអមសាលាដំបូងរាជធានីភ្នំពេញ ចុះមកផ្ទាល់ផងដែរ ។ យោងតាមប្រភពពីសមត្ថកិច្ចបានប្រាប់ឱ្យដឹងថា មុនឈានដល់ការចុះបង្ក្រាបទីតាំងម៉ាស្សាខាងលើនេះ ដោយទទួលបានពាក្យបណ្តឹងរបស់ម្តាយនារីបម្រើការនៅក្នុងទីតាំងម៉ាស្សាម្នាក់ដែលមានអាយុ១៧ឆ្នាំ បាមចាញ់ល្បួងរបស់គេឱ្យមកធ្វើការក្នុងហាងម៉ាស្សា រួចក៏ល្បួងឱ្យបម្រើសេវាផ្លូវភេទជាមួយភ្ញៀវ ហើយនារីនោះក៏បានតេទៅប្រាប់ម្តាយ រួចម្តាយក៏ទៅដាក់ពាក្យបណ្តឹងនៅការិយាល័យប្រឆាំងការជួញដូរមនុស្ស និង ការពារអនីតិជនឲ្យជួយអន្តរាគមន៍ ។ ខណៈសមត្ថកិច្ចជំនាញទទួលពាក្យបណ្តឹងរួចហើយ ក៏បានបើកការស្រាវជ្រាវរហូតឈានដល់ការចុះបង្ក្រាបទីតាំងខាងលើតែម្តង ។

ក្រោយពីបញ្ចប់ការចុះបង្ក្រាបករណី ដែលលួចបង្កប់សេវាបម្រើផ្លូវភេទ ខាងលើនេះ សមត្ថកិច្ចបាននាំខ្លួនម្ចាស់ទីតាំងប្រុសស្រី២នាក់ និងនារីបម្រើការងារអនីតិជន២នាក់ បញ្ជូនទៅកាន់ការិយាល័យប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន ដើម្បីសួរនាំបន្តនីតិវិធី៕B/

## សាលាឧទ្ធរណ៍សម្រេចប្រកាសសាលដីកា បន្ថយទោសដល់ស្ត្រីជាប់ចោទម្នាក់ ១ ឆ្នាំ

https://www.postkhmer.com/ គឹម សារុំ | Publication date 29 January 2019 | 08:20 ICT

ភ្នំពេញៈ សាលាឧទ្ធរណ៍បានសម្រេចបន្ថយទោសស្ត្រីជាប់ចោទម្នាក់ចំនួន ១ ឆ្នាំ ជាប់ចោទបទសញ្ជារកម្មមានស្ថានទម្ងន់ទោស ដោយសារបានបើកកន្លែងម៉ាស្សាបង្កប់សេវារួមភេទប្រព្រឹត្តកាលពីឆ្នាំ ២០១៥ នៅសង្កាត់ទួលសង្កែ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ។

ការសម្រេចនេះធ្វើឡើងបន្ទាប់ពីសាលាឧទ្ធរណ៍កាលពីម្សិលមិញបានបើកសវនាការប្រកាសសាលដីកាចំពោះមុខស្ត្រីជាប់ចោទម្នាក់ដោយបន្ថយទោសពីជាប់ពន្ធនាគារ ៦ ឆ្នាំមកនៅ ៥ ឆ្នាំវិញ។ សវនាការជំនុំជម្រះបានធ្វើឡើងកាលពីថ្ងៃទី ១៥ មករា តែពេលនោះពុំបានប្រកាសសាលដីកាភ្លាមទេ។

នៅក្នុងបន្ទប់សវនាការពីម្សិលមិញលោកស្រីចៅក្រម ចាន់ ម៉ាឌីណា មិនបានបញ្ជាក់ពីមូលហេតុនៃការបន្ថយទោសដល់ស្ត្រីជាប់ចោទនោះទេ ដោយគ្រាន់តែប្រាប់ទៅស្ត្រីជាប់ចោទថាតុលាការមិនបានអានសំអាងហេតុដល់ជនជាប់ចោទទេដោយគ្រាន់តែអានសេចក្តីសម្រេចជូនប៉ុណ្ណោះ។ លោកស្រីថ្លែងថាៈ «ស្ត្រីជាប់ចោទបើអ្នកមិនសុខចិត្តនឹងការសម្រេចសេចក្តីរបស់សាលាឧទ្ធរណ៍ទេអ្នកអាចប្តឹងសារទុក្ខទៅតុលាការកំពូលបន្តទៀតបាន គិតចាប់ពីថ្ងៃប្រកាសសាលដីកានេះ ១ ខែ»។

យោងតាមកំណត់ហេតុរបស់តុលាការបានឲ្យដឹងថាស្ត្រីជាប់ចោទឈ្មោះ លឹម ណៃអន អាយុ ៣៨ ឆ្នាំបានបើកកន្លែងម៉ាស្សាកោសជប់មួយកន្លែងមានឃីហោឈ្មោះ ៩៩៩ ស្ថិតនៅក្នុងភូមិ-សង្កាត់ទួលសង្កែ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញហើយត្រូវបាននគរបាលនៃការិយាល័យប្រឆាំងការជួញដូរមនុស្សរាជធានីភ្នំពេញចុះឆែកឆេរនិងឃាត់ខ្លួននារីម៉ាស្សាបានចំនួន ៤ នាក់កាលពីរសៀលថ្ងៃទី ១០ ខែវិច្ឆិកាឆ្នាំ ២០១៥។ ក្នុងប្រតិបត្តិការនោះសមត្ថកិច្ចឃាត់ខ្លួនបាននារីបម្រើការក្នុងហាងម៉ាស្សាកោសជប់នោះសរុបចំនួន ៥ នាក់ប៉ុន្តែក្រោយមកសមត្ថកិច្ចបានដោះលែងនារីម៉ាស្សាចំនួន ៤ នាក់វិញហើយបានឃាត់ខ្លួនស្ត្រីជាប់ចោទជាម្ចាស់ហាងម៉ាស្សាកោសជប់នេះ។ ពេលនោះសមត្ថកិច្ចបានឆែកឆេរក្នុងហាងម៉ាស្សាកើតហេតុនិងបានរកឃើញស្រោមអនាម័យទាំងប្រើហើយនិងមិនទាន់ប្រើបានមួយចំនួនធំ។

សំណុំរឿងនេះត្រូវសាលាដំបូងបើកសវនាការកាលពីថ្ងៃទី ២០ មីនា ២០១៦ និងប្រកាសសាលក្រមនៅថ្ងៃទី ២៧ ខែមីនាឆ្នាំ ២០១៦ ដោយសម្រេចផ្តន្ទាទោសស្ត្រីជាប់ចោទដាក់ពន្ធនាគារ ៦ ឆ្នាំចោទបទសញ្ជារកម្មមានស្ថានទម្ងន់ទោសដោយទាក់ទងនឹងចារីតាមបញ្ញត្តិមាត្រា ២៧ ច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្សនិងធ្វើអាជីវកម្មផ្លូវភេទ និងមាត្រា ២៨៨ នៃក្រមព្រហ្មទណ្ឌ។

កាលពីថ្ងៃជំនុំជម្រះកន្លងមកស្ត្រីជាប់ចោទលឹម ណៃអនបានប្រាប់ចៅក្រមថា គាត់ប្តឹងមកសាលាឧទ្ធរណ៍ ពេលនេះដោយសារគាត់ចង់ឲ្យសាលាឧទ្ធរណ៍បន្ថយទោសដល់គាត់ព្រោះមានកូនតូចនៅក្នុងបន្ទុក ៣ នាក់គ្មានអ្នក ថែទាំហើយពួកគេមិនបានរៀនសូត្រត្រឹមត្រូវទេ។ ម្យ៉ាងម្តាយគាត់ចាស់ជរាហើយគាត់បានដឹងថា មានកំហុសហើយ៕

## ពលករបរទេសខ្លះនៅថៃរួមទាំងខ្មែរ ពុំទាន់ចុះឈ្មោះទទួលសេវាថែទាំសុខភាព

https://www.postkhmer.com/ ខន សាវិ | Publication date 29 January 2019 | 09:00 ICT

ភ្នំពេញៈ ពលករមួយចំនួន ក្នុងចំណោមពលករប្រមាណជិត ៥ លាននាក់ ដែលកំពុងធ្វើការទាំងស្របច្បាប់ និងមិនស្របច្បាប់នៅក្នុងប្រទេសថៃ ក្នុងនោះក៏មានកូនៗរបស់ពួកគេប្រមាណ ២០ ម៉ឺននាក់ និងក៏មានពលករខ្មែរ ប្រមាណជិត ២ លាននាក់ផងដែរនោះនៅពុំទាន់ត្រូវបានចុះឈ្មោះ ដើម្បីទទួលបានសេវាថែទាំសុខភាពនៅឡើយ ហើយកូនៗរបស់ពួកគេវិញ ក៏កំពុងប្រឈមមិនបានរៀនសូត្រផងដែរ។

របាយការណ៍ដែលចេញកាលពីថ្ងៃទី ២៤ ខែមករា របស់ទីស្នាក់ការសម្របសម្រួលជនស្នាក់នៅនៃអង្គការ សហប្រជាជាតិប្រចាំប្រទេសថៃ (Office of the United Nations Resident Coordinator) ស្តីពីជនអន្តោប្រវេសន៍ក្នុង ប្រទេសថៃនៅឆ្នាំ ២០១៩ នេះបង្ហាញថា បច្ចុប្បន្ន ប្រទេសថៃ មានជនអន្តោប្រវេសន៍ប្រហែល ៤ លាន ៩ សែននាក់ ហើយក្នុងនោះចំនួន ៣ លាន ៩ សែននាក់ គឺជាពលករស្របច្បាប់មកពីប្រទេស មីយ៉ាន់ម៉ា វៀតណាម ឡាវ និង ប្រទេសកម្ពុជា។ ជនអន្តោប្រវេសន៍ទាំងនេះបានផ្តល់អត្ថប្រយោជន៍ជាច្រើនទៅដល់ប្រទេស ថៃ ដូចជាការបំពេញភាព ខ្វះខាតកម្លាំងពលកម្ម និងបានចូលរួមចំណែកពីចន្លោះជាង ៤% ទៅជាង ៦% នៃផលិតផលក្នុងស្រុកដែលជួយសេដ្ឋ កិច្ចប្រទេសថៃឲ្យរីកចម្រើន។

ផ្ទុយទៅវិញនៅក្នុងរបាយការណ៍បញ្ជាក់ថា នៅតែមានជនអន្តោប្រវេសន៍ជាច្រើនបន្តប្រឈមនឹងទុក្ខលំបាក និងបន្តក្លាយជាជនរងគ្រោះដែលត្រូវគេរំលោភបំពានថ្វីដ្បិតស្ថានភាពសម្រាប់ជនអន្តោប្រវេសន៍ ក្នុងប្រទេស ថៃ មាន លក្ខណៈល្អប្រសើរខ្លះ ចាប់ពីឆ្នាំ ២០១៤ ក្តី។ របាយការណ៍បានកត់សម្គាល់ថា ជនអន្តោប្រវេសន៍ស្របច្បាប់មានតែ ៥១% ប៉ុណ្ណោះ ដែលគេចុះឈ្មោះសម្រាប់ទទួលបានសេវាថែទាំសុខភាពខណៈកូនៗរបស់ពួកគេចំនួន ២ សែននាក់ បន្តគ្មានឱកាសចូលសិក្សារៀនសូត្រនៅឡើយ។

ទោះបីយ៉ាងណា របាយការណ៍នេះមិនបានបញ្ជាក់ថា តើក្នុងចំណោមនោះមានពលករកម្ពុជាចំនួនប៉ុន្មាននាក់ ទេ ប៉ុន្តែ បើតាមលោក ហេង សួរ អ្នកនាំពាក្យក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ពលករខ្មែរស្របច្បាប់មាន ជាង ១ លាននាក់ ខណៈលោក មឿន តុលា នាយកប្រតិបត្តិនៃមជ្ឈមណ្ឌលសម្ព័ន្ធភាពការងារ និងសិទ្ធិមនុស្សលើក ឡើងថា តាមការប៉ាន់ប្រមាណចុងក្រោយ អាចមានចំនួនពី ១ លាន ៧ សែននាក់ ទៅដល់ ២ លាននាក់ ហើយក្នុង ចំណោមអ្នកទាំងនេះ ប្រហែល ២០% គឺជាពលករខុសច្បាប់។ លោកតុលាថ្លែងថា ថ្វីដ្បិតពលករស្របច្បាប់ មានការ ធានារ៉ាប់រងពីរបបសន្តិសុខសង្គម សម្រាប់ថែទាំសុខភាពក្តី ប៉ុន្តែពួកគេខ្លះ នៅតែមានឧបសគ្គទទួលសេវានេះដដែល ដោយសារមានក្តីព្រួយបារម្ភអំពីការប្រើភាសានៅពេលត្រូវទៅព្យាបាលនៅតាមមន្ទីរពេទ្យរដ្ឋនានារបស់ថៃ ដែលបញ្ហា នេះកើតឡើង ដោយសាររោងចក្រមួយចំនួន មិនបានរកអ្នកបកប្រែភាសាសម្រាប់ពលករបរទេស។ បើតាមលោក តុលា អ្នកដែលទទួលបានការធានារ៉ាប់រងសុខភាពគឺភាគច្រើន ជាពលករបំពេញការងារនៅតាមបណ្តារោងចក្រធំៗ ដូចជារោងចក្រផលិតសម្លៀកបំពាក់ និងគ្រឿងអេឡិចត្រូនិកជាដើម ប៉ុន្តែសម្រាប់ពលករវិស័យសំណង់ កសិកម្ម និង

នៅតាមភោជនីយដ្ឋាន ឬហាងបាយតូចតាចវិញ មិនទទួលបានសេវានេះទេ។ លោកថា៖ «បញ្ហាមួយទៀតរឿងកូន ដោយសារពួកគាត់ចំណាកស្រុកជាគ្រួសារ អ៊ីចឹងក្មេងនៅតែអត់ទាន់បានចូលសាលា និងអត់ទទួលបានសេវាផ្សេងៗពីរដ្ឋគេទេ រឿងហ្នឹងដោះអត់ទាន់ចេញទេ អាហ្នឹងទាមទារឱ្យរដ្ឋទាំងពីរកម្ពុជា-ថៃ ត្រូវជជែកគ្នា ហើយស្នើឱ្យភាគីថៃ ដោះរឿងហ្នឹង»។ លោកគុលា បន្ថែមថា ក្រៅពីនេះ ក៏មានពលករខ្លះ ត្រូវបានអាជ្ញាធរថៃ ចាប់ឃុំឃាំង ដោយសារតែពួកគាត់ប្រើប្រាស់លិខិតឆ្លងដែនខុសច្បាប់ តាមការចាញ់បោកមេខ្យល់ និងខ្លះទៀត ដែលមិនស្របច្បាប់ ត្រូវបានថៅកែថៃបញ្ឆោតឱ្យធ្វើការអស់ជាច្រើនខែ និងក្រោយមកមិនបើកប្រាក់ខែឱ្យ ហើយថៃមទាំងហៅអាជ្ញាធរថៃ មកចាប់ខ្លួនពួកគាត់ថែមទៀត។ លោកគុលាថ្លែងទៀតថា លោកក៏កំពុងព្រួយបារម្ភ ចំពោះពលករធ្វើការនៅតាមទូកនេសាទ និងវិស័យសំណង់ខ្លះ ដែលត្រូវបានគេបង្ខំឱ្យប្រើប្រាស់គ្រឿងញៀនឱ្យមានកម្លាំងដើម្បីបំពេញការងារ ហើយមិនទទួលបានប្រាក់ខែ។

ចំណែកលោក ហេង សួរ អ្នកនាំពាក្យក្រសួងការងារ លើកឡើងដែរថា ថ្វីត្បិតរដ្ឋាភិបាលកម្ពុជាបានសហការជាមួយរដ្ឋាភិបាលថៃផ្តល់ភាពស្របច្បាប់ ១០០ ភាគរយដល់ពលករកម្ពុជាបានជាង ១ លាននាក់ក្តី ប៉ុន្តែក្រសួងនៅតែព្រួយបារម្ភថា ពលករទាំងនោះ អាចក្លាយជាពលករខុសច្បាប់វិញ ប្រសិនបើពួកគេរំលោភច្បាប់ការងាររបស់ថៃ។ «យោងទៅតាមច្បាប់ការងារថៃ ទោះបីជានៅខែ ៦ ឆ្នាំ ២០១៨ ដែលរាជរដ្ឋាភិបាលបានសហការជាមួយរាជ រដ្ឋាភិបាលថៃ ផ្តល់ភាពស្របច្បាប់ដល់ពួកគាត់ក៏ដោយ ប៉ុន្តែប្រសិនជាគាត់ធ្វើការផ្លាស់ប្តូរកន្លែងធ្វើការដោយមិនបានសុំការអនុញ្ញាតពីមន្ទីរការងារថៃជាមុនទេគឺគាត់អាចក្លាយជាអ្នកខុសច្បាប់វិញ អានេះគឺជាក្តីព្រួយបារម្ភរបស់យើង»។ លោកបន្តថា រដ្ឋាភិបាលប្រទេសទាំង ២ ក៏បានចុះអនុស្សរណៈយោគយល់គ្នា ដើម្បីផ្តល់ឱ្យពលករខ្មែរមានសិទ្ធិពេញលេញទៅតាមច្បាប់នៃប្រទេសថៃ ដូចជាការធានារ៉ាប់រងគ្រោះថ្នាក់ ការងារផ្នែកសុខភាព និងការទទួលបានប្រាក់បៀវត្សរ៍ពេញលេញជាដើម។

នៅពេលទាក់ទងតាមទូរស័ព្ទកាលពីម្សិលមិញ លោក ណៃ សម្បត្តិ ដែលជាពលករខ្មែរម្នាក់កំពុងធ្វើការនៅក្នុងរោងចក្រផលិតកន្ស្រែងពោះគោ នៅខេត្តឈុនបូរី ឲ្យដឹងថា ក្នុងរយៈពេល ២-៣ ឆ្នាំចុងក្រោយនេះ ការរំលោភសិទ្ធិពលករខ្មែរ និងរូបភាពប្រើហិង្សាផ្សេងៗលើពលករខ្មែរហាក់ដូចជាស្ងប់ស្ងាត់ច្រើន ដោយសារបច្ចុប្បន្ន ពលករជាច្រើនបានទទួលភាពស្របច្បាប់ដើម្បីបំពេញការងារ។ «ស្ថានភាពពលករដែលមកធ្វើការនៅក្នុងប្រទេស ថៃ ឥឡូវ ហាក់មានភាពស្ងប់ស្ងាត់ខ្ញុំចង់និយាយថា វាមានលំនឹងព្រោះពួកគាត់ភាគច្រើនស្របច្បាប់ ប៉ុន្តែគ្រាន់តែថា តាមរោងចក្រមួយចំនួន អារឿងប្រាក់ចំណូលពួកគាត់ វាអត់ដូចគ្នា ដោយសារសេដ្ឋកិច្ចថៃវាអត់សូវល្អដែរ»៕ Contact author: ខន សាវិ

## ថ្ងៃទី៣០ ខែមករា ឆ្នាំ២០១៩

## គណៈកម្មាធិការសុវត្ថិភាពកុមារបើកកិច្ចប្រជុំតុមូល ស្ដីពីការគេចប្រឆាំងនឹងខ្លឹមសារតាមប្រព័ន្ធអ៊ីនធឺណិត

http://information.gov.kh/detailnews/ ចេញផ្សាយ ថ្ងៃទី 29 ខែ មករា ឆ្នាំ 2019

AKP ព្រះសីហនុ ថ្ងៃទី២៩ ខែមករា ឆ្នាំ២០១៩ ៖ គណៈកម្មាធិការប្រយុទ្ធប្រឆាំង អំពើជួញដូរមនុស្សខេត្តព្រះសីហនុ បើកកិច្ចប្រជុំតុ មូលនៅសណ្ឋាគារឆ្នេរថ្មី សង្កាត់លេខ៣ ក្រុងព្រះសីហនុ ក្រោមអធិបតីលោកស្រី ហៀក

ហ៊ីមុល្លី អភិបាលរងខេត្តព្រះសីហនុ មានការចូលរួមពីតំណាងគណៈកម្មាធិការប្រយុទ្ធ ប្រឆាំងអំពើជួញដូរមនុស្សខេត្ត តំណាងមន្ត្រីនគរបាលខេត្ត តំណាងអង្គការក្រៅ រដ្ឋាភិបាល ខេត្ត តំណាងវិស័យឯកជន និងយុវជន សិស្សានុសិស្ស ប្រមាណ៧០នាក់ នាព្រឹកថ្ងៃអង្គារ ៩រោជ ខែបុស្ស ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦២ ត្រូវនឹងថ្ងៃទី២៩ ខែមករា ឆ្នាំ ២០១៩។ លោកស្រី ហៀក ហ៊ីមុល្លី មានប្រសាសន៍ថា បច្ចេកវិទ្យាព័ត៌មានបានដើរតួយ៉ាងសំខាន់ ក្នុងការអភិវឌ្ឍរបស់កុមារនៅប្រទេសកម្ពុជា ដោយសារស្ថានភាពបច្ចុប្បន្ននៃការកេងប្រវ័ញ្ច ផ្លូវភេទលើកុមារតាមប្រព័ន្ធ Internet មានការកើនឡើង ដើម្បីឆ្លើយ តប និងទប់ស្កាត់ចំពោះករណីកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធ Internet និងការចូលរួមចែក រំលែក និងកិច្ចសហប្រតិបត្តិការរបស់អង្គការដៃគូ ក្នុងការការពារសុវត្ថិភាពកុមារ របស់អង្គការដៃគូ ដើម្បីរៀបចំយុទ្ធសាស្ត្រឆ្លើយតបចំពោះករណី កេងប្រវ័ញ្ចលើផ្លូវភេទលើ កុមារតាមប្រព័ន្ធ Internet ។

លោកស្រីបន្តថា ការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអ៊ីនធឺណិតបានក្លាយជា ការព្រួយបារម្ភកាន់តែខ្លាំង ក្នុងចំណោមអ្នកពាក់ព័ន្ធនានា ដែលធ្វើការផ្នែកការពារកុមារ មានអង្គការសកម្មភាព ដើម្បីកុមារបានដាក់ឱ្យដំណើរការនូវបណ្តាញរាយការណ៍តាមប្រព័ន្ធ Internet (IHC) ចាប់ពីឆ្នាំ២០១៥មក។ គណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ខេត្តព្រះសីហនុ បានសហការជាមួយអង្គការក្រៅរដ្ឋាភិបាល យុវជន សិស្សានុសិស្ស និងតំណាងវិស័យឯកជន ចូលរួមការពារកុមារពីការកេងប្រវ័ញ្ចផ្លូវភេទតាមប្រព័ន្ធ Internet។ ការប្រជុំពិភាក្សានាពេលនេះ ដើម្បីជំរុញឱ្យអ្នកចូលរួមទាំងអស់តាមដាន បង្ការ និងរាយ ការណ៍ ក៏ដូចជាការបង្ហាញ ឱ្យឃើញនូវវត្តមានរបស់បណ្តាញអ្នករាយការណ៍ ពិសេសតាម ប្រព័ន្ធ Internet ដើម្បីរាយការណ៍ ពីជនសង្ស័យ នៃអំពើកេងប្រវ័ញ្ចផ្លូវភេទ ព្រមទាំងសម្ភារ រំលោភបំពានផ្លូវភេទ (CSAM)ផ្សេងទៀត ដើម្បីចូលរួមចំណែកក្នុងការការពារសុវត្ថិភាព កុមារកាន់តែល្អប្រសើរ។ លោកស្រីសង្ឃឹមថា ហានិភ័យ នៃការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធ Internet (OCSE) និងសុវត្ថិភាពកុមារតាមប្រព័ន្ធអ៊ីនធឺណិត និងទទួលបាននូវវិធីសាស្ត្រត្រឹមត្រូវ ក្នុងការតាមដានរាយការណ៍ បង្ការ ទប់ស្កាត់ និងការចែករំលែក ចំណេះដឹង និងពិភាក្សាស្វែងរកដំណោះស្រាយបានទាន់ពេលវេលា៕ ដោយ ងូ សុមុនី

## រដ្ឋាភិបាល ចិន និងវៀតណាម សម្រុកបញ្ជូនពលករចេញទៅធ្វើការនៅជប៉ុនកាន់តែច្រើន

https://cambonomist.com/news/ January 30, 2019

ក្នុងចំណោម ពលករបរទេសដែលធ្វើការនៅប្រទេសជប៉ុន១៥ ប្រទេស ពលករជនជាតិ និងវៀតណាម គឺឈរក្នុងលំដាប់លេខ១ និងលេខ ២ ដែលបានចូលទៅធ្វើការនៅប្រទេសជប៉ុនច្រើនជាងគេបំផុត ខណៈដែលកម្ពុជា គឺឈរក្នុងលំដាប់លេខរៀងទី ៧។ នៅ៥ឆ្នាំខាងមុខនេះ ប្រទេសជប៉ុនរំពឹងថា នឹងមានពលករប្រទេសចូលមកធ្វើការប្រមាណ ៣៤ម៉ឺននាក់ បន្ថែមទៀត ខណៈដែលចិន និងវៀតណាមកំពុងសម្រុកបញ្ជូនពលករចូលមកធ្វើការនៅជប៉ុនកាន់តែច្រើន។

របាយការណ៍ ពីរាជរដ្ឋាភិបាលជប៉ុន ដែលបានបង្ហាញនៅក្នុងសារព័ត៌មានជប៉ុន Asian Nikkei Review បានឲ្យដឹងថា ចំនួនពលករបរទេស ដែលធ្វើការនៅប្រទេសជប៉ុន បច្ចុប្បន្ន បានកើនឡើងខ្ពស់បំផុតមិនធ្លាប់មានឡើយ រហូតដល់ ជាង ១,៤លាននាក់ ដែលមានកំណើន២ដង គិតត្រឹម៥ឆ្នាំចុងក្រោយនេះ ខណៈដែលប្រទេសជប៉ុន កំពុងប្រឈមនឹងកង្វះកម្លាំងពលកម្ម។ បើមើលទៅលើរបាយការណ៍ ឃើញថា ពលករចិន និងវៀតណាម គឺឈរក្នុងតំណែងលេខរៀងទី ១ និងលេខ២ ដែលបានបញ្ជូនពលករទៅធ្វើការនៅជប៉ុនច្រើនជាងគេបំផុត។ តួយ៉ាង គិតនៅត្រឹមខែតុលាឆ្នាំ ២០១៨ ពលរជនជាតិចិន ដែលធ្វើការនៅជប៉ុនមានជិត ៤០ម៉ឺននាក់ ស្មើនឹងប្រមាណ ២៧% នៃ

ចំនួនពលករបរទេសសរុបដែលធ្វើការនៅជប៉ុន។ រីឯ ពលកររៀតណាមវិញ មានប្រមាណជាង ៣១ម៉ឺននាក់ ស្មើនឹង ២២% នៃពលករបរទេសសរុប។ បន្ទាប់មក គឺពលករពីជនជាតិភីលីពីន ឈរលំដាប់លេខ៣ មានប្រមាណ១៦ម៉ឺននាក់ ស្មើនឹង១១% ។ របាយការណ៍ បានបង្ហាញទៀតថា បើមើលទៅលើអត្រាកំណើនប្រចាំឆ្នាំ នៃចំនួនពលករគិតជាភាគរយ ឃើញថា ពលកររៀតណាម គឺមានកំណើនខ្ពស់ជាងគេ ពោលគឺចំនួនពលកររៀតណាមបានកើនឡើង ៣២% ឯណោះ បើធៀបនឹងឆ្នាំមុន។

ដោយឡែក បើតាមរបាយការណ៍ពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ កម្ពុជា បានឲ្យដឹងដែរថា គិតត្រឹមដើមឆ្នាំ២០១៩នេះ កម្ពុជា បានបញ្ជូនពលករ កម្មសិក្សាការីទៅធ្វើការនៅប្រទេសជប៉ុន មានចំនួន ប្រមាណជិត ១ម៉ឺននាក់ និងឈរក្នុងលំដាប់លេខរៀងទី ៧ នៃចំនួនពលករបរទេស ទាំង១៥ ប្រទេស។ ក្នុងចំណោមពលករពីក្រៅប្រទេសទាំងអស់ ដែលធ្វើការនៅជប៉ុន មានលើស ៤៣ម៉ឺននាក់ ឬស្មើនឹង៣០% គឺធ្វើការនៅក្នុងឧស្សាហកម្មផលិត និងមានប្រមាណ ១៤% ទៅ ១៧% ផ្សេងទៀត គឺធ្វើការក្នុង វិស័យលក់រាយ និងសេវាកម្មម្ហូបអាហារ និងភេសជ្ជៈ។ ដ្បិតតែ ចំនួនពលករបរទេសមានការកើនឡើងជាលំដាប់ក៏ពិតមែន ប៉ុន្តែ ចំនួននេះ គឺនៅតែមានចំណែកតូចនៅឡើយ បើធៀបនឹងកម្លាំងពលកម្មក្នុងស្រុករបស់ជប៉ុន ពោលគឺមានប្រមាណ តែ ២% ប៉ុណ្ណោះ។
គួរបញ្ជាក់ថា កាលពីពេលថ្មីៗនេះដែរ រាជរដ្ឋាភិបាលជប៉ុន ក៏ទើបតែបានសម្រេចអនុម័តច្បាប់ថ្មីទាក់ទងនឹងពលករបរទេសនេះដែរ ដោយនឹងត្រូវចូលជាធរមាននៅ ខែមេសាខាងមុខនេះ ហើយបើតាមការប៉ាន់ស្មានរបស់រាជរដ្ឋាភិបាលប្រទេសនេះ ច្បាប់ថ្មីនេះ អាចនឹងលើកទឹកចិត្តឲ្យពលករពីក្រៅប្រទេស ចូលមកធ្វើការក្នុងប្រទេសជប៉ុនកាន់តែច្រើនឡើងថែមទៀត ពោលគឺអាចមានលើសពី ៣៤ម៉ឺននាក់ គិតត្រឹមរយៈពេល ៥ឆ្នាំបន្ទាប់នេះ៕

## ថ្ងៃទី៣១ ខែមករា ឆ្នាំ២០១៩

### រដ្ឋមន្ត្រីក្រសួងសង្គមកិច្ចៈ "ក្នុងឆ្នាំ២០១៨ ក្រសួងសម្រេចបាននូវលទ្ធផលផ្លែផ្កា៧ចំណុច"

http://www.rasmeinews.com/ January 30, 2019, 2:36 PM

ដោយៈ ប៊ុនណាត / បាត់ដំបងៈ នៅសាលប្រជុំ នៃសណ្ឋាគារខេមរា១ កាលពីព្រឹកថ្ងៃទី៣០ខែមករាឆ្នាំ ២០១៩ នៅក្នុងសន្និបាតបូកសរុបលទ្ធផលការងារឆ្នាំ២០១៨ និងទិសដៅអនុវត្តបន្តឆ្នាំ២០១៩ និងការប្រកាសដាក់ឱ្យអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍវិស័យសង្គកិច្ចអតីតយុទ្ធជន និងយុវនីតិសម្បទា២០១៩-២០២៣ លោក វង សូត រដ្ឋមន្ត្រីក្រសួងសង្គកិច្ចអតីតយុទ្ធជន និងយុវនីតិសម្បទាមានប្រសាសន៍ថា "ក្នុងឆ្នាំ២០១៨ក្រសួងសម្រេចបាននូវលទ្ធផលផ្លែផ្កា៧ចំណុច"។ លោករដ្ឋមន្ត្រីបានបញ្ជាក់ថា លទ្ធផលដែលក្រសួងសម្រេចបានជាផ្លែផ្កាទាំង៧ចំណុច រួមមានៈ

១.សេវាសុខាភិបាលសម្រាប់ជនក្រីក្រងាយរងគ្រោះ កុមារ មនុស្សចាស់ អតីតមន្ត្រីរាជការស៊ីវិល អតីតយុទ្ធជនត្រូវបានពង្រឹងនិងពង្រីក។ ២.វិស័យសុខុមាលភាពកុមារបានបន្តរីកចម្រើនឥតឈប់ឈរ។ ការធ្វើអាជីវកម្មតាមគ្រប់រូបភាពលើកុមារ អំពើហិង្សាលើកុមារ ការប្រើប្រាស់ពលកម្មកុមារ អំពើពេស្យាចារលើកុមារ ការជួញដូរកុមារ អំពើអនាចារនិងអសីលធម៌ផ្សេងៗ លើកុមារត្រូវបានចាត់វិធានការបង្ការនិងទប់ស្កាត់ជាជំហានៗ។ ៣.វិស័យសុខុមាលភាពជនពិការ ត្រូវបានយកចិត្តទុកដាក់ខ្ពស់ដូចជាៈ ការស្តារលទ្ធភាពពលកម្ម ការបណ្តុះបណ្តាលវិជ្ជាជីវៈ ការបង្កើត

មុខរបរជូនជនពិការជាពិសេសការអនុវត្តន៍គោលនយោបាយជនក្រីក្រនៅតាមសហគមន៍។ ៤.វិស័យសុខុមាលភាពមនុស្សចាស់ ត្រូវបានយកចិត្តទុកដាក់ជាប្រចាំ។ សមាគមមនុស្សចាស់ត្រូវបានបង្កើតជាបន្តបន្ទាប់ នៅតាមឃុំ សង្កាត់ ដើម្បីជួយរំលែកទុក្ខលំបាករបស់មនុស្សចាស់។ ទន្ទឹមនឹងនេះ មណ្ឌលថែទាំមនុស្សចាស់គ្រោងដាក់ឱ្យដំណើរការក្នុងពេលឆាប់ៗខាងមុខដែលទទួលមនុស្សក្រីក្រគ្មានទីពឹងឱ្យស្នាក់នៅ និងជាថ្នាលបណ្តុះបណ្តាលធនធានមនុស្សសម្រាប់បម្រើឱ្យកិច្ចថែទាំមនុស្សចាស់ផងដែរ។ ៥.វិស័យអតីតយុទ្ធជនបានបន្តពង្រឹងពង្រីកសកម្មភាពរបស់ខ្លួនប្រកបដោយភាពស្វាហាប់ និងទទួលបានលទ្ធផលផ្លែផ្កាជាបន្តបន្ទាប់។ បេឡាមរណសង្គ្រោះកំពុងដំណើរការយ៉ាងសកម្ម រួមចំណែកជួយសម្រួលទុក្ខលំបាក ការឧបត្ថម្ភគាំទ្រនិងលើកស្ទួយជីវភាពបងប្អូនអតីតយុទ្ធជន ដែលធ្វើឱ្យបងប្អូនអតីតយុទ្ធជននិងគ្រួសារទទួលបានការសាទរយ៉ាងខ្លាំង។ ៦.របបសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល និងអតីតយុទ្ធជនបាននិងជំរុញឱ្យកាន់តែប្រសើរឡើងតាមរយៈការបើកផ្តល់តាមប្រព័ន្ធធនាគារ ប្រកបដោយប្រសិទ្ធភាព គណនេយ្យភាព និងទាន់ពេលវេលា។ ទន្ទឹមនេះ របបសន្តិសុខសង្គមត្រូវបានកែសម្រួល និងតម្លើងជាបន្តបន្ទាប់ស្របតាមការវិវត្ត នៃសេដ្ឋកិច្ចជាតិ និង ៧.ជំរុញបង្កើនចំនួនបុគ្គលិកសង្គមកិច្ច (Social Worker) តាមរយៈវិទ្យាស្ថានជាតិសង្គមកិច្ច សម្រាប់បម្រើឱ្យវិស័យសង្គមកិច្ចទាំងកម្រិតមធ្យម និងឧត្តមរាប់រយនាក់ក្នុងមួយឆ្នាំៗ ស្របតាមតម្រូវការសង្គមជាតិ និន្នាការសេដ្ឋកិច្ចនិងសង្គមក្នុងបរិបទ នៃចរន្តសកលភាវូបនីយកម្ម។

ក្នុងពិធីនេះដែរ លោករដ្ឋមន្ត្រីបានប្រកាសចូលកាន់តំណែងរបស់លោក ខុម ផលលឿន ជានាយកវិទ្យាស្ថានជាតិសង្គមកិច្ច។ បន្ទាប់ពីលោក ងួន រ៉ានី រដ្ឋលេខាធិការក្រសួងសង្គកិច្ចអតីតយុទ្ធជននិងយុវនីតិសម្បទា បានឡើងអានរបាយការណ៍បូកសរុបលទ្ធផលការងារឆ្នាំ២០១៨ និងទិសដៅអនុវត្តបន្តឆ្នាំ២០១៩ និងការប្រកាសដាក់ឱ្យអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍវិស័យសង្គកិច្ចអតីតយុទ្ធជន និងយុវនីតិសម្បទា២០១៩-២០២៣ និងមានបទអន្តរាគមន៍ជាច្រើននាក់ទៀត៕ ល

## ប្រជាពលរដ្ឋរស់នៅ ក្នុងសង្កាត់លេខ២ ក្រុងព្រះសីហនុ ត្អូញត្អែររឿងស្រីៗ រកស៊ីផ្លូវភេទ តាមចិញ្ចើមថ្នល់ យ៉ាងអណាធិបតេយ្យ ដោយពុំឃើញមានអជ្ញាធរ ឬសមត្ថកិច្ចពាក់ព័ន្ធណា មកបង្រាបឡើយ

https://khmer.social/social/ Pheak Tra January 31, 2019

ខេត្តព្រះសីហនុៈ ថ្មីៗនេះ មានប្រជាពលរដ្ឋរស់នៅក្នុងសង្កាត់លេខ២ បាននិយាយរៀបរាប់ប្រាប់អ្នកយកព័ត៍មានយើងអោយបានដឹងថា ដោយលោកស្រីបានស្នើសុំកុំអោយបញ្ចេញឈ្មោះគាត់ ហើយលោកស្រីបានរៀបរាប់បន្តថា រូបគាត់មិនពេញចិត្តទេ ព្រោះរូបគាត់ជាស្ត្រីខ្មែរម្នាក់ ដែលបានឃើញស្រីៗ ជាជនជាតិចិន នឹងជនជាតិវៀតណាម មានទាំងស្រីៗជនជាតិថៃ ក្នុងនោះក៏មានខ្មែរមួយចំនួនផង គិតជារួមមានរហូតទៅដល់៤សាសន៍ផង។ លោកស្រីបានបន្តទៀតថា រូបគាត់មានចិត្តបារម្ភណ៍ខ្លាំងណាស់ ព្រោះគាត់មានប្តីមានកូនខ្លាចអនាគតទៅមុខទៀត កូនខ្ញុំកូនគេវាមិនដឹងជាយ៉ាងណា បើឥឡូវនេះវាមានស្រីៗ បើកហាងរកស៊ីផ្លូវភេទ តាមចិញ្ចើមថ្នល់យ៉ាងនេះទៅហើយ ពួកគេរកស៊ីបានយ៉ាងអណាធិបតេយ្យដោយពុំឃើញមានអជ្ញាធរ ឬសមត្ថកិច្ចពាក់ព័ន្ធណា មកបង្រាប់ឡើយ។

ជាក់ស្តែងថ្មីៗនេះ យើងបានសង្កេតឃើញទីតាំងមួយកន្លែង ស្ថិតនៅក្នុងភូមិ១សង្កាត់២ ក្រុងព្រះសីហនុ គេហៅឈ្មោះថា ស្ទឹងខៀវ គឺជាកន្លែងនាក់រកស៊ីផ្លូវភេទ បានដាក់ឃីហោជ្រកក្រោមផ្លាកផ្ទះសំណាក់ទាំងអស់ នៅចំណុចភូមិ១ សង្កាត់លេខ២ ជិតផ្លូវធំចំម្ងាយ40ម៉ែត្រ គឺជាកន្លែងទីតាំងអ្នករកស៊ីផ្លូវភេទ ជាទីតាំងអមផ្លូវសងខាង

ប្រវែង១០០ម៉ែត្រដោយមានសកម្មភាពបានយ៉ាងរលូន នេះគួរអោយបញ្ជាក់ថា គេហានរកស៊ីបំពានមកលើច្បាប់យ៉ាងនេះ តើលោកមេប៉ុស្តិ៍នគបាលសង្កាត់លេខ២ អាចដឹងឬទេ បើលោកមិនដឹងច្បាស់ជាមានអ្នកណាម្នាក់បើកភ្លើងខៀវនោះអោយគេហើយ ទើបពួកគេមិនខ្លាចគេហ៊ានបំពាននឹងប្រឆាំចំពោះច្បាប់៕

## អ្នកផលិតវីដេអូ«ម្តាយខ្ញុំលក់ខ្ញុំ»ស្អែកនេះសាលាឧទ្ធរណ៍ចាត់ការហើយ

https://kohsantepheapdaily.com.kh/ ថ្ងៃទី ៣០ ខែ មករា ឆ្នាំ ២០១៩ម៉ោង ១៥:៤៨ស.សុខុម (អ៊ាង ម៉េងឡេង)

រាជធានីភ្នំពេញ ក្រុមប្រឹក្សាជំនុំជម្រះនៃសភាស៊ើបសួរសាលាឧទ្ធរណ៍ដែលដឹកនាំដោយលោកចៅក្រម សួស សំអាត នៅព្រឹកថ្ងៃទី៣០ ខែមករា ឆ្នាំ២០១៩នេះបានបើកសវនាការជាអសាធារណៈលើបណ្តឹងសុំនៅក្រៅឃុំរបស់ប្រធានសហជីពកម្មករសំណង់ពាក់ព័ន្ធការផលិតវីដេអូរឿងម្តាយខ្ញុំលក់ខ្ញុំ ។

សវនាការនេះបានបញ្ចប់នៅវេលាម៉ោង១០និង៤៥នាទី និងប្រកាសសាលដីកានៅព្រឹកស្អែកថ្ងៃទី៣១ ខែមករានេះ ។ ខណៈពេលដែលតុលាការកំពុងបើកសវនាការមានក្រុមគ្រួសារសាច់ញាតិរបស់ជនសង្ស័យបានមកតវ៉ាដោយបានលើកបដាដែលសរសេរថា«ដោះលែងមុន្នី» និងមានកាន់រូបថតរបស់ជនសង្ស័យចំនួន២សន្លឹកផង ។ កាលពីថ្មីៗក្រុមគ្រួសារជនសង្ស័យបាននាំគ្នាទៅតវ៉ាសុំអន្តរាគមន៍នៅមុខស្ថានទូតរុស្ស៊ី និងនៅមុខសាលាដំបូងរាជធានីភ្នំពេញ ដែលមានអ្នកចូលរួមប្រមាណជាង១០នាក់ ។

គួររំលឹកផងដែលថា កាលពីវេលាម៉ោងប្រមាណជិត៧យប់ ថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០១៨ ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញបានសម្រេចឃុំខ្លួនជនជាប់ចោទម្នាក់ដាក់ពន្ធនាគារព្រៃស ជាបណ្តោះអាសន្ន ក្រោមការចោទប្រកាន់ពីបទញុះញង់អោយមានការរើសអើងតាមបញ្ញត្តិមាត្រា៤៩៦ នៃក្រមព្រហ្មទណ្ឌពាក់ពន្ធករណីផលិតខ្សែវីដេអូរឿង (ម្តាយខ្ញុំលក់ខ្ញុំ) ។

សមត្ថកិច្ចបញ្ជាក់ថា ជនជាប់ចោទមានឈ្មោះ វ៉ាត់ វ័ន្នមុនី ភេទប្រុស អាយុ៤៧ឆ្នាំ មុខរបរជាប្រធានសហជីពកម្មករសំណង់ដែលមានមូលដ្ឋាននៅប្រទេសថៃមានទីលំនៅផ្ទះជួលម្តុំវត្តអង្គតាមិញ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ និងមានស្រុកកំណើតនៅភូមិឆាយរំពាត់ ឃុំកន្ទឺ ស្រុកបាណន់ ខេត្តបាត់ដំបង ។ ក្នុងសំណុំរឿងនេះដើមបណ្តឹងជានាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជននៃក្រសួងមហាផ្ទៃ ៕

## រដ្ឋបាលខេត្តកោះកុង ជំរុញដោះស្រាយបញ្ហាប្រឈមនានាលើការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស

https://www.interior.gov.kh/report/ January 30, 2019

នៅថ្ងៃពុធ ១០រោច ខែបុស្ស ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦២ ត្រូវនឹងថ្ងៃទី៣០ ខែមករា ឆ្នាំ២០១៩ លោកស្រី ឈុន វ៉ាវុធ អភិបាលរង នៃគណៈអភិបាលខេត្តកោះកុង និងជាប្រធានលេខាធិការដ្ឋានខេត្ត បានអញ្ជើញដឹកកិច្ចប្រជុំពិភាក្សាការងារប្រចាំខែមករា និងលើកទិសដៅការងារបន្តរបស់លេខាធិការដ្ឋាន នៃគណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។

លោកស្រីអភិបាលរងខេត្ត សូមអោយសមាជិក សមាជិកា នៃអង្គប្រជុំទាំងអស់យកចិត្តទុកដាក់លើរបាយការណ៍ប្រចាំខែមករា ឆ្នាំ២០១៩ ព្រមទាំងពិភាក្សាអំពីបញ្ហាប្រឈម ដំណោះស្រាយ និងលើកទិសដៅអនុវត្តបន្តអោយកាន់តែមានប្រសិទ្ធភាព និងស័ក្តិសិទ្ធិបន្ថែមទៀត៕ មុនីមេ្យ ប្រភពៈរដ្ឋបាលខេត្តកោះកុង

## ការធ្វើកសិដ្ឋានចម្រុះ ធ្វើឲ្យពលរដ្ឋលែងចង់ចំណាកស្រុក

http://km.rfi.fr/cambodia/ ចុះផ្សាយនៅថ្ងៃ 30/01/2019

ជារៀងរាល់ថ្ងៃ មានពលរដ្ឋខ្មែរ មិនតិចទេ ដែលបានធ្វើចំណាកស្រុកទៅរកការងារធ្វើនៅក្រៅប្រទេស ឬ មានពលរដ្ឋខ្លះ ធ្វើចំណាកស្រុក ពីខេត្តមួយ ទៅខេត្តមួយ ក្នុងគោលបំណងស្វែងរកការងារដែលអាចរកចំណូលបានច្រើន។ ការចំណាកស្រុកទាំងនោះ ដោយពួកគេភាគច្រើន អស់សង្ឃឹមនឹងការរកចំណូលពីការងារនៅក្នុងភូមិកំណើត។ ប៉ុន្តែពលរដ្ឋដែលធ្លាប់ចំណាកស្រុកមួយចំនួន នៅខេត្តសៀមរាប បានស្អប់លាចំពោះពាក្យថាធ្វើចំណាកស្រុក នៅពេលពួកគេបានចាប់ផ្តើមធ្វើកសិអេកូឡូស៊ី (Agroecology) ឬ ហៅថាជាការដាំបន្លែសុវត្ថិភាព។ ការដាំបន្លែ ក្រោមការជួយគាំទ្រពីគម្រោងរបស់អង្គការ Gret និង CIRD ត្រូវបានពលរដ្ឋស្វាគមន៍ ដោយពួកគេយល់ថា បានចូលរួមចំណែកក្នុងការកាត់បន្ថយភាពក្រីក្រ បានធ្វើការជួបជុំក្រុមគ្រួសារ ព្រមទាំងមិនបារម្ភពីបញ្ហាសុវត្ថិភាពក្នុងការទទួលទានបន្លែទាំងនោះ។

## ដឹងទេ! ពលរដ្ឋខ្មែរចេញ-ចូលផ្សាររ៉ុងក្លឿប៉ុន្មានម៉ឺននាក់ក្នុងមួយថ្ងៃ

https://kohsantepheapdaily.com.kh/ ថ្ងៃទី ៣១ ខែ មករា ឆ្នាំ ២០១៩ម៉ោង ១០:៤៩ប៊ុន ធឿន

ខេត្តបន្ទាយមានជ័យ ៖ ប្រជាពលរដ្ឋខ្មែរដែលបានចេញ-ចូលផ្សាររ៉ុងក្លឿ ប្រទេសថៃ ដែលទិញសំបុត្រទៅព្រឹកវិលល្ងាចក្នុងមួយថ្ងៃប្រមាណជិត២ម៉ឺននាក់ មានទាំងអាជីវករ និងកម្មករ។ ជាក់ស្តែងនៅល្ងាចថ្ងៃទី២៩ ខែមករា ឆ្នាំ ២០១៩ កន្លងទៅនេះ នៅច្រកទ្វារអន្តរជាតិប៉ោយប៉ែតខេត្តបន្ទាយមានជ័យ គេឃើញមានប្រជាពលរដ្ឋត្រឡប់ពីផ្សាររ៉ុងក្លឿ ប្រទេសថៃ ចូលមកក្រុងប៉ោយប៉ែតវិញមានចំនួនច្រើន ដែលភាគច្រើនមានអាជីវករ និងកម្មករបានត្រឡប់ពីលក់ដូរវិញនៅពីផ្សាររ៉ុងក្លឿ ស្ថិតក្នុងស្រុកអារញ្ញប្រាថេត ខេត្តស្រះកែវ ប្រទេសថៃ ដែលប្រឈម ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ ប្រទេសកម្ពុជា។

លោក សាន ស៊ានហូរ អភិបាលក្រុងប៉ោយប៉ែតបានប្រាប់កាលពីរសៀលថ្ងៃទី៣០ ខែមករា ឆ្នាំ២០១៩នេះថា ប្រជាពលរដ្ឋដែលរស់នៅក្រុងប៉ោយប៉ែតបានចេញចូលទៅលក់ដូរនៅផ្សាររ៉ុងក្លឿ ប្រទេសថៃ តាមច្រកទ្វារអន្តរជាតិប៉ោយប៉ែត ក្នុង១ថ្ងៃមិនតិចជាង២ម៉ឺននាក់ ដែលបានទិញសំបុត្រចេញ-ចូលទៅរកស៊ី មានទាំងអាជីវករ និងកម្មករដែលបានទៅលក់ដូរនៅផ្សាររ៉ុងក្លឿ ប្រទេសថៃមានដល់៨០ភាគរយ។ លោកបានបញ្ជាក់ថា មានអាជីវករខ្មែរមួយចំនួនបានទៅស្នាក់នៅក្នុងផ្សាររ៉ុងក្លឿ និងស្រុកអារញ្ញ ប្រទេសថៃដោយស្របច្បាប់ទៅប្រកបមុខរបរលក់ដូរនៅផ្សាររ៉ុងក្លឿ ដែលបានជួលតូបលក់ដូរទំនិញជាមធ្យមក្នុង១តូបតំលៃ៥ទៅ១០ម៉ឺនបាត។

ដោយយោងតាមរបាយការណ៍ប្រចាំខែធ្នូ ឆ្នាំ២០១៨ កន្លងទៅនេះ ដែលស្នាក់ការត្រួតពិនិត្យច្រកទ្វារអន្តរជាតិប៉ោយប៉ែត សរុបអ្នកដំណើរចេញ-ចូលមានចំនួន១.០៧១.០៤៧នាក់ (ស្រី៥១៣.៧៧៩នាក់) ក្នុងនោះមានសញ្ជាតិខ្មែរមានចំនួន៩៩១.៦៦៩នាក់ (ស្រី៤៦៧.៣២៨នាក់) និងជានជាតិបរទេសមានចំនួន៧៩.៣៧៨នាក់ (ស្រី៤៦.៤៥១នាក់) ភ្ញៀវបរទេសមានចំនួន៧៧.០៨៨នាក់៕

## ថ្ងៃតែមួយ ថៃបញ្ជូនសពពលករ២នាក់មកស្រុកកំណើតវិញ

https://kohsantepheapdaily.com.kh/ ថ្ងៃទី ៣០ ខែ មករា ឆ្នាំ ២០១៩ម៉ោង ១៧:០៥ម៉ុត សារុន

ខេត្តបន្ទាយមានជ័យ ៖ សពពលករខ្មែរ២នាក់ត្រូវភាគីថៃធ្វើការបញ្ជូនត្រឡប់មកវិញកាលពីវេលារសៀលក្នុងថ្ងៃតែមួយ (ថ្ងៃទី៣០ មករា ២០១៩) តាមច្រកទ្វារអន្តរជាតិប៉ោយប៉ែត ក្រោយជនរងគ្រោះទាំង២នាក់ស្លាប់ដោយសារជម្ងឺគាំងបេះដូងដូចគ្នា ប៉ុន្តែក្នុងខេត្តផ្សេងគ្នា គឺខេត្តសាមុទ្រប្រាកាន និងខេត្តណាខនណាយុគ។

ករណីនៅខេត្តសាមុទ្រប្រាកាន បានកើតឡើងកាលពីវេលាម៉ោង១០យប់ថ្ងៃទី២៩ មករា ២០១៩ ដោយជនរងគ្រោះឈ្មោះឈន នឿត ហៅយី ភេទប្រុស អាយុ៤២ឆ្នាំ ជាកម្មកររោងចក្រដែកនៅក្នុងខេត្តសាមុទ្រប្រាកាន និងមានទីលំនៅភូមិឫស្សីក្រោក ឃុំឫស្សីក្រោក ស្រុកមង្គលបូរី ខេត្តបន្ទាយមានជ័យ។

ដោយឡែកករណីមួយទៀតនៅខេត្តណាខនណាយុគ បានកើតឡើងកាលពីវេលាទៀបភ្លឺឈានចូលព្រឹកថ្ងៃទី៣០ មករា ២០១៩ ជនរងគ្រោះឈ្មោះរ៉ាន់ រ៉ាត់ ភេទប្រុស អាយុ៣៧ឆ្នាំ ជាកម្មករសំណង់នៅខេត្តណាខនណាយុគប្រទេសថៃ និងមានទីលំនៅភូមិព្រៃស្វាយ ឃុំរហាល ស្រុកព្រះនេត្រព្រះ ខេត្តបន្ទាយមានជ័យ។

ក្រុមគ្រួសារសាច់ញាតិរបស់ជនរងគ្រោះទាំង២នាក់បានប្រាប់ថា ជនរងគ្រោះស្លាប់ដោយសារជំងឺគាំងបេះដូង។ សពជនរងគ្រោះម្នាក់ត្រូវបានសាច់ញាតិជួលរថយន្តដឹកបន្តទៅលំនៅដ្ឋាន រីឯសពជនរងគ្រោះម្នាក់ទៀតត្រូវបានសាច់ញាត់ដឹកតាមរ៉ឺម៉កម៉ូតូកង់បីទៅធ្វើបុណ្យនៅភូមិព្រៃគប់ សង្កាត់ផ្សារកណ្តាល ក្រុងប៉ោយប៉ែត (ផ្ទះសាច់ញាតិ)៕

## ថៃថាកំណើនសេដ្ឋកិច្ចខ្លួន បានមកពីកម្លាំងពលកម្មរបស់ពលកររបរទេសនៃប្រទេសជិតខាង

http://www.wmc.org.kh/ ថ្ងៃពុធ ទី៣០ ខែមករា ឆ្នាំ២០១៩ នួន បូរិន

ក្នុងឆ្នាំ២០១៩នេះ របាយការណ៍អន្តោប្រវេសន៍ថៃ ប៉ាន់ប្រមាណថាមានពលករមកពីប្រទេសជិតខាងជិត៥លាននាក់ ដែលមានអ្នកកាន់កាប់ឯកសារស្របច្បាប់រួមទាំងខុសច្បាប់ពីបួនប្រទេស កម្ពុជា ឡាវ វៀតណាម និង មីយ៉ាន់ម៉ា ជិត៤លាននាក់។ ពី កាសែត The Nation ឬ ប្រជាជាតិថៃ បានរៀបរាប់សរសើរពីកំណើនសេដ្ឋកិច្ចប្រទេសខ្លួនតាមរយៈវិភាគទាននៃពលករចំណាកស្រុក បំពេញកង្វះពលកម្មក្នុងប្រទេសដែលពួកគេមក ពីប្រទេសបួននៅក្នុងព្រំដែនអាស៊ីអាគ្នេយ៍ជាមួយគ្នា រួមមានកម្ពុជា វៀតណាម ឡាវនិង មីយ៉ាន់ម៉ា។

ថៃថា ភាគរយនៃកម្លាំងពលកម្មសរុបបង្កើតបានជាង១០ភាគរយ ហើយប្រមាណជា ៤,3 ទៅ ៦,៦ភាគរយបានមកពីកម្លាំងពលករមកពីបរទេសមកធ្វើការនៅទីនេះ គឺជួយដល់ផលិតផលជាតិក្នុងស្រុកថៃ។ តែយ៉ាងណាកាសែតនោះអះអាងថា ក៏មានពលករមិនតិចដែរ ដែលជួបការលំបាក និងរងគ្រោះរំលោភបំពាន ទោះការគ្រប់គ្រងស្ថានភាពជនអន្តោប្រវេសន៍នៅប្រទេសនេះមានភាពរីកចម្រើនច្រើនបើធៀបនឹងឆ្នាំ២០១៤។ ជាមួយគ្នានេះដែរមន្ត្រីជាន់ខ្ពស់អង្គការសម្ព័នសិទ្ធិពលករ និងការងារកម្ពុជា ហៅកាត់ថា សង់ត្រាល់ បានប្រាប់ The Nation ថា ប្រមាណ២០ភាគរយនៃពលករកម្ពុជាចំណាកប្រទេស ជិត ១លាន៧សែននាក់ ទៅ២លាននាក់ ហើយពួកគាត់មួយចំនួនពុំមានលិខិតកាន់កាប់ស្របច្បាប់នោះទេ ហើយជាបញ្ហាប្រឈមសម្រាប់ពួកគេ នៅថ្ងៃណាមួយ ។ ក្នុងនោះពលករច្រើនទៀតពិបាកក្នុងការប្រាស្រ័យទាក់ទងនិយោជក ក្នុងភាសាថៃ សេវាកម្មថៃ ពេទ្យ សាលារៀន រីកូនៗរបស់ពួកគេមិនអាចចូលសាលារដ្ឋបាន ។ ឯពលករខ្លះទៀតត្រូវបានចាប់ខ្លួនដោយការបន្លំប៉ះស្ព័រ ខ្លះទៀតត្រូវថៅកែបោកប្រើដោយមិនឱ្យប្រាក់ឈ្នួលថែមទាំងហៅប៉ូលីសមកចាប់ទៀត ជាពិសេសលោកព្រួយបារម្ភទៅនឹងកម្មករនេសាទត្រី និង កម្មករ

សមណាង់ដែលពួកគេខ្លះបង្ខំចិត្តជក់ថ្នាំយកកម្លាំងធ្វើការដោយឥតមានទទួលប្រាក់ថ្ងៃ ឬ ខែអ្វីសោះ តែលោកបានបញ្ជាក់ទៀតថា ក្រុមហ៊ុន ឬ រោងចក្រធំៗមិនបង្កជាផលវិបាកដល់ពលករកម្ពុជាច្រើននោះទេ។

រដ្ឋមន្ត្រីក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈកម្ពុជា ឆ្លើយតបថា រដ្ឋាភិបាលកំពុងធ្វើការរឿងនេះដើម្បីឱ្យពលរដ្ឋចំណាកស្រុកទាំងអស់ជាង១លាននាក់១០០ភាគរយទៅធ្វើការស្របច្បាប់ តែខ្លាចតែកម្មករទាំងនោះបំពានច្បាប់ពលកម្មថៃពេលធ្វើការក៏មិនអាចកំណត់បាន។

ផលិតផលជាតិក្នុងស្រុកថៃ ក្នុងឆ្នាំ២០១៧ មានចំនួន ៤៥៥ពាន់លានដុល្លារដែលប្រជាជនម្នាក់រស់នៅសមម្យេគឺ ៦ពាន់៥រយដុល្លារ និងមានសន្ទុះកំណើនសេដ្ឋកិច្ច4.1 ភាគរយក្នុងឆ្នាំ២០១៨៕

## អាជ្ញាធរថៃចាប់បានពលករភូមាចំនួន37នាក់ ករណីឆ្លងដែនចូលប្រទេសថៃខុសច្បាប់

https://www.facebook.com/search/ ទឹកចិត្ត ពលករ ឆ្លងដែន 31-1-2019

30-1-2019 អាជ្ញាធរថៃចាប់បានពលករភូមាចំនួន37នាក់ ក្នុងករណីឆ្លងដែនចូលប្រទេសថៃខុសច្បាប់ ប្រុស 33នាក់ ស្រី4នាក់ និងក្មេងតូចម្នាក់ ពលករភូមាទាំងអស់នេះត្រូវបានអាជ្ញាធរថៃចាប់បាននៅក្នុងស្រុកថាខាម ភូមិតាសេស ខេត្តធុមផន នៅប្រទេសថៃ។ (អំពីខ្ញុំ ទឹកចិត្ត ពលករ ឆ្លងដែន)